ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ទស្សនបង្រួបបង្រួមជាតិសម្រាប់តំបន់អន្លង់វែង
- សំឡេងពីស្រុកអន្លង់វែង : មរតកអតីតកាល និង ជីវិតបច្ចុប្បន្ន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៥២ ខែសីហា ឆ្នាំ២០១២

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១៥២ ខែសីហា ឆ្នាំ២០១២

## មាតិកា

◆ទស្សនបង្រួបបង្រួមជាតិសម្រាប់តំបន់អន្លង់វែង ........ ១

**ផ្នែកឯកសារ**

◆ចម្លើយសារភាពរបស់ ខែក ប៊ុន ហៅ ស៊ូ គណៈទាក់ទងថៃ ........ ៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆សំឡេងពីស្រុកអន្លង់វែង ........ ១៨

◆សិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅ ........ ២៥

◆អ្នកជាំបាយនៅអគ្គភាពក-៦ ........ ២៧

◆ស្រុកកំណើតរបស់ នួន ជា នៅភូមិវត្តគរ ........ ២៩

◆ឈប់រៀនដើម្បីបម្រើសិល្បៈបដិវត្តន៍ តែបដិវត្តន៍ ........ ៣១

◆បែកទាំងកុមារភាព ........ ៣៣

◆ត្រូវចង់ស្លាបសេកដោយសាររត់ទៅជួបម្ដាយ ........ ៣៥

◆បែកម្ដាយបីឆ្នាំ ចំណាំមុខម្ដាយលែងបាន ........ ៣៧

◆ខ្សែសង្វាក់នៃការចាប់ខ្លួននៅក្រសួងការបរទេស ........ ៤១

**ផ្នែកច្បាប់**

◆តើច្បាប់អាចលប់លើនយោបាយដែរឬយ៉ាងណា ........ ៤៥

**វេទិកាពិភាក្សាសាធារណៈ**

◆សេចក្ដីសម្រេចលើការប្រព្រឹត្តខុសក្រមសីលធម៌ ........ ៥១

◆ហេតុអ្វីបានជាត្រូវចាំបាច់ផ្សព្វផ្សាយពីកិច្ចដំណើរការ ........ ៥៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ស៊ីវ ធួន ៖ ដំណើរឆ្លងកាត់របបខ្មែរក្រហម ........ ៥៧

◆ប្រវត្តិអ្នកម្ដាយ ........ ៦០



លោក ញាណ សុជាតិ កំពុងបង្រៀនពីរបបកម្ពុជាប្រជាធិបតេយ្យដល់គរុនិស្សិតនៃវិទ្យាស្ថានជាតិអប់រំ

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ ៖*** *អេង កុកថាយ, ឆាយ ឈុនលី, ម៉ម សុវណ្ណ, ចាន ប្រុញ, ហ៊ុយ សម្ផស្ស, ពៅ ពុទ្ធារី, ហ៊ុន សុធានី, អេន ហេនឌល, គ្រីស្តូហ្វើ ឌៀរីង, ស៊ីវ ធួន, ហេង សំណាង* ***អ្នកនិពន្ធនិងស្រាវជ្រាវ ៖*** *ទាវ សារៈមុនិន្ទ, សោម ប៊ុនថន, ស៊ិន សុធីតា* ***អ្នកបកប្រែ ៖*** *ញាណ សុជាតិ* ***និពន្ធនាយកទូទៅ ៖*** *ឆាំង យុ* ***ជំនួយការនិពន្ធនាយក ៖*** *ញាណ សុជាតិ* ***ក្រាហ្វិកកុំព្យូទ័រ ៖*** *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ ៖*** *ឆេង វើង* Email: dccam@online.com.kh, Homepage: www.dccam.org

# ធស្សនបង្រួបបង្រួមជាតិសម្រាប់តំបន់អន្លង់វែង

អន្លង់វែងគឺជាតំបន់តស៊ូចុងក្រោយបង្អស់របស់ខ្មែរក្រហម ។ នាដំណាក់កាលចុងក្រោយ កងទ័ពខ្មែរក្រហមទាំងអស់បានមកផ្តុំកម្លាំងគ្នានៅតំបន់នេះដោយបង្កើតកងពលយ៉ាងហោចណាស់ក៏ចំនួនប្រាំបួនដែរ ។ ប្រជាជនដែលរស់នៅតំបន់អន្លង់វែងនាពេលបច្ចុប្បន្ននេះភាគច្រើនគឺជាអតីតកម្មាភិបាល និងកងទ័ពខ្មែរក្រហម ព្រមទាំងសាច់ញាតិរបស់កម្មាភិបាល និងកងទ័ពទាំងនោះ ។ ប្រជាជនមួយចំនួនតូចគឺជាអ្នកចំណូលថ្មីដែលបានចូលមករស់នៅតំបន់អន្លង់វែងនាដើមទសវត្សរ៍៩០ ដើម្បីមករស់នៅជាមួយអតីតកម្មាភិបាលខ្មែរក្រហមដែលជាសាច់ញាត្តិរបស់ខ្លួន ។ បច្ចុប្បន្ននេះ អន្លង់វែងលែងជាតំបន់ដាច់ស្រយាលទៀតហើយ ។ អន្លង់វែងបានផ្សារភ្ជាប់ជាមួយតំបន់ផ្សេងទៀតជាច្រើនទូទាំងប្រទេស ក្នុងនោះមានផ្លូវសំខាន់ពីរខ្សែដែលភ្ជាប់ទៅកាន់តំបន់អន្លង់វែងគឺផ្លូវមកពីទីរួមខេត្តសៀមរាបនិងផ្លូវពីខេត្តព្រះវិហារ ព្រមទាំងមានច្រកអន្តរជាតិមួយទៅកាន់តំបន់ដាច់ស្រយាលនៃខេត្តស៊ីសាកេត ប្រទេសថៃ ។

តំបន់អន្លង់វែងត្រូវបានគ្រប់គ្រងនិងដឹកនាំដោយអតីតលេខាភូមិភាគនិរតីរបស់របបកម្ពុជាប្រជាធិបតេយ្យគឺ តាម៉ុក ដែលធ្លាប់ទទួលខុសត្រូវលើការបន្សុទ្ធនៃអតីតកម្មាភិបាលខ្មែរក្រហមជាច្រើននាក់ក្នុងអំឡុងឆ្នាំ១៩៧៧ និង១៩៧៨ ។ ទោះបីជា តាម៉ុក មានឈ្មោះជាមនុស្សកាចសាហាវពីអតីតកាលក្តី នៅពេលដែលជួបជាមួយអ្នកស្រុកអន្លង់វែងនាពេលបច្ចុប្បន្ននេះ ភាគច្រើនបានអះអាងថា តាម៉ុក ជាបុគ្គលដែលមានចិត្តសប្បុរសម្នាក់ និងជាមេដឹកនាំដែលចូលខ្លួនយ៉ាងជិតជាមួយប្រជាជនសាមញ្ញ ដែលប្រជាជនទាំងអស់អាចប្រាស្រ័យទាក់ទងបានដោយផ្ទាល់



អ្នកភូមិ និងសិស្សានុសិស្ស ចូលរួមពិធីសម្ពោធពាក្យស្លោកនៅវិទ្យាល័យអន្លង់វែងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២

យ៉ាងល្អូកល្អឺនក្នុងសកម្មភាពប្រចាំថ្ងៃ ។ តាម៉ុក ធ្លាប់ជាមនុស្សដ៏ប៉ិនប្រសប់ម្នាក់ ដែលធ្វើឲ្យអំពើកាប់សម្លាប់ដែលខ្មែរក្រហមបានប្រព្រឹត្តិនៅភូមិភាគនិរតីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនមាននៅក្នុងការចងចាំរបស់អ្នកស្រុកអន្លង់វែងទេ ។

ដោយការចងចាំមិនភ្លេចអំពីការកាប់សម្លាប់ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ដល់១៩៧៩ តើយើងអាចនិយាយទៅកាន់អតីតកម្មាភិបាលខ្មែរក្រហមនិងកូនចៅរបស់អ្នកទាំងនោះនៅតំបន់អន្លង់វែងដោយវិធីណា? ម្យ៉ាងទៀត បច្ចុប្បន្នតំបន់អន្លង់វែងនិងតំបន់ផ្សេងទៀតទូទាំងប្រទេសកំពុងតែមានសន្តិភាព ហើយប្រជាជននៅតំបន់អន្លង់វែងកំពុងតែមានអារម្មណ៍ថាខ្លួនឯងកំពុងតែមានកំហុសតើអ្នកស្រុកអន្លង់វែងគួរតែឆ្លើយតបយ៉ាងដូចម្តេចទៅនឹងជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យនិងបដិវត្តន៍កុម្មុយនីស្តខ្មែរក្រហមដែលខ្លួនធ្លាប់តែគាំទ្រអស់រយៈពេលជាងបីទសវត្សរ៍កន្លងមក តើប្រវត្តិសាស្ត្រខ្មែរក្រហមគួរតែនិយាយនិងបង្រៀនយ៉ាងដូចម្តេចសម្រាប់តំបន់អន្លង់វែង? នេះហើយគឺជាផលលំបាកដែលកំពុងតែប្រឈមមុខទៅនិងបញ្ហាបង្រួបបង្រួមជាតិនៅអន្លង់វែងសព្វថ្ងៃនេះ ។

ក្រោយពីបានជួបប្រាស្រ័យទាក់ទងជាមួយប្រជាជនអន្លង់វែងជាច្រើនរយនាក់ យើងអាចយល់បានថា អ្នកស្រុកអន្លង់វែងមិនមានមោទកភាពនូវអ្វីដែលខ្លួនបានធ្វើក្នុងសម័យខ្មែរក្រហមនោះទេ តែផ្ទុយមកវិញ អ្នកស្រុកអន្លង់វែងបែរជាមានអារម្មណ៍ថាខ្លួនបានសាងកំហុសនិងមានអារម្មណ៍ខ្មាសអៀន ។ អ្នកស្រុកអន្លង់វែងបានបង្ហាញក្តីខកចិត្តនូវអ្វីដែលខ្លួនធ្លាប់ប្តេជ្ញាចិត្តនិងបូជាកម្លាំងកាយចិត្តដែលទីបំផុតទាំងអស់គ្នាមិនបានទទួលផលអ្វីទាំងអស់សម្រាប់ខ្លួនឯង ។ ម្យ៉ាងវិញទៀត អ្នកស្រុកអន្លង់វែងទាំងនោះបានការពារខ្លួនឯងដែលធ្លាប់គាំទ្របដិវត្តន៍ខ្មែរក្រហម ។ អ្នកខ្លះបានចូលជាមួយចលនាខ្មែរក្រហមដោយការបង្ខិតបង្ខំ ចំណែកអ្នកខ្លះទៀតចូលជាមួយចលនាខ្មែរក្រហមដោយស្ម័គ្រចិត្ត តែអ្នកទាំងនោះមិនដឹងថា បដិវត្តន៍ខ្មែរក្រហមនាំខ្លួនទៅរកការកាប់



អេង កុកថាយ (រូបឈរកាន់សៀវភៅ) កំពុងសំណេះសំណាលជាមួយអ្នកភូមិក្នុងពិធីសម្ពោធពាក្យស្លោកនៅវិទ្យាល័យអន្លង់វែង

សម្លាប់នោះទេ ។ សម្រាប់កម្មាភិបាលនិងកងទ័ពខ្មែរក្រហមថ្នាក់ក្រោម គ្មាននរណាម្នាក់ដឹងថានិងមានរឿងអ្វីកើតឡើងទេនៅទីបញ្ចប់នៃបដិវត្តន៍ ។ អតីតកម្មាភិបាលនិងកងទ័ពខ្មែរក្រហមដែលបន្តគាំទ្រខ្មែរក្រហមក្រោយឆ្នាំ១៩៧៩ គឺដោយសារតែអ្នកទាំងនោះគេចពីការវាយប្រហារពីសំណាក់ទាហានវៀតណាម និងបានរត់គេចខ្លួនជាមួយទាហានខ្មែរក្រហមទៅនៅតំបន់ដែលខ្មែរក្រហមបោះទីតាំងនៅក្បែរព្រំដែនកម្ពុជា-ថៃ ។ ទាហានខ្មែរក្រហមខ្លះទៀតចង់ចុះចូលនិងត្រឡប់មករួមរស់ជាមួយរដ្ឋាភិបាលសម្តេច ហ៊ុន សែន វិញដែរ តែមិនហ៊ានសម្រេចចិត្តដោយសារតែបារម្ភពីសុវត្ថិភាពប្រពន្ធកូនរបស់ខ្លួនដែលកំពុងរស់នៅជាមួយខ្មែរក្រហម ។

ក្នុងចំណោមអ្នកស្រុកអន្លង់វែងទាំងអស់ មានមន្ត្រីរដ្ឋាភិបាលចំនួនពីររូបបានផ្តល់គំនិតនិងទស្សនយោបល់ដ៏គួរឲ្យចាប់អារម្មណ៍ទាក់ទងទៅនឹងរបបខ្មែរក្រហម ។ យឹម ផាន់ណា អតីតប្រធានកងពលខ្មែរក្រហមមួយរូបដែលបានផ្តាច់ខ្លួនមករួមរស់ជាមួយរដ្ឋាភិបាលសម្តេច ហ៊ុន សែន ក្នុងឆ្នាំ១៩៩០ ហើយក្រោយមកបានដើរតួនាទីជាអ្នកចរចាដ៏សំខាន់ម្នាក់ជាមួយរដ្ឋាភិបាលសម្តេច ហ៊ុន សែន បាននិយាយថា កាលពីទសវត្សរ៍៩០ មេដឹកនាំនិងកងទ័ពខ្មែរក្រហមខ្លះមានបំណងចង់ចរចានិងស្វែងរកដំណោះស្រាយសន្តិភាពចំពោះសង្គ្រាម ។ កាលនោះ អន្លង់វែងដែលធ្លាប់ជាតំបន់ប្រមូលផ្តុំខ្មែរក្រហមមួយបានជួបរឿងប្រេះឆាគ្នាជាបន្តបន្ទាប់ក្នុងបណ្តាប្រធានកងពលទាំងអស់ ។ ចលនាខ្មែរក្រហមនៅអន្លង់វែងបានបែកខ្ញែកជាពីរក្រុម ។ ក្រុមមួយគឺជាក្រុមរបស់ ប៉ុល ពត និងមេបញ្ជាការកងទ័ពរបស់គាត់ជាច្រើនរូបទៀតដូចជា តាសាន ប្អូន ០៦ និង តាសារឿន ប្អូន ០៥ជាដើម ។ អ្នកដែលនៅខាង ប៉ុល ពត រួមបញ្ចូលទាំង នួន ជា និង ខៀវ សំផន ។ ចំណែកឯមួយក្រុមទៀតគឺក្រុមរបស់ តាម៉ុក, សុន សេន និងអ្នកនៅក្រោមបង្គាប់ផ្សេងទៀត ។ ដោយសារតែរឿងបែកខ្ញែកទាំងនេះហើយដែលបង្កឲ្យមានការប្រយុទ្ធនិងការកាប់សម្លាប់គ្នាឯងកាលពីឆ្នាំ១៩៩៧និង១៩៩៨ ដែលបង្កឲ្យមានការសម្លាប់អតីតរដ្ឋមន្ត្រីការពារជាតិ សុន សេន និងគ្រួសាររបស់គាត់ទាំងមូលដែលមាន



រថយន្តផ្សាយវិទ្យុចល័តដែលជាអំណោយរបស់ប្រទេសចិនជូនចំពោះមេដឹកនាំរបស់ចលនាខ្មែរក្រហមកាលពីទសវត្សរ៍៨០ ។ សព្វថ្ងៃរថយន្តនេះត្រូវបានបោះបង់ចោលនៅក្បែរផ្ទះរបស់ តាម៉ុក នៅតំបន់អន្លង់វែង ។

សមាជិកចំនួន១១នាក់ ដែលការសម្លាប់នោះត្រូវបានជឿថាជាការធ្វើឡើងក្រោមបញ្ជារបស់ ប៉ុល ពត ។ ចៅស្រីម្នាក់របស់ សុន សេន ត្រូវបានវាយដំនិងរំលោភមុននឹងសម្លាប់ចោល ។ ការសម្លាប់ សុន សេន នាំទៅរកការចាប់ខ្លួន ប៉ុល ពត និងនាំទៅរកការជំនុំជម្រះទោសចំពោះមេដឹកនាំរូបនេះនាដើមឆ្នាំ១៩៩៨ ។ តាម៉ុក បានបញ្ជាឲ្យមានការជំនុំជម្រះទោស ប៉ុល ពត បន្ទាប់ពីរូបថតរបស់សាកសព សុន សេន និងសាច់ញាតិរបស់គាត់ត្រូវបានចែកចាយទៅឲ្យអ្នកស្រុកអន្លង់វែងបានដឹង ។

យឹម ដាន់ណា បានបន្តទៀតថា មេបញ្ជាការកងពលជាច្រើនរូបស្ទះស្វែងរកដំណោះស្រាយចំពោះសង្គ្រាម ជាពិសេសចំពោះស្ថានភាពដែលមេបញ្ជាការទាំងនោះកំពុងជួបប្រទះ ។ មេបញ្ជាការខ្មែរក្រហមមិនចង់សម្លាប់គ្នាទៀតទេ ហើយក៏មិនចង់ច្បាំងជាមួយរាជរដ្ឋាភិបាលកម្ពុជាតទៅទៀតដែរព្រោះដោយសារតែការដួលរលំនៃកុម្មុយនីស្តលើសកលលោក ការបន្តច្បាំងទៅទៀត គឺជារឿងឥតប្រយោជន៍ ។ មេបញ្ជាការខ្មែរក្រហមចង់កសាងមូលដ្ឋានដ៏សមរម្យមួយសម្រាប់សន្តិភាពទៅថ្ងៃអនាគតដោយមិនចូលរួមពាក់ព័ន្ធជាមួយជម្លោះប្រដាប់អាវុធដែលនាំទៅរកការស្លាប់និងបន្សល់នូវភាពពិការរូបរាងកាយទៀតទេ ។ ដោយសារតែការព្យាយាមក្នុងការចរចាជាមួយរដ្ឋាភិបាល ហ៊ុន សែន កាលពីដំណាក់កាលដំបូង យឹម ដាន់ណា ត្រូវបានផ្តល់ការសរសើរក្នុងការស្វែងរកសន្តិភាពនិងភាពសុខសាន្តនៅតំបន់អន្លង់វែងនាពេលនេះ ។ អតីតប្រធានកងពលរូបនេះគាំទ្រយ៉ាងខ្លាំងចំពោះកិច្ចការស្រាវជ្រាវនិងការចងក្រងឯកសារនៃប្រវត្តិអន្លង់វែង ជាពិសេស ប្រវត្តិតំបន់អន្លង់វែងនាដំណាក់កាលចុងក្រោយនៃចលនាខ្មែរក្រហមរួមទាំងការជំទាស់របស់គាត់ជាមួយអតីតកម្មាភិបាលនិងមិត្តភក្តិដែលជាខ្មែរក្រហមដូចគ្នា ។ យឹម ដាន់ណា ពេញចិត្តនឹងគោលនយោបាយបង្រួបបង្រួមជាតិដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រើដើម្បីបញ្ចុះបញ្ចូលកម្មាភិបាលខ្មែរក្រហមនិងក្រុមគ្រួសារដើម្បីផ្តាច់ខ្លួននិងធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជា ។

ក្នុងនាមជាមន្ត្រីរដ្ឋាភិបាលម្នាក់ដែលបានបាត់បង់សាច់ញាតិអស់ជាច្រើនក្រោមរបបខ្មែរក្រហម លោកជំទាវ ទន់ សាអ៊ីម បានបង្ហាញនូវទស្សនបង្រួបបង្រួមប្រកបដោយការថ្លឹងថ្លែងខ្ពស់នូវអ្វីដែលបានកើតឡើងកាលពីរបបកម្ពុជាប្រជាធិបតេយ្យនៅពេលដែលគាត់មានប្រសាសន៍ទៅកាន់ប្រជាជនអន្លង់វែងក្នុងអំឡុងពិធីសម្ពោធពាក្យស្លោកប្រឆាំងនិងអំពើប្រល័យពូជសាសន៍នៅវិទ្យាល័យអន្លង់វែងកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ដែលរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅពេលដែល



អគារនេះសាងសង់ឡើងដោយ តាម៉ុក ដើម្បីប្រើប្រាស់ជាទីបញ្ជាការរបស់អ៊ុនគាត់កាលពីដើមទសវត្សរ៍៩០ ។ តែដោយសារភាពមិនចុះសម្រុងគ្នារវាងខ្មែរក្រហមនិងអ៊ុនគាត់ អាគារនេះត្រូវបានប្រើប្រាស់ជាជង្រុកស្រូវវិញ ។ សព្វថ្ងៃ អាគារនេះគឺជាអាគារមួយរបស់វិទ្យាល័យអន្លង់វែង ។

គាត់កំពុងនិយាយទៅកាន់ប្រជាជនស្រុកអន្លង់វែង នៅពីក្រោយលោកជំទាវគឺជាអគារមួយមានកម្ពស់បីជាន់ដែលសាងសង់ឡើងដោយ តាម៉ុក ក្នុងឆ្នាំ១៩៩៣ ។ លោកជំទាវបានមានប្រសាសន៍ថា ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ លោកជំទាវនិងប្រជាជនកម្ពុជាទាំងឡាយនាំគ្នាធ្វើការយ៉ាងលំបាកលំបិនដើម្បីកសាងជីវិតថ្មីឡើងវិញនិងដើម្បីឲ្យទាំងអស់គ្នាមានថ្ងៃនេះ ។ លោកជំទាវមិនបានរៀបរាប់ដោយត្រង់ៗពីអំពើប្រល័យពូជសាសន៍ពីឆ្នាំ១៩៧៥ដល់១៩៧៩ទេ តែលោកជំទាវបានធ្វើការបន្ទោសជម្លោះដែលបានកើតឡើងនៅកម្ពុជានោះដោយសារតែការដណ្តើមអំណាចគ្នាផ្នែកមនោគមវិជ្ជាសាកលលោកដែលរីករាលដាលមកដល់ប្រទេសកម្ពុជាតាមរយៈសង្គ្រាមឥណ្ឌូចិនលើកទីពីរ ។ ដោយសារតែសង្គ្រាមកើតឡើងនៅកៀកនឹងប្រទេសកម្ពុជាបែបនេះ ការជ្រៀតចូលរបស់កងទ័ពវៀតណាមខាងជើងមកក្នុងទឹកដីកម្ពុជាគឺជារឿងជៀសមិនផុត ហើយមូលហេតុនេះហើយដែលបង្ខំចិត្តឲ្យទាហានវៀតណាមខាងត្បូងនិងកងទ័ពអាមេរិកចូលមកទឹកដីកម្ពុជាដើម្បីតតាំងជាមួយនឹងកងទ័ពវៀតណាមខាងជើង ។ លទ្ធផលនៃការប្រយុទ្ធគ្នានៅលើទឹកដីកម្ពុជាធ្វើឲ្យមានការបំផ្លិចបំផ្លាញដល់ផលិតផលកសិកម្មជាច្រើននិងធ្វើឲ្យមានអស្ថេរភាពផ្នែកនយោបាយផ្ទៃក្នុងប្រទេស ហើយធ្វើឲ្យកម្លាំងកុម្មុយនីស្តកាន់តែមានសភាពខ្លាំងក្លាដែរ ដែលក្រោយមកចលនាកុម្មុយនីស្តនោះក្លាយជា “ខ្មែរក្រហម” ។ ជាមួយគ្នានោះដែរកម្ពុជាខ្លួនឯងផ្ទាល់ក៏រួមចំណែកនាំប្រទេសជាតិឲ្យធ្លាក់ចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមដែរដោយសារតែរដ្ឋប្រហារយោធារបស់ លន់ នល់ ។ លោកជំទាវមិនបានប្រើពាក្យអំពើប្រល័យពូជសាសន៍និងការកាប់សម្លាប់ទេ ពេលដែលកំពុងថ្លែងទៅកាន់អ្នកស្រុកនិងសិស្សានុសិស្សអន្លង់វែងប្រមាណជាង ៦០០នាក់ ។ ក្នុងនាមជាមន្ត្រីម្នាក់របស់ក្រសួងអប់រំ លោកជំទាវ ទន់ សាអ៊ីម បានចូលរួមកិច្ចការជាមួយគម្រោងអប់រំអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយ ជាពិសេសកិច្ចការចូលរួមក្នុងនិងកម្មវិធីសម្ពោធពាក្យស្លោកនៅវិទ្យាល័យមួយចំនួនទូទាំងប្រទេស ។ លោកជំទាវគឺជាអតីតគ្រូអក្សរសាស្ត្រអស់រយៈពេលជាងសាមសិបឆ្នាំ ។ ហើយលោកជំទាវមានជំនាញក្នុងការថ្លែងប្រកបដោយគុណភាពទៀតផង ។

លោកជំទាវ ទន់ សាអ៊ីម បានបន្ថែមទៀតថា ព្រឹត្តិការណ៍ដែលកើតឡើងនៅកម្ពុជានាដើមសតវត្សរ៍ទី២០នេះដូចជាក្រុមឥស្សរៈប្រឆាំងរបបអាណានិគមបារាំង ក្រុមកុម្មុយនីស្តនិងមេដឹកនាំកាលជំនាន់នោះសុទ្ធតែជាអ្នកស្នេហាជាតិ ។ អ្នកទាំងនោះស្រឡាញ់ប្រទេសជាតិនិងប្រជាជនរបស់ខ្លួនដូចគ្នា ។ បញ្ហាត្រង់ថាអ្នកទាំងនោះបានយល់ឃើញពីដំណោះស្រាយផ្សេងៗពីគ្នាដើម្បីដោះស្រាយបញ្ហាសង្គមនិងនយោបាយនៅក្នុងប្រទេស ។ ត្រង់ចំណុចនេះ លោកជំទាវ ទន់ សាអ៊ីម បានថ្លែងក្នុងលក្ខណៈទន់ភ្លន់ថាខ្មែរក្រហមគឺជាក្រុមដែលមិនគិតពីប្រយោជន៍ខ្លួនឯងទាល់តែសោះនិងមានការប្តេជ្ញាចិត្តខ្ពស់ ។ ខ្មែរក្រហមមិនបានលួចប្លន់កុហកនិងមិនបានប្រមែប្រមូលកេតនភ័ណ្ឌទ្រព្យសម្បត្តិដើម្បីយកមកទុកផ្ទាល់ខ្លួនទេ ។ ខ្មែរក្រហមបន្តមានគំនិតបែបនេះរហូតពេញមួយចលនាតស៊ូរបស់ខ្លួន ។ លោកជំទាវមិនបាននិយាយឲ្យចំចំណុចដែលថាមេដឹកនាំខ្មែរក្រហមខ្លះដែលគ្មានចិត្តមេត្តាធម៌និងជាពេជ្ឈឃាតដែលបានសម្លាប់កម្មាភិបាលខ្លួនឯងនិងប្រជាជននៅក្រោមការគ្រប់គ្រងរបស់ខ្លួនទេ ។ កម្មាភិបាលខ្មែរក្រហមទាំងនោះត្រូវបានមើលឃើញថាមិនទុកចិត្តនិងខ្វះភាពស្មោះត្រង់ចំពោះបក្ស ។ លោកជំទាវបាននិយាយដោយច្បាស់ៗថា ដំណោះស្រាយផ្សេងគ្នារបស់ថ្នាក់ដឹកនាំនីមួយៗនាំឲ្យប្រទេសជាតិធ្លាក់ទៅក្នុងសង្គ្រាម ។ លោកជំទាវបានបន្ថែមទៀតថា ក្រោយរបបខ្មែរក្រហម នរណាក៏ជាជនរងគ្រោះដែរ ទោះបីជាអ្នកនោះជាកម្មាភិបាលខ្មែរក្រហមក្តីឬជាប្រជាជនធម្មតាក្តីពីព្រោះបទបញ្ជាដែលចេញពីថ្នាក់លើគឺជាបទបញ្ជាមរណៈ ។ ពេលនេះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមកំពុងត្រូវបានកាត់ទោសដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយសារតែតែថ្នាក់ដឹកនាំជាន់ខ្ពស់នោះប៉ុណ្ណោះដែលជាបុគ្គលដែលទទួលខុសត្រូវមិនមែនប្រជាជនធម្មតាដែលលោកជំទាវកំពុងនិយាយទៅកាន់ពេលនេះទេ ហើយប្រជាជនធម្មតាទាំងនេះកំពុងតែចង់រស់នៅដោយសន្តិភាពក្រោយសង្គ្រាម ។ អ្នកស្រុកអន្លង់វែងមិនគួរខ្លាចនិងនិយាយជាមួយប្រជាជនខ្មែរទូទៅនៅខាងក្នុងទេ (ប្រជាជនអន្លង់វែងត្រូវបានចាត់ទុកថាជាអ្នកក្រៅ) ។

លោកជំទាវបានបន្ថែមថា អតីតកម្មាភិបាលខ្មែរក្រហម

គួរតែមានអារម្មណ៍ថា ខ្លួនជាអ្នកឈ្នះដែលបានផ្តាច់ខ្លួន និងមករួមរស់ជាមួយសង្គមជាតិវិញ ។ ប្រជាជនកម្ពុជាទាំងអស់គួរតែគិតថាប្រជាជនអន្លង់វែងគឺជាអ្នកឈ្នះពីព្រោះអ្នកទាំងនោះអាចទទួលបាននូវសុខសន្តិភាពចុងក្រោយបន្ទាប់ពីជម្លោះអស់រយៈពេលជាងសាមសិបឆ្នាំក្រោយពីជួបប្រទះនូវការប្រយុទ្ធគ្នាយ៉ាងព្រៃផ្សៃនិងអូសបន្លាយយ៉ាងយូរ ។ យើងទាំងអស់គ្នាដើរចេញពីសង្គ្រាមប្រកបដោយភាពថ្លៃថ្នូរនិងភាពក្លាហានដើម្បីសម្លឹងរកគ្នានិងនិយាយទល់មុខគ្នាដូចអ្វីដែលលោកជំទាវកំពុងតែនិយាយទៅកាន់អ្នកស្រុកអន្លង់វែងនៅពេលនេះដែរ ។

លោកជំទាវបានដកស្រង់ទស្សនរបស់ព្រះពុទ្ធស្តីអំពីការអត់ឱននិងការបង្រួបបង្រួមដែលមាននៅក្នុងរឿងអង្គុលីមា ។ នៅក្នុងរឿងនោះអង្គុលីមាបានព្យាយាមសម្លាប់និងកាត់ម្រាមដៃមនុស្សជាច្រើននាក់ដើម្បីឲ្យខ្លួនមានបារមីខ្លាំងក្លានិងមានជីវិតអមតៈ ។ មនុស្សគ្រប់គ្នាមើលឃើញអង្គុលីមាថាជាមនុស្សអាក្រក់មានការស្អប់និងចង់សងសឹក ។ អង្គុលីមាក៏មានអារម្មណ៍ស្តាយក្រោយនូវអ្វីដែលខ្លួនបានប្រព្រឹត្តដែរ ។ ព្រះពុទ្ធអង្គបានត្រាស់យល់ពីភាពល្អនៅក្នុងចិត្តរបស់អង្គុលីមាដោយព្រះអង្គបានពន្យល់និងណែនាំគាត់ឲ្យក្លាយជាមនុស្សល្អវិញ ។ ព្រះពុទ្ធអង្គកែតម្រង់ជីវិតមនុស្សអាក្រក់ដូចជាអង្គុលីមានេះ និងអត់ឱនទោសឲ្យគាត់ ដរាបណាអង្គុលីមាដឹងពីកំហុសនិងស្តាយក្រោយ ។ លោកជំទាវក៏បានបន្តទៀតថា នៅពេលដែលប្រជាជនកម្ពុជាប្រណិបត្តិសាសនាហិណ្ឌូ អ្នកដែលគោរពព្រះសិវៈដែលជាព្រះបង្កើតលោកនិងអ្នកគោរពព្រះវិស្ណុដែលជាព្រះការពារលោក មិនប្រណិប័តន៍ជាមួយគ្នាទេ ។ ហេតុដូច្នេះហើយបានជាមានការបង្កើតព្រះមួយដែលមានព្រះភ័ក្ត្រពីរ ។ មួយគឺជាព្រះភ័ក្ត្ររបស់សិវៈនិងមួយទៀតគឺជាព្រះភ័ក្ត្ររបស់ព្រះវិស្ណុ ។ ការលើកយកចំណុចនេះមកនិយាយគឺជាបំណិនដ៏ប៉ិនប្រសប់មួយរបស់លោកជំទាវដើម្បីឲ្យស័ក្តិសមទៅនឹងកាលៈទេសៈនៃការផ្សះផ្សាជាតិនៅពេលនេះ ។ **អេង កុកថាយ**



ពីឆ្វេងទៅស្តាំ អ៊ឹម ចែម, លោកជំទាវ ទន់ សាអ៊ីម និងលោក យឹម ផាន់ណា (អភិបាលស្រុកអន្លង់វែង) កំពុងចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងទស្សនាវដ្តីស្វែងរកការពិតដល់សិស្សានុសិស្សនិងអ្នកស្រុកអន្លង់វែងប្រមាណជា៦០០នាក់កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ។

# ចម្លើយសារភាពរបស់ ខែក ប៊ិន ហៅ ស៊ូ គណៈទាក់ទងកម្ពុជា-ថៃ

## ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ J00៣៥៣

ខែក ប៊ិន ហៅ ស៊ូ មានស្រុកកំណើតនៅភូមិអំពិល ឃុំសំរោងយា ស្រុកពួក ខេត្តសៀមរាប ។ ប៊ិន ហៅ ស៊ូ បានចូលចលនា សេ.អ៊ី.អា តាមការដឹកនាំរបស់ ទីវ អុល និង ម៉ៃ លន់ ក្នុងឆ្នាំ១៩៦៣ ដើម្បីកសាងកម្លាំងក្នុងស្រទាប់សិស្សនិងគ្រូ ។ ក្នុងអំឡុងពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៤ ស៊ូ ធ្វើការក្នុងជួរបដិវត្តន៍ ហើយកសាងកម្លាំងប្រឆាំងបដិវត្តន៍ដោយឲ្យប្រជាជនថ្នាំងថ្នាក់នឹងការដឹកនាំរបស់បដិវត្តន៍ បើកផ្លូវឲ្យខ្មាំងធ្វើសេដ្ឋកិច្ចក្នុងដីរំដោះនិងគាំទ្រកម្លាំងទ័ព លន់ នល់ ។ ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ស៊ូ បានផ្លាស់មកកាន់ពាណិជ្ជកម្មរដ្ឋ ហើយធ្វើការទំនាក់ទំនងជាមួយថៃ ពីសកម្មភាព សេ.អ៊ី.អា អាមេរិក រហូតត្រូវអង្គការចាប់ខ្លួនបាន ។ យោងទៅតាមចម្លើយសារភាពដែលមានចំនួន៦៥ទំព័រដែលធ្វើឡើងនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៧ ស៊ូ បានរៀបរាប់ពីប្រវត្តិនិងសកម្មភាពរបស់ក្រុមខ្លួនដែលមានឈ្មោះអ្នកជាប់ពាក់ព័ន្ធចំនួន ៧៧នាក់ ។ ស៊ូ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ ខែក ប៊ិន ហៅ ស៊ូ ។

កាលពីក្មេង ស៊ូ បានចូលរៀននៅវត្តតាទេក ស្ថិតនៅស្រុកពួក ខេត្តសៀមរាប ។ នៅឆ្នាំ១៩៤៥ ស៊ូ ចូលរៀនថ្នាក់បឋម ។ ប្រាំឆ្នាំបន្ទាប់ ក្រោយពីបានបញ្ចប់ថ្នាក់បឋមសិក្សា ស៊ូ ក៏បានប្រឡងចូលសាលាមធ្យមសិក្សានៅខេត្តបាត់ដំបងវិញ ។

ឆ្នាំ១៩៥៣ ស៊ូ បានប្រឡងចូលសាលាគរុកោសល្យ នៅពេលរៀននោះគឺមាន ទីវ អុល, កុយធួន, កែ គីមហួត, លាង ហាប់អាន រៀនឆ្នាំជាមួយគ្នា ដោយមានគ្រូបង្រៀនឈ្មោះ អ៊ុច វ៉ែន ។ ក្នុងឆ្នាំ១៩៥៩ ស៊ូ បានចេញធ្វើគ្រូបង្រៀននៅខេត្តសៀមរាប ។ មួយឆ្នាំក្រោយមក ស៊ូ ក៏បានផ្លាស់ការងារមកធ្វើជាគ្រូបង្ហាត់កីឡានៅវិទ្យាល័យស៊ីសុវត្ថិនៅភ្នំពេញដោយមានចាងហ្វាងសាលាឈ្មោះ ឌួង សារិន និង ខៀវ កុមារ ជាចាងហ្វាងរង ។

ឆ្នាំ១៩៦០ ស៊ូ បានប្រឡងចូលជានិស្សិតសាស្ត្រាចារ្យ ហើយក៏បានជួប ទីវ អុល, កុយ ធួន, កែ គីមហួត និង លាង ហាប់អាន ។ ពេលនោះ ទីវ អុល និង កុយ ធួន បានចេញធ្វើជាសាស្ត្រាចារ្យ ហើយចំណែក ស៊ូ និង កែ គីមហួត ជានិស្សិតសាស្ត្រាចារ្យជាមួយគ្នា ។ ថ្ងៃមួយ កុយ ធួន បានហៅ ស៊ូ ទៅជួបនាផ្ទះ ។ ពេលមកដល់ផ្ទះ កុយ ធួន លើកពីរបបសក្តិភូមិដែលហួសសម័យដែលត្រូវការផ្លាស់ប្រែ ស៊ូ ក៏បានបង្ហាញពីយោបល់ដូច កុយ ធួន ដែរ ។ នៅបន្ទាប់ពីនោះគឺ ទីវ អុល ក៏បាន



កុយ ធួន

ផ្តាំតាមឈ្មោះ យី យ៉ុន ឲ្យ ស៊ូ មកជួប ។ ការជួបនោះ ទីវ អុល ក៏បានទទួល ស៊ូ ដោយមានការរាក់ទាក់ជាមួយគ្នា ព្រមទាំងបានបង្ហាញឲ្យឃើញពីរបបសក្តិភូមិដែលត្រូវរំលំ ហើយនិងត្រូវផ្លាស់របបថ្មី ។

នៅឆ្នាំ១៩៦២ ស៊ូ ត្រូវបាន ទីវ អុល អប់រំនិងណែនាំឃោសនាឲ្យយល់ដឹងពីរឿងបដិវត្តន៍ដោយបានបំផុសបំផុលថាការធ្វើបដិវត្តន៍មានការសប្បាយ នៅទីក្រុងនឹងមានចលនាគគ្រឹកគគ្រេង ។ នៅក្នុងឆ្នាំ១៩៦៣ ស៊ូ បានចូលបដិវត្តន៍តាមការដឹកនាំរបស់ ទីវ អុល រួមមាន ឈ្មោះ កែ សុខន, ម៉ៃ លន់, យី យ៉ុន, កែ គីមហួត ។ ក្រោយមក ស៊ូ ក៏បានស្គាល់ម្នាក់ទៀតឈ្មោះ ហេង ហ៊ី (អតីតមិត្តចាស់រៀនជាមួយគ្នា) ។ បន្ទាប់ពីបានជួបគ្នា ហេង ហ៊ី បានបបួល ស៊ូ ឲ្យទៅធ្វើការងារនៅទូតអាមេរិក ប៉ុន្តែដោយសារ ស៊ូ មិនសូវចេះភាសាអង់គ្លេស ហើយមានការងារជាសាស្ត្រាចារ្យនិងមានប្រាក់ខែគួរសមផង ជាពិសេសមានមិត្តភក្តិដែលរួមការងារនៅផ្នែកនេះហើយ ស៊ូ មិនបានទៅតាមការទាក់ទងរបស់ ហេង ហ៊ី ទេ ។

## សកម្មភាពដំបូងក្នុងការបំផ្លាញបដិវត្តន៍

សកម្មភាពរបស់ ស៊ូ ចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ១៩៦៣ នេះជាសកម្មភាពដែលធ្វើបដិវត្តន៍តែរូបភាព ប៉ុន្តែខ្លឹមសារគឺប្រឆាំងបដិវត្តន៍ ។ ស៊ូ បានរៀបចំសកម្មភាពផែនការប្រឆាំងបដិវត្តន៍ ដោយបានបំផុសបំផុលក្នុងមជ្ឈដ្ឋានសាស្ត្រាចារ្យ និងមជ្ឈដ្ឋានគ្រូបង្រៀនឲ្យគិតគូរតែប្រាក់ខែ ពីសញ្ញាបត្រ ផែនការគ្រួសារ មុខមាត់ បុណ្យសក្តិធ្វើយ៉ាងណាដើម្បីផ្តួលគោលជំហររបស់គ្រូមជ្ឈដ្ឋានសិក្សាគឺឲ្យសប្បាយឈ្លក់វង្វេងជាមួយសញ្ញាបត្រ ។ ចំណែកឯសិស្ស និងយុវជនវិញ ស៊ូ បញ្ចុះបញ្ចូលឲ្យនិស្សិតទាំងអស់ឈ្លក់វង្វេងនឹងការសប្បាយ ដោយបបួលគ្នាជួលឡានដើម្បីដើរលេងកំសាន្តនៅខាងទន្លេបាទីនិងទាក់ចិត្តតែរឿងសប្បាយៗ នៅតាមទីក្រុងមិនគិតគូរដល់ការងារដែលត្រូវចេញទៅជនបទដើម្បីធ្វើការតស៊ូ ។

នៅក្នុងឆ្នាំ១៩៦៤ ស៊ូ បានរួមសកម្មភាពជាមួយឈ្មោះ ហូ គិមអេង តាមការណែនាំពី ទីវ អុល ថាជាខ្សែរបស់ ម៉ៃ លន់ នៅសមាគមគ្រូបង្រៀន និង ហូ គិមអេង ជាប្រជាចលនា និងជាភ្នាក់ងារ សេ.អ៊ី.អា ។ បន្ទាប់មក គិមអេង ក៏បានរួមសកម្មភាពខាងវាយគោលជំហរនៅខាងមជ្ឈដ្ឋានសិក្សាកុំឲ្យងាកទៅរកបដិវត្តន៍ ។ ស៊ូ ត្រូវបាន ទីវ អុល ណែនាំឲ្យចូលធ្វើជា សេ.អ៊ី.អា កន្លែងដែលបញ្ចូលគឺនៅទីចាត់ការសមាគមសាស្ត្រាចារ្យ អ្នកដែលទទួលស្គាល់ ស៊ូ នៅពេលនោះមាន កែ សុខន និង ម៉ៃ លន់ និងអ្នកដែលចូលជាមួយ ស៊ូ មានឈ្មោះ យីយ៉ុន និងកែគិមហួត ។ នៅឆ្នាំដដែល ស៊ូ បានបង្ហាត់កីឡានៅវិទ្យាល័យយុគន្ធរ ស៊ូ បានទាក់ទងជាមួយយុវជន ពីរនាក់ឈ្មោះ សុត ហៅ សៀន និង ឡាយ ឡេងហួ ហៅ ប៊ូញ៉ា ។ សៀន ចេញទៅខាងជនបទភាគពាយ័ព្យ ចំណែក ប៊ូញ៉ា វិញចេញទៅខាងនិរតី ។ មិនយូរប៉ុន្មាន អ្នកទាំងពីរត្រូវបាន ស៊ូ បញ្ចុះបញ្ចូលឲ្យចូលជា សេ.អ៊ី.អា ។

ឆ្នាំ១៩៦៥ ស៊ូ បានផ្លាស់ទៅខេត្តព្រៃវែង ។ នៅទីនោះ ទីវ អុល បានខទ្មេសនាមឲ្យ ស៊ូ ទាក់ទង កែ សាខន ជាចាងហ្វាងសាលាអង្គឌួងនៅព្រៃវែង ។ ក្រោយមក ស៊ូ និង កែ សាខន បានរៀបចំសកម្មភាពប្រឆាំងបដិវត្តន៍ដើម្បីកុំឲ្យយុវជនយល់ដឹងអំពីរដ្ឋអំណាចដែលត្រូវតស៊ូវណ្ណៈនិងឲ្យយុវជនមាននាំគ្នាសប្បាយរីករាយអ៊ូអរគគ្រឹកគគ្រេងដូចជាពេលនៅក្នុងបុណ្យបំណាច់ឆ្នាំដោយមានចែករង្វាន់ទៅដល់សិស្សទៀតផង ។ ក្នុងការងារនេះ ស៊ូ បានកសាងកម្លាំងពីរនៅព្រៃវែង កម្លាំងទីមួយគឺឈ្មោះ ហែម យ៉ន ហៅ សែម នៅភូមិភាគឧត្តរ និងកម្លាំងទីពីរឈ្មោះ ហម ចេញទៅព្រៃខាងពាយ័ព្យ ។ មួយរយៈក្រោយមក ទីវ អុល បានឲ្យ ស៊ូ ផ្លាស់ចេញពីព្រៃវែងទៅកាន់ខេត្តកំពង់ស្ពឺដោយណែនាំឲ្យទាក់ទងជាមួយឈ្មោះ យីយ៉ុន ដើម្បីធ្វើសកម្មភាពក្បត់ ។ នៅកំពង់ស្ពឺ ស៊ូ និង យី យ៉ុន បានអនុវត្តន៍សកម្មភាពក្បត់បដិវត្តន៍ដោយបានអូសទាញយុវជនឲ្យស្រឡាញ់រាប់អានក្រុមខ្លួននិងបោកប្រាសឲ្យធ្វើបដិវត្តន៍តែរូបភាព តែខ្លឹមសារគឺប្រឆាំងនិងបដិវត្តន៍ ។ ក្រោយមក យី យ៉ុន និង ស៊ូ បានកសាងយុវជននៅវិទ្យាល័យសុទ្ធិភាពបានបីនាក់មានឈ្មោះ ឈួ សារ៉េត ហៅ ប៉ាង, ខៀវ វ៉ាន់ហន, និង សេន ។ អ្នកទាំងបីនាក់នេះត្រូវបានស៊ូអូសទាញតាមការទាក់ទងខាងមនោសញ្ចេតនានិងឧបត្ថម្ភជាលុយកាក់ដើម្បីទិញសម្ភារៀនសូត្រ ។ ក្រោយមកអ្នកទាំងបីត្រូវបាន ស៊ូ ឲ្យចូលជា សេ.អ៊ី. អា ដោយមាន ទីវ អុល ជាអ្នកគ្រប់គ្រង ។ មិនយូរប៉ុន្មាន ស៊ូ ក៏បានផ្លាស់ចេញពីកំពង់ស្ពឺដោយប្រគល់ភារកិច្ចឲ្យ យី យ៉ុន គ្រប់គ្រងអ្នកទាំងបីនេះ និងបន្តអប់រំកសាងកម្លាំងបន្ថែមទៀត ។

នៅឆ្នាំ១៩៦៧ ស៊ូ បានផ្លាស់ពីកំពង់ស្ពឺមកភ្នំពេញមក

បង្ហាត់នៅសាលាឥន្ទ្រទេវីនៅម្ដុំទួលគោក ។ នៅទីនោះ ស៊ូ បានជួប ទីវ អុល, កង សារ៉ែន, និង ចាន់ សសេរី ហើយបានរួមធ្វើសកម្មភាពដើម្បីក្ដាប់ចលនារបស់យុវជនគឺមិនឲ្យយុវជនទៅព្រៃហើយ បង្កើតភាពសប្បាយរីករាយនៅក្នុងក្រុមដូចជាការមើលសិល្បៈជាដើម ។

ចុងឆ្នាំ១៩៦៧ ទីវ អុល បានណែនាំឲ្យ ស៊ូ ចេញទៅព្រៃ និងប្រាប់អំពីសភាពការណ៍ដែលមានការប្រែប្រួលជាពិសេសមានកម្មាភិបាលចេញទៅជនបទច្រើន ដូច្នេះត្រូវបង្កប់ខ្លួនធ្វើជាអ្នកបដិវត្តន៍ស៊ីរូងផ្ទៃក្នុងបដិវត្តន៍ ។ នៅពេលនេះ ទីវ អុល បានខទ្ទេសនាមអ្នកដឹកនាំថ្មីឈ្មោះ ថន និងក្រុមថ្មីដែលមានឈ្មោះ ជា ហួន ហៅ វ៉ាញ, ម៉ែនដុន ហៅ ហឹង និង សុន ហៅ សៀន ដោយមានសម្គាល់សញ្ញាទាក់ទងគ្នាគឺ០០១ហើយសួរនិងឆ្លើយដោយសម្គាល់សញ្ញា០០៣ ។ នៅពេលដែលណាត់ជួបគ្នា ស៊ូ បានទៅកន្លែងណាត់ឃើញឈ្មោះ គិន ហៅ គុន មកទទួល ។ គិន បាននាំ ស៊ូ ទៅប្រគល់ឲ្យនិរសារមកពីពាយ័ព្យឈ្មោះ ដូ ។ អ្នកទាំងពីរបានធ្វើដំណើរតាមឡានទៅខាងពាយ័ព្យ ។ ទៅដល់ពាយ័ព្យនៅពេលថ្ងៃ ស៊ូ មកដល់ជួប សាវិន និង សាន នៅភូមិកំហត ។ ក្រោយមក ស៊ូ និង សាន បានបន្តដំណើរទៅដល់ភ្នំវាយចាប រួចក៏បានជួបជាមួយ ថន ។ បន្ទាប់មក ស៊ូ បន្តដំណើរពីភ្នំវាយចាបទៅខាងភ្នំសំឡូតជាមួយ សាន ដោយចំណាយរយៈពេលមួយអាទិត្យបានមកដល់កន្លែងអង្គការបដិវត្តន៍ដោយមានការទទួលអ្នកទាំងពីរដោយរាក់ទាក់ ។

នៅក្នុងឆ្នាំ១៩៦៨ អង្គការខាងភូមិភាគបើកវគ្គរៀនសូត្រ ។ ពេលនោះមានការជួបជុំក្រុមរបស់ ស៊ូ ព្រោះក្រុម ស៊ូ ត្រូវមករៀនទាំងអស់គ្នាដោយមាន សាយ, វ៉ាញ, ស៊ូ និង ហឹង ។ ការជួបជុំគ្នានេះដើម្បីសាកសួរអំពីសកម្មភាពដែលបានអនុវត្តនៅកន្លែងរៀងៗខ្លួន ។ ពេលនោះ សាន បាននិយាយអំពីការដែលមិនវាយសម្រុកទៅលើខ្មាំងគឺបំផុសនូវសតិអារម្មណ៍ ហើយនៅសម្ងំរកស្បៀង សម្ងំរករស់គឺថាមិនវាយសម្រុកទៅលើខ្មាំង ។ ចំណែកខាងមិត្ត ស៊ាន បានបំផុសអំពីសាមគ្គីភាព ពិសេសគឺបំផុសបំផុលអំពីទំនាស់រវាងអ្នកទៅពីក្រុងនិងខាងតំណាងអង្គការភូមិភាគដោយវាយប្រហារថា ចង្អៀតចង្អល់ ចំពោះអ្នកមកពីទីក្រុង ។ ចំពោះ វ៉ាញ បានបង្កើតទំនាស់រវាងកម្មាភិបាលកសិករនៅជនបទ និងកម្មាភិបាលដែលចេញពីក្រុង ។ បន្ទាប់ពីជួបគ្នាហើយ សាយ បានណែនាំក្រុមសមាជិកទាំងអស់បំពេញភារកិច្ច សេ.អ៊ី.អា ដែលបានប្រគល់ភារកិច្ចឲ្យបង្កប់ខ្លួនឲ្យជ្រៅនៅក្នុងជួរបដិវត្តន៍និងប្រឆាំងបដិវត្តន៍ ។ ដោយស្ថិតនៅក្រោមការដឹកនាំរបស់ សាយ ផ្ទាល់ ស៊ូ និង វ៉ាញ បានរៀបចំដឹកនាំក្រុមឈ្លបមួយក្រុមធ្វើក្លូចហូបដោយមិនឲ្យគិតគូរវាយខ្មាំងគិតគូរយ៉ាងម៉េចធ្វើក្លូចឲ្យហូបឲ្យតែរស់ ចំណែកសម្ភារវាយខ្មាំងគឺគ្មាននឹកនាគ្មានបានលើកឡើងទេ គឺមួយថ្ងៃៗ គិតគូរតែរឿងធ្វើក្លូចតែប៉ុណ្ណោះ ។ ចំពោះ វ៉ាញ និង ស៊ូ វិញ ក្រៅពីធ្វើក្លូចគឺបានសរសេរសំបុត្រមួយច្បាប់ជាអត្ថបទព្រឹត្តិបត្រដែលការអត្ថាធិប្បាយរបស់ព្រឹត្តិបត្រនេះគឺមាននិយាយអំពីរឿងបដិវត្តន៍តែសំបកក្រៅទេ ឯខ្លឹមសារប្រឆាំងបដិវត្តន៍គឺគ្មាននិយាយអំពីការវាយសម្រុកខ្មាំង បញ្ហាប្រយុទ្ធតស៊ូវណ្ណៈ បញ្ហារដ្ឋអំណាច កម្មករ កសិករ គឺមិនមាននិយាយទេ គឺនិយាយតែបញ្ហាទូទៅ ។ លើសពីនេះទៅទៀត សាយ បានដឹកនាំចែកទៅតាមក្រុមមុខសញ្ញាផ្សេងៗគ្នាគឺមានមុខសញ្ញាខាងស្រុកគាស់ក្រឡ មុខសញ្ញាខាងស្រុកមោង មុខសញ្ញានៅពោធិ៍សាត់ ហើយមុខសញ្ញាខាងពោធិ៍សាត់មានក្រុមឈ្លបបួនក្រុម ។ ស៊ូ បានចុះជាមួយក្រុមឈ្លបជាមួយ សាយ ដោយមានភារកិច្ចជាអ្នកឃោសនា ។ ក្រោយមក សាយ រួមជាមួយក្រុមឈ្លបទាំងបួនក្រុមដើរធ្វើសកម្មភាពគ្រប់ទិសដែលត្រូវធ្វើសកម្មភាពនេះ គឺនៅខាងខេត្តពោធិ៍សាត់ទៅខាងទួលគ្រោះ និងអន្លង់ចម្រូង ។ រីឯក្រុមពីរ មានសមាជិកដូចជា សាន, បួ, និង ហឿន បានដឹកនាំធ្វើសកម្មភាពរបៀបសន្តិសម្ព័ន្ធ គឺមិនធ្វើសកម្មភាពវាយខ្មាំង ប៉ុន្តែធ្វើសកម្មភាពទាក់ទងទិញអង្ករ, និងដោះស្រាយសេដ្ឋកិច្ចខាងស្បៀងអាហារជាពិសេសខាងអង្ករ ។

ឆ្នាំ១៩៧០ ស៊ូ ត្រូវបានអង្គការបដិវត្តន៍ភូមិភាគចាត់តាំងឲ្យយកអាវុធនៅភូមិភាគនិរតី ។ មួយរយៈក្រោយមក ស៊ូ បានជួបជាមួយខ្មែរទាក់ទងចាស់ឈ្មោះ ធុច រិន ហៅ គ្រិន, អ៊ុម ឈឿន ហៅ ម៉ៃ ។ ការជួបនេះ ស៊ូ បានសាកសួរអំពីភារកិច្ចសម្ងាត់ និងបានរាយការណ៍អំពីភារកិច្ចរបស់ខ្លួនជូនមិត្តទាំងពីរបានដឹងដែរ ។ ឆ្នាំ១៩៧១ ស៊ូ ត្រូវបានអង្គការចាត់តាំងឲ្យធ្វើជាអនុលេខាតំបន់៤ ជាតំបន់ថ្មី ដោយមានអនុលេខាតំបន់មាន ឈ្មោះ ស៊ុយ ហើយមានអ្នកជំនួយបីនាក់ទៀតគឺយ៉ុង, ព្រមទាំងពួកវៀតណាម

ខាងជើងពីរនាក់ថែមទៀតឈ្មោះ ភុំមួយ, និងរួម(អ្នកទាំងពីរត្រូវបានអង្គការចាប់ខ្លួនរួចហើយ) ។

## សកម្មភាពនៅតំបន់៤

ចុះមកដល់តំបន់៤ សកម្មភាពដំបូងរបស់ ស៊ូ គឺប្រមូលកម្លាំងស្រទាប់លើវណ្ណៈសិរ្សធំទូលាយនិងមិនគិតគូរដល់កម្លាំងមូលដ្ឋានទេ ។ ក្រោយមក ស៊ូ បានទាក់ទងជាមួយថៅកែឡូនេសាទឈ្មោះ ទីវ ហួ ដោយខ្សែទាក់ទងជាកម្មាភិបាលដែលកសាងបានឈ្មោះ វ៉ុន នាទីជាអ្នកទទួលភារៈខាងនេសាទនៅទន្លេសាបរបស់តំបន់ទី៤ ។ ឈ្មោះ វ៉ុន នេះបានធ្វើការទាក់ទងជាមួយថៅកែ ទីវ ហួ តាមការអនុញ្ញាតរបស់ ស៊ូ ។ ក្នុងការទាក់ទងនេះគឺទាក់ទងលក់ឡូនេសាទឲ្យទៅថៅកែ ទីវ ហួ ។ ក្នុងការដែល ថៅកែ ទីវ ហួ នេះចូលធ្វើឡូនេសាទនៅក្នុងព្រៃរំដោះ គឺដើម្បីស៊ើបកម្លាំងរបស់បដិវត្តន៍ ។ ក្រោយពីក្តាប់កម្លាំងបដិវត្តន៍បានហើយ ដោយដឹងថាកម្លាំងរបស់ ស៊ូ កាន់តែខ្សោយៗទៅ ដូច្នេះ ថៅកែ ទីវ ហួ បានបញ្ចុះថ្លៃឡូនេសាទ ។ ដល់តថ្លៃឡើងចុះឡើងឃើញថាមិនបានសម្រេចបំណង ហើយថៅកែ ទីវ ហួ មិនព្រមបង់ថ្លៃឡូនេសាទនោះ ក្រោយមក ថៅកែ ទីវ ហួ បានយកទាហាន និងកងទ័ពមកដាក់ដើម្បីដាក់ការពារឡូនេសាទនេះថែមទៀត ។ នេះគឺជាសកម្មភាពក្បត់របស់ ស៊ូ ដែលទាក់ទងធ្វើសម្ព័ន្ធភាពជាមួយខ្មាំងនិងធ្វើឲ្យខ្មាំងដឹងកម្លាំងព្រមទាំងកាន់កាប់តំបន់រំដោះនោះបានថែមទៀត ។ នេះគឺជាអំពើក្បត់នឹងមាគ៌ារបស់អង្គការបដិវត្តន៍ដែលត្រូវពង្រឹងខ្មាំងផ្តាច់ស្បៀងអាហារខ្មាំង ។ ផ្ទុយទៅវិញ ស៊ូ បែរជាទៅចេញសំបុត្រឲ្យយកទៅចិញ្ចឹមខ្មាំងវិញ ។

នៅឆ្នាំ១៩៧២ ស៊ូ បានកសាងកម្លាំងប្រាំនាក់ទៀតមាន បឿយ គណៈស្រុក ក្រោយមក រស់នៅសហករណ៍នៅខាងស្រុកមោង, យ៉េន អតីតលេខាស្រុកមោង ក្រោយមក ជំនួយការខាងសាងសង់ផ្ទះឲ្យប្រជាជន, សឹម ជាលេខាស្រុកដូនទាវតំបន់៤, ធី អនុលេខាស្រុកមោង និង ហឿន ជាអនុលេខាស្រុកដូនទាវ ។ កម្លាំងទាំងនេះបានរួមអនុវត្តផែនការបដិវត្តន៍ដើម្បីឲ្យមានសម្ព័ន្ធភាពធ្វើសកម្មភាពដណ្តើមតំបន់រំដោះបាន ហើយដណ្តើមបានប្រជាជនថែមទៀត ។

នៅក្នុងឆ្នាំ១៩៧៣ ស៊ូ បានចាត់តាំងឲ្យ បឿយ នៅខាងមូលដ្ឋាន ហើយចំណែក មិត្ត ធុរ អនុវត្តតាមផែនការរបស់ សាយ ដែលបានដាក់ឲ្យ ស៊ូ ចុះជាប់ជាមួយនឹង បឿយ ដើម្បីពិគ្រោះគ្នានៅក្នុងសភាពការណ៍ជាក់ស្តែងនៃមូលដ្ឋានដើម្បីអនុវត្តផែនការនេះឲ្យបានសម្រេច ។ ក្រោយមក បឿយ មានយោបល់ថាលទ្ធភាពមូលដ្ឋាននេះគឺអាចធ្វើច្រកដើម្បីទាក់ទងជាមួយខ្មាំងបាន ព្រោះនៅពេលមុនៗខាងខ្មាំងក៏មានចោលពាក្យសម្តីធ្វើការទាក់ទងជាមួយនឹងយើងដែរ ។ ដូច្នេះសភាពរបស់ ធុរ នេះពិនិត្យទៅគឺឃើញថាអាចអនុវត្តផែនការដែល សាយ ជាមេ សេ.អ៊ី.អា នេះដាក់ឲ្យមកសម្រេច ។ ក្រោយមក ស៊ូ និង បឿយ បានឲ្យកម្មាភិបាលក្រោមចុះមកធ្វើការទាក់ទងដើម្បីធ្វើច្រកទាក់ទងគ្នា ។ ចាប់តាំងពីនោះមកច្រកនេះបានដំណើរការជាធម្មតាដោយអាចទិញដូររបស់របរចាំបាច់ខ្លះៗដូចជា ក្រណាត់, ថ្នាំពេទ្យ, និង អំបិល ជាដើមខាងបដិវត្តន៍បានលក់ចេញទៅវិញនូវ ត្រីងៀត, ត្រីឆ្អើរ និង អណ្តើក ដូច្នេះឃើញថា ច្រកនេះអាចទាក់ទងដំណើរការបានស្រួលខាងប្រជាជននៅក្នុងតំបន់រំដោះ ។ ដូច្នេះការដែលបើកច្រកនេះទៅខាងកងទ័ពក៏មិនហ៊ានធ្វើសកម្មភាពនៅត្រង់នេះព្រោះក្រែងប៉ះពាល់ដល់ការដាច់ច្រកនេះនាំឲ្យមានការលំបាកដោះស្រាយខាងផ្នែកសម្ភារដែលត្រូវខ្វះខាតផ្សេងៗដូច្នេះច្រកនេះគឺជាបរិយាកាសសន្តិភាពដែលទាក់ទងដោយធូរស្រាល ។ ក្រោយពីខ្មាំងក្តាប់បានសភាពការណ៍បដិវត្តន៍ហើយពួកខ្មាំងនឹងធ្វើសកម្មភាពចូលលុកលុយខាងក្រោយមូលដ្ឋាន ។ នៅខាងក្រោយមូលដ្ឋាន តាប៉ុន នេះគឺមាន ស៊ុយ ជាលេខាតំបន់បានពិភាក្សាជាមួយ ស៊ូ អំពីលទ្ធភាពដើម្បីអនុវត្តផែនការដែល សាយ ដាក់ចុះមក ។ ក្រោយពិភាក្សារួចឃើញថាមូលដ្ឋានខាងក្រោយរបស់ តាប៉ុន នេះអាចធ្វើសម្ព័ន្ធភាពជាមួយនឹងខ្មាំងបាន ព្រោះមានសក្តិពីរ អ៊ុក សុផុន ជាសាច់ញាតិរបស់ ស៊ុយ ធ្លាប់បានផ្ញើសំបុត្រឲ្យ ស៊ុយ តាមរយៈ សែន ជាលេខាស្រុកសង្កែដែលគ្រប់គ្រងខាង តាប៉ុន នេះ ។

ចាប់តាំងពីនោះមក ស៊ូ បានចុះទៅជួបជាមួយ សែន និងក្តាប់បានសភាពការណ៍ជាក់ស្តែងនៅមូលដ្ឋាននិងអនុវត្តផែនការដែល សាយ បានដាក់ឲ្យ ។ ក្រោយមក សែន បានយល់ស្របថាមានលទ្ធភាពបើកធ្វើការទាក់ទងជាមួយនឹង អ៊ុក សុផុន នេះដែរ ដោយសារ អ៊ុក សុផុន ធ្លាប់បានសរសេរសំបុត្រមកធ្វើការទាក់ទង

អង្គការបដិវត្តន៍របស់ក្រុមយើងដែរ ។ ដូច្នេះសភាពការណ៍ឃើញថាអាចអនុវត្តបាន ស៊ូ និង សែន ឲ្យបើកច្រកធ្វើការទាក់ទងជាមួយសក្តិពីរ អ៊ុក សុផុន ។ ច្រកនេះគឺជាច្រកដែលរូបភាពដោះស្រាយបញ្ហាសម្ភារផ្សេងៗនិងដើម្បីបោកបន្លំ ហើយខ្លឹមសារច្រកនេះគឺធ្វើឲ្យប្រជាជននៅក្នុងតំបន់រំដោះយល់ឃើញថា ពួក លន់ នល់ លែងកាចសាហាវ ហើយយល់ថាជាមនុស្សល្អ ។ ដូច្នេះគឺធ្វើឲ្យការរស់នៅសតិអារម្មណ៍ក្លាយជាសតិអារម្មណ៍សន្តិភាពមិនមានជំហរប្រយុទ្ធតស៊ូទៅមុខទៀត ។ ចំណុចមួយទៀត ពួក លន់ នល់ ដែលជាពួកចារកម្មអាចស៊ើបព័ត៌មានអំពីកម្លាំងបដិវត្តន៍ អ្នកដឹកនាំប្រជាជននិងការលំបាកផ្សេងៗនៅក្នុងជួរបដិវត្តន៍ ។ ដូច្នេះឃើញថា ការបើកច្រកនេះគឺបានផលប្រយោជន៍ដល់ សេ.អ៊ី.អា ជាច្រើនដោយបានសម្រេចផែនការដែលទប់ទល់នឹងការវាយសម្រុករបស់បក្សកុម្មុយនីស្តទៅលើពួក លន់ នល់ ។ ចំណែកនៅខាងពាមវិញ ស៊ូ បានចុះទៅផ្ទាល់ជាមួយ សឹម ជាអនុលេខាស្រុកដូនទាវ ។ នៅទីនោះ ស៊ូ មានលទ្ធភាពបើកច្រកដើម្បីធ្វើសន្តិសម្ព័ន្ធទាក់ទងជាមួយខ្មាំងបានអ្នកដែលទទួលផ្ទាល់ច្រកនេះគឺមាន កែវ ជាប្រធានកងអនុសេនាធំ ។

នៅឆ្នាំ១៩៧៤ ស៊ូ បានជួបជាមួយ សាយ ម្តងទៀត នៅពេលដែលទៅរៀនសូត្រនិងបានជួបនឹង វ៉ាញ, សៀន និង ស៊ាន ។ នៅពេលនោះ សាយ បានលើកសភាពការណ៍ថាបក្សកម្មុយនីស្តកម្ពុជាមានវិធានទប់ទល់នឹងខបាយកល សន្តិសម្ព័ន្ធនិងចារកម្មនេះយ៉ាងខ្លាំង ដូច្នោះត្រូវប្រឆាំងនឹងវិធានការណ៍នេះដោយបន្តសកម្មភាពសន្តិសម្ព័ន្ធនេះតទៅទៀត ហើយត្រូវធ្វើឲ្យកងទ័ព ខ្វះស្បៀង, ខ្វះគ្រាប់ ដោយយកលេសថាមកពីបញ្ហាភូមិសាស្ត្រ ។ ក្រោយមក ស៊ូ ក៏បានយកផែនការនេះមកពិភាក្សាជាមួយនឹង ស៊ុយ ដោយធ្វើយ៉ាងណាឲ្យកងទ័ពនៅក្នុងតំបន់បន្ថយការវាយសម្រុក ហើយលើកថា ខ្វះគ្រាប់រំសេវ ដូច្នេះវាយសម្រុកតាមលទ្ធភាពដែលមានអាចធ្វើបានសំខាន់ធ្វើឲ្យទ័ពមានភាពស្ពឹកស្រពន់ ។ ស៊ុយ បានអនុវត្តនៅផែនការនេះដោយធ្វើដំណើរយាមល្បាតទៅជិតប៉ុស្តិ៍របស់ខ្មាំង ។ ក្រោយមក ស៊ូ បានកសាងកម្លាំងឈ្មោះ រាន និង ហឿន ឲ្យទទួលភារកិច្ចនៅច្រកនេះតែម្តង ។ ក្រៅពីនេះ ស៊ូ បានបើកច្រកមួយទៀតនៅភូមិក្រកោះដោយបានពិភាក្សាជាមួយឈ្មោះ វ៉ន, ហួ, និង ហាក់ ដែលទទួលខុសត្រូវនៅក្នុងឃុំក្រកោះឃើញថាមានលទ្ធភាពបើកច្រកកន្លែងនេះអាចខាងខ្មាំងចង់ទាក់ទងដើម្បីទិញត្រីសាច់ពីក្រុមរបស់ខ្លួនដោយសារតែកន្លែងទ័ព លន់ នល់ ខ្វះខាតនៅខាង ត្រី សាច់ ជាច្រើនដូច្នេះឃើញលទ្ធភាពដែលអាចបើកច្រកនេះ ស៊ូ ក៏សម្រេចបើកឲ្យបើច្រកថ្មីមួយថែមទៀត ដើម្បីអនុញ្ញាតឲ្យខ្មាំងធ្វើសកម្មភាពបាន ។ ជាពិសេសដើម្បីវាយសម្រុករបស់កងទ័ពទៅផ្លូវជាតិលេខ៥ ត្រូវតាំងបើកច្រកធ្វើពាណិជ្ជកម្មគឺកងទ័ពមិនហ៊ានធ្វើសកម្មភាពទេ ពីព្រោះខ្លាចដាច់ច្រកផ្សារនេះ ។ ដូច្នេះ ទាហាន លន់ នល់ គឺមានការចំណេញម្យ៉ាងបានត្រីសាច់ដើម្បីយកទៅធ្វើម្ហូបអាហារនិងដើម្បីធ្វើការទាក់ទងឲ្យសម្ភារៈផ្សេងៗដល់កម្មាភិបាលដែលបានធ្វើការនៅតាមច្រកនេះផង ព្រមទាំងអាចស៊ើបការណ៍ពីតំបន់រំដោះបានផង ។ ដូច្នេះ ផែនការរបស់ សាយ បានដាក់ឲ្យ ស៊ូ គឺខិតខំអនុវត្តប្រឆាំងបក្សកម្មុយនីស្តកម្ពុជាដោយអនុវត្តឲ្យបានតាមបញ្ជារបស់មេ សេ.អ៊ី.អា គឺធ្វើយ៉ាងណាដើម្បីបន្តសកម្មភាពសន្តិសម្ព័ន្ធព្រមទាំងធ្វើឲ្យស្ពឹកស្រពន់មិនសូវវាយសម្រុកខ្មាំងដោយយកលេសថាខ្វះគ្រាប់រំសេវ ខ្វះស្បៀងអាហារ ឬភូមិសាស្ត្រមានទឹកច្រើនពេក ។

នៅក្នុងឆ្នាំ១៩៧៥ ស៊ូ បានជួបជាមួយ សាយ ម្តងទៀត ពេលដែលជួបនេះ ស៊ូ ក៏បានជួបជាមួយសមាជិកផ្សេងទៀតដែលមានឈ្មោះធ្លាប់ធ្វើ សេ.អ៊ី.អា ដូចជា វ៉ើង, ស៊ាន និងសៀន ។ នៅក្នុងជំនួបនេះ សាយ បានឲ្យដឹងថាសភាពការណ៍គឺមានចលនាវាយសម្រុកនៅក្រុមរបស់កងទ័ពបដិវត្តន៍ដោយស្ថិតនៅក្រោមការដឹកនាំរបស់បក្សកម្មុយនីស្តកម្ពុជាគឺកាន់តែខ្លាំង ដូច្នេះភារកិច្ចរបស់ក្រុមសេ.អ៊ី.អា គឺត្រូវធ្វើសកម្មភាពទប់ទល់យ៉ាងណាកុំឲ្យចលនានេះវាយសម្រុកបានសម្រេច ។ លើសពីនេះទៅទៀត ដើម្បីសម្របខ្លួននៅក្នុងការបង្កប់ខ្លួននៅក្នុងបក្សកម្មុយនីស្តកម្ពុជា ស៊ូ បានចុះមកមូលដ្ឋានដើម្បីបានផ្សាយអំពីវិធានការនេះដល់ក្រុម សេ.អ៊ី.អា នៅក្នុងតំបន់រំដោះខ្លួនដោយជំរុញឲ្យក្រុមរបស់ខ្លួនខិតខំធ្វើសកម្មភាពទប់ទល់នឹងការវាយសម្រុករបស់កងបដិវត្តន៍ដើម្បីបំផ្លាញបដិវត្តន៍ជាបន្តបន្ទាប់ ។ ក្រៅពីការនេះ ស៊ូ បានអប់រំកម្លាំង សេ.អ៊ី.អា បានចំនួនបួននាក់បន្ថែមទៀត និងបានបញ្ចូលឈ្មោះអ្នកទាំងបួនទៅក្នុងអង្គការសេ.អ៊ី.អា មានឈ្មោះ វ៉ុម ជាសមាជិក

គណៈស្រុកខ្ចប តំបន់៤, វ៉ែម សមាជិកគណៈសហករណ៍នៅក្នុងឃុំតាប៉ុន, ណន ជាសមាជិកសហករណ៍នៅក្នុងឃុំខ្ចប, និងជាសមាជិកសហករណ៍នៅក្នុងភូមិខ្ចបដែរ ។ ក្រោយមក ស៊ូ បានប្រគល់ភារកិច្ចឲ្យក្រុមនេះធ្វើការសកម្មភាពប្រឆាំងបំផ្លាញចលនាបដិវត្តន៍ដើម្បីធ្វើឲ្យប្រទេស កម្ពុជាទៅជារបបនាយទុនទៅវិញ ។

មួយរយៈក្រោយមក អង្គការភូមិភាគបានចាត់តាំងក្រុមរបស់ ស៊ូ ទាំងបីនាក់ធ្វើជាគណៈក្រុងបាត់ដំបងបណ្ដោះអាសន្ន ។ នៅក្នុងនោះ ស៊ុយ មានតួនាទីជាប្រធាន និងមានភារៈចាត់ចែងគ្រប់គ្រងទាហាន លន់ នល់ ហើយចំណែក វ៉ាញ ធ្វើអនុប្រធាននិងមានភារៈខាងសេដ្ឋកិច្ច និងចុងក្រោយ ស៊ូ ជាសមាជិកទទួលភារៈខាងនយោបាយ ។ នៅក្នុងសកម្មភាពដំបូង ស៊ូ តាមណែនាំរបស់ ស៊ុយ ដែលជាប្រធានថានឹងចាត់ការឲ្យបានរហ័សគឺត្រូវធ្វើការទាក់ទងយកខ្មែររបស់ខ្មាំងប្រើជាបណ្ដោះអាសន្នដូច្នេះបានជានៅក្នុងការងារផ្សេងៗដូចជា រកយានជំនិះ រកស្បៀងអាហារ, ប្រមែប្រមូលអ្នកក្រុងមកជួបជុំគ្នា ។ នៅក្នុងក្រុងនេះ ក្រុមរបស់ ស៊ូ បានទទួលការណែនាំពី សាយ ឲ្យបំផ្លាញបដិវត្តន៍ខាងការរុះរើ ធ្វើការឲ្យមានការអន្តរាយដូចជា គ្រឿងម៉ាស៊ីនជាដើម ។

ពីរថ្ងៃ បន្ទាប់ពីថ្ងៃរំដោះ ស៊ូ បានទទួល សោម សំអ៊ុន តាមរយៈ ហឿន ខ ទ្មេសនាម និងចាត់តាំងឲ្យ សំអ៊ុន ជួយធ្វើការងារដោយឃោសនាដែលជាភារកិច្ចនយោបាយរបស់ ស៊ូ និងណែនាំឲ្យ សំអ៊ុន រកខ្មែរសន្ដាក់របស់ខ្លួនមួយចំនួនទៀត ។ ពេលនោះ សំអ៊ុន ជ្រើសរើសខ្មែរសន្ដាក់របស់ខ្លួនបានចំនួន៧០ នាក់ដោយបានយកទៅប្រគល់ឲ្យកម្មាភិបាលតាមស្រុកនិងឃុំឲ្យធ្វើជំនួយរបស់កម្មាភិបាលសហករណ៍ដើម្បីរៀបចំឲ្យប្រជាជនជម្លៀសនេះជាការចាត់តាំងតាមផ្លូវការតែសកម្មភាពជា សេ.អ៊ី.អា ។ ស៊ូ បានចាត់ចាំងឲ្យធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ដូចជាឲ្យធ្វើស្ថិតិខុសដើម្បីនាំឲ្យមានការច្របូកច្របល់នៅក្នុងការគ្រប់គ្រងដោយមិនឲ្យដាក់គ្រប់ឬបន្ថែមលើសចំនួនព្រមទាំងចាត់តាំងឲ្យធ្វើយ៉ាងណាឲ្យមានទំនាស់ជាមួយកម្មាភិបាលបដិវត្តន៍ដែលធ្វើការជាមួយគ្នា ។ ជាពិសេសនៅក្នុងគោលបំណងដើម្បីឲ្យប្រជាជនទំនាស់ជាមួយនឹងកម្មាភិបាលបដិវត្តន៍ ។ ភារកិច្ចសេ.អ៊ី.អា ដែលប្រគល់ឲ្យនេះមានសមាជិកចំនួនចិតសិបនាក់ដែលជាខ្មែរសន្ដាក់របស់ សោម សំអ៊ុន ។ លើសពីនេះទៀត សំអ៊ុន ជាមួយ ស៊ូ បានក្ដាប់សភាពការណ៍ប្រជាជនដែលជម្លៀសចំណុចស្រួលនិងពិបាកដើម្បីធ្វើវិទ្ធង្សនកម្មផ្សេងៗ នៅពេលនោះដោយមានកន្លែងខ្វះស្បៀងអាហារហើយដឹកជញ្ជូនមិនទាន់ពេលវេលាដែលនាំឲ្យប្រជាជនជម្លៀសមានការលំបាកមានការទោមនស្សនឹងអង្គការបដិវត្តន៍ ។

ក្រៅពីនេះក្រុមរបស់ ស៊ូ បានធ្វើវិទ្ធង្សនកម្មដោយមានមិនសួរអើពើគិតគូរជួយរកជម្រកដល់ប្រជាជនថ្មីនិងមិនជួយដោះស្រាយសម្ភារចាំបាច់មានដូចជា ចាន ឆ្នាំង ជាដើម ធ្វើឲ្យមានការលំបាកដើម្បីកើតទំនាស់នឹងអង្គការបដិវត្តន៍នេះគឺជាសកម្មភាពដែលក្រុម សំអ៊ុន បានចូលរួមធ្វើសកម្មភាព សេ.អ៊ី.អា ។ ក្រោយមក សំអ៊ុន និងបក្សពួកចំនួនប្រាំមួយទៅប្រាំពីរនាក់ត្រូវបាន ស៊ូ ចាត់តាំងឲ្យធ្វើការជាប់នឹងគណៈស្រុកធ្វើយ៉ាងណាឲ្យគណៈស្រុកមានទំនុកចិត្ត ហើយប្រើប្រាស់ជាដំបូងគឺប្រើខាងបច្ចេកទេសជាសរសេរកត់ត្រាផ្សេងៗដូចជាគូសផែនទីប៉ុន្តែដល់យូរៗទៅមានការទុកចិត្តពេលនេះគេអាចនឹងប្រគល់ភារកិច្ចអ្វីនៅក្នុងជួរបដិវត្តន៍គឺនៅពេលដែលមានភារកិច្ចមួយនៅក្នុងជួរបដិវត្តន៍ច្បាស់លាស់ហើយនោះក្រុមរបស់ សោម សំអ៊ុន អាចធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ដោយយករូបភាពជាអ្នកបដិវត្តន៍តែសកម្មភាពគឺប្រឆាំងនឹងបដិវត្តន៍ ។

ចំពោះ សំអ៊ុន និងក្រុមរបស់ខ្លួនមួយចំនួនបានការទុកចិត្តពីកម្មាភិបាលខាងតំបន់ និងខាងស្រុក ជាបន្តបន្ទាប់ ។ ចំណែកក្រុមចិតសិបនាក់ដែលរួមមកដើម្បីជួយរៀបចំប្រជាជនជម្លៀសនេះក្រោយមក ស៊ូ បានដកឲ្យទៅចុះជាប់នឹងសហករណ៍ ។ នៅទីនោះគឺចាត់តាំងឲ្យស្គាល់ភារកិច្ចគឺធ្វើសកម្មភាពវាយប្រហារប្រឆាំងនឹងអង្គការបដិវត្តន៍ ជាពិសេសគឺបញ្ហាខ្វះខាត ស្បៀងអាហារ ថ្នាំសង្កូវ និងប្រឆាំងសហករណ៍ឲ្យរស់នៅជាឯកជន ។ ចំណែក ស៊ូ និង សំអ៊ុន វិញ ជាអ្នកទទួលក្ដាប់ការរាយការណ៍ ហើយណែនាំសកម្មភាពផ្ទាល់ជាបន្តបន្ទាប់ ។ នៅពេលត្រូវជម្លៀសប្រជាជន ស៊ូ បានទាក់ទងពេទ្យសង្គមចាស់ឈ្មោះ ពីង គីមស៊ា និង ឃីម គីមសាន ដែលជាពេទ្យធំនៅក្នុងក្រុងបាត់ដំបង ព្រមទាំងបានយកពេទ្យចំនួន៦ គ្រួសារផ្សេងទៀតមកដាក់នៅក្នុងតំបន់៤ក្នុងគោលបំណងដើម្បីប្រើប្រាស់បច្ចេកទេសរបស់ក្រុមខ្លួននៅពេលដែលបើកមន្ទីរពេទ្យ

ថ្មីៗ ដោយសារតែប្រជាជនជម្លៀសមកច្រើន ។ នៅចុងខែមិថុនា និងខែកក្កដា ស៊ូ បានយកពេទ្យ ពីង គឹមស៊ា និង ឃឹម គឹមសាន ទៅប្រើនៅតាមមន្ទីរពេទ្យស្រុក ។ ជាផ្លូវការគឺចាត់តាំងឲ្យជំនួយការបច្ចេកទេស ប៉ុន្តែភារកិច្ចសេ.អ៊ី.អា គឺត្រូវធ្វើយ៉ាងណាឲ្យបំផ្លាញបដិវត្តន៍នៅក្នុងផ្នែកសង្គមកិច្ច សុខាភិបាល នេះឲ្យបានជាអតិបរមា ។ ពីង គឹមស៊ា នេះ ស៊ូ ស្គាល់ខ្សែថាជា សេ.អ៊ី.អា តាមរយៈ សំអ៊ិន ជាអ្នកខ្ទេសនាម ។ នៅក្នុងមន្ទីរនេះ ពីង គឹមស៊ា និង ឃឹម គឹមសាន គឺបានធ្វើសកម្មភាពតាមការចាត់តាំងរបស់ ស៊ូ គឺបានប្រឆាំងនឹងការប្រើប្រាស់នូវថ្នាំបូរាណដោយបំផុសមិនឲ្យអ្នកជំងឺជឿទៅលើថ្នាំបូរាណ ព្រមទាំងធ្វើឲ្យខូតខាតនៅថ្នាំពេទ្យនៅក្នុងឃ្លាំង និងទុកឲ្យខូចខាតប្រើប្រាស់មិនបាន ។ ទន្ទឹមនេះចំពោះឥទ្ធិពលនៅក្នុងចំណោមអ្នកជំងឺនិងពេទ្យគឺ ពីង គឹមស៊ា និង ឃឹម គឹមសាន មានឥទ្ធិពលលើសពេទ្យបដិវត្តន៍ ពីព្រោះអ្នកទាំងពីរមានបច្ចេកទេសជឿនលឿនជាង ម្យ៉ាងទៀតមហាជនប្រជាជនធ្លាប់ស្គាល់ដោយមានការទទួលស្គាល់ថាជាពេទ្យធំដូច្នេះការប្រើប្រាស់អ្នកទាំងពីរនេះនាំឲ្យប៉ះពាល់ដល់មាគ៌ាបក្សកម្មុយនីស្តកម្ពុជាដែលតែងតែលើកឡើងថាពេទ្យយើងគឺចេញពីអ្នកក្រចេញពីស្រទាប់មូលដ្ឋាន ហើយបច្ចេកទេសរបស់ក្រុម ស៊ូ គឺរៀនបណ្តើរធ្វើបណ្តើរ សកម្មភាពរបស់សេ.អ៊ី.អា របស់ ពីង គឹមស៊ា នៅក្នុងមន្ទីរនេះគឺបានធ្វើសកម្មភាពខ្លាំងដែលនាំបណ្តាលឲ្យដល់អ្នកជំងឺមិនមានជំនឿលើថ្នាំបូរាណជឿលើតែថ្នាំវិទ្យាសាស្ត្រ ។

ក្រោយមក ស៊ូ ដោយសារតែឃើញ ពីង គឹមសា នេះធ្លាប់មានឥទ្ធិពលនៅក្នុងប្រជាជននៅក្នុងសង្គមចាស់ច្រើនដូច្នេះបើដាក់ ពីង គឹមស៊ា ឲ្យទៅអនុវត្តភារកិច្ច សេ.អ៊ី.អា នៅក្នុងសហករណ៍ឃើញថាមានប្រសិទ្ធភាពជាងនៅក្នុងមន្ទីរពេទ្យ ។ ចាប់តាំងពីនោះមក ស៊ូ បានចាត់តាំង ពីង គឹមស៊ា ចុះទៅបន្តសកម្មភាព សេ.អ៊ី.អា នៅក្នុងសហករណ៍វិញ ដោយបានបំផុសកំហឹងឲ្យមានការទោមនស្សជាមួយអង្គការបដិវត្តន៍ ពិសេសបញ្ហាខ្វះស្បៀងអាហារ ថ្នាំសង្កូវ សម្លៀកបំពាក់ និងប្រឆាំងនឹងសហករណ៍ទាមទារការរស់នៅជាឯកជនវិញ ។

## សកម្មភាពក្នុងនាទីជាគណៈទាក់ទងព្រំដែនកម្ពុជា-ថៃ

នៅថ្ងៃ១២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ស៊ូ ត្រូវបានអង្គការចាត់តាំងជាគណៈទាក់ទងព្រំដែនកម្ពុជា-ថៃ ។ សាយ បានចាត់តាំងឲ្យ ស៊ូ ធ្វើការទាក់ទងជាមួយ ហ៊ីង ដោយសារ ស៊ូ ត្រូវដាច់ចេញពីការងារពីភាគទៅហើយ និងទៅរស់នៅក្នុងតំបន់របស់ ហ៊ីង ដូច្នេះការងារសម្ងាត់របស់ សេ.អ៊ី.អា ត្រូវទាក់ទងតាមរយៈ ហ៊ីង ។ ទន្ទឹមនឹងនោះ សាយ ក៏បានខ្ទេសនាម ស៊ូ ឲ្យបានដឹងថា ឈ្មោះ ម៉ៃ ដែលរួមភារកិច្ចគណៈទាក់ទងនេះក៏ជាមនុស្សនៅក្នុងក្រុម សេ.អ៊ី.អា ដែរ ដូច្នេះត្រូវសហការគ្នាឲ្យបានល្អ ។

ចាប់ពីពេលនោះមក ស៊ូ បានស្គាល់តាមការខ្ទេសនាមរវាងតំណាងកម្ពុជានិងតំណាងប្រទេសថៃនូវគណៈទាក់ទងដែលត្រូវធ្វើការជាមួយគ្នាមានឈ្មោះ សួង ជាប្រធាន និង សាវ៉ាត ជាអនុប្រធាន ។ អ្នកទាំងពីរគឺមកពីក្រសួងការបរទេសនៅបាងកក ។ ឈ្មោះ អំនួយ ជាសមាជិកនិង ជាចៅហ្វាយស្រុកអារញ្ញនិងឈ្មោះ ជេឆា ជាអ្នកបកប្រែភាសាថៃមកខ្មែរនិងពីខ្មែរទៅថៃ ។ ក្នុងការធ្វើការទាក់ទងជាមួយនឹងគណៈទាក់ទងថៃនេះ ពេលដំបូងគឺស៊ូធ្វើការជាផ្លូវការធម្មតាទេ ។

ខែមករា ឆ្នាំ១៩៧៦ ពេលនោះអង្គការភូមិភាគបានឲ្យ ស៊ូ បើកច្រកផ្សារដើម្បីនឹងធ្វើទីផ្សារលក់ដូរត្រី-សាច់ដែលមានសល់ទុកមួយចំនួននៅអូរជ្រៅ ។ ពេលនោះ ស៊ូ បានធ្វើការទាក់ទងបើកច្រកផ្សារនាំចេញផលិតផលគ្រឿងឧបភោគបរិភោគមួយចំនួន មានដូចជា ការនាំចេញសាច់, ត្រី, កាហ្វេ, គ្រាប់ឈូក, គ្រាប់ធញ្ញជាតិជាដើម ។ ក្រៅពីនេះ ស៊ូ បានធ្វើទំនាក់ទំនងជាមួយឈ្មួញផ្នែករត់ពន្ធគយឈ្មោះ ឡុប, ឡាង, ឡេង, និង ផុន នេះជាអ្នករត់គយស្រី ចំណែកឈ្មោះ ឃុន, ផួន ជាប្រុស ។ ក្នុងការទាក់ទងនេះ ជាដំបូង ស៊ូ បានទទួលអំណោយរបស់ក្រុមនេះមានផ្លែឈើ,ផ្លែទំពាំងបាយជូរ,ផ្លែក្រូច ជាដើម ។ ឆ្លៀតឱកាសនេះ ស៊ូ បានស៊ើបការណ៍អំពីស្ថានភាពសភាពការណ៍នៅប្រទេសថៃជាពិសេសស៊ើបសួរអំពីសភាពការណ៍នៃពួកខ្មែរដែលបានរត់ភៀសខ្លួនទៅខាងថៃ តើមានចំនួនប៉ុន្មាននាក់? ហើយនៅកន្លែងណាខ្លះ? តាមការទទួលព័ត៌មានពីអ្នករត់គយបានឲ្យដឹងថាឃើញមានបីកន្លែង ប៉ុន្តែក្រុមនេះច្រើនស្គាល់តែអារញ្ញនេះមានខ្មែររត់ទៅប្រហែលជាមានចំនួនបួនពាន់នាក់ ។ ចំណែកនៅខាងម៉ាឡៃវិញ ក៏មានទ័ពខ្មែររត់ទៅទីនោះដោយស្ថិតនៅក្រោមការដឹកនាំគ្រប់គ្រងរបស់ឈ្មោះ

សេក សំអៀត និង អ៊ិន តាំ ។ ទ័ពនេះគឺក្រុមទាហានចាស់ៗដែលបានរត់ពីកម្ពុជាទៅនៅក្នុងជំរំភៀសខ្លួន ។

នៅខែមិថុនា ឆ្នាំ១៩៧៦ ស៊ូ ត្រូវទទួលខាងពាណិជ្ជកម្មរដ្ឋមានឈ្មោះ ឈឿន, ហាន និង យត ។ ស៊ូ ទទួលអ្នកទាំងនោះដោយយកចិត្តទុកដាក់ព្រោះជាភារកិច្ចដែល ស៊ូ ទៅនៅកន្លែងនោះ មុនហើយក្រសួងពាណិជ្ជកម្មនេះបានធ្វើការទាក់ទាញមនោសញ្ចេតនារបស់ ស៊ូ ជាច្រើនដោយឲ្យសម្ភាររបស់ហូបមានសម្រង់ បន្លងជាដើម និងឲ្យវ៉ែនតាមីញ៉ូប ដល់ ម៉ៃ និងហ្វីលថតរូប ព្រមទាំងខ្សែអាត់ថតចម្រៀងដល់ ស៊ូ មួយចំនួនទៀតផង ។ ការទាក់ទងជាមួយពាណិជ្ជកម្មរដ្ឋនេះ គឺធ្វើការទាក់ទងជាមួយពាណិជ្ជកម្មមន្ទីរ-ក្រសួងរបស់អង្គការដូចគ្នា ។ ចំណែកសកម្មភាពរបស់ក្រុមពាណិជ្ជកម្មនេះ គឺមានសិទ្ធិទាក់ទងផ្ទាល់ជាមួយនឹងឈ្មួញថៃ ព្រោះក្រសួងទាំងពីរនេះមានការឡើងទៅថ្នាក់លើទាំងពីរផ្សេងៗគ្នា ។ ដូច្នេះខាងក្រសួងពាណិជ្ជកម្ម ក៏មានសិទ្ធិទាក់ទងផ្ទាល់ដោយឆ្លងតាមយោធាដែលទទួលខុសត្រូវមានឈ្មោះ ឈឿង ជាអ្នកទទួលខុសត្រូវច្រកចេញចូល ។ ចំណែកឯ ស៊ូ ទាក់ទងជាមួយគណៈទាក់ទងក៏ប្រាប់ខាងយោធាដើម្បីអាចអនុញ្ញាតឆ្លងកាត់ដែរ ក្រុមពាណិជ្ជកម្មរដ្ឋ ដែល ស៊ូ បានទាក់ទងមានឈ្មោះដូចជា ឈឿន ជាអ្នកទទួលខុសត្រូវនៅក្នុងការគ្រប់គ្រងនៅខាងអូរជ្រៅ ដើម្បីពិភាក្សាគ្នាអំពីបញ្ហាទិញដូរទៅវិញទៅមក ។ ក្រោយមក ស៊ូ និង ឈឿន ទាក់ទងឈ្មួញខ្លះទៀត ដើម្បីយកមកធ្វើការទាក់ទងជាផ្លូវសម្ងាត់ហើយនិងធ្វើការបើកចំហខ្លះ គឺផ្លូវពាណិជ្ជកម្មឈ្មោះ ឈឿន ដែល ស៊ូ ទាក់ទងនោះគឺមានឈ្មោះ ហម ។ ក្រោយមក ស៊ូ ក៏បានធ្វើការទាក់ទងជាមួយឈ្មោះបន្តបន្ទាប់ទៀតដែលមានឈ្មោះ ហាន និង យត ។ ឈ្មោះ ហាន បានមកពីងពាក់ខាងកន្លែងរបស់ ស៊ូ ដើម្បីវាយសារទូរលេខទៅភ្នំពេញតាមវិទ្យុទាក់ទង ។ ដូច្នេះក្រសួងទាំងពីរនេះក៏មានទំនាក់ទំនងគ្នាតាមផ្លូវការខ្លះ ដូចជាទទួលភារៈខាងបញ្ជូនទូរលេខជាដើម ។ ចំណែក សកម្មភាពសម្ងាត់របស់ ហាន គឺមានឈ្មោះ យត នៅខាងអូរជ្រៅមានសកម្មភាពទាក់ទងជាប់ជាមួយនឹងឈ្មួញថៃពីព្រោះឈ្មួញថៃចុះឡើងជារាល់ថ្ងៃ ។ ដូច្នេះសកម្មភាពរបស់ ស៊ូ ក៏បានរួមចំណែកនៅក្នុងសកម្មភាពក្នុងអំពើក្បត់របស់ក្រុមពាណិជ្ជកម្មរដ្ឋដែរ ។ មួយចំណែកទៀត ក្រុមពាណិជ្ជកម្មក៏មានឈ្មួញមានថៅកែដែលខាងពាណិជ្ជកម្មរដ្ឋនេះទាក់ទងផ្ទាល់ដោយខ្លួនឯង ហើយស្នើឲ្យខាងយោធាគេអនុញ្ញាតឲ្យជួប ។

ពាក់កណ្តាលឆ្នាំ១៩៧៦ ស៊ូ និង ម៉ៃ បានជួប ហម ជាខ្មែរនៅសុរិន្ទនាទីអ្នកតំណាងខាងទេសចរណ៍នៅបាងកកប្រទេសថៃ ។ ចំណែក ហម ដោយសារធ្លាប់បានស្គាល់ឈ្មោះ ស៊ូ និង ម៉ៃ និងដោយសារតែ ហម នេះបានទទួលឪពុកដែលជាប់នៅខាងប្រទេសកម្ពុជាយើងក្រោយរំដោះ ហើយអង្គការបដិវត្តន៍ក៏បានអនុញ្ញាតដោះលែងប្រគល់ឲ្យទៅខាងថៃវិញ ។ ក្រោយពីបានថ្លែងអំណរគុណចំពោះអ្នកទាំងពីរហើយ ហម ក៏បានប្រាប់ទៅកាន់ ស៊ូ និង ម៉ៃ ថាបើចង់ពឹងពាក់អ្វីគេនឹងជួយ ។ ក្រោយមក ហម ក៏បានជួបជាមួយ ស៊ូ ដើម្បីធ្វើការទាក់ទងនៅក្នុងការទិញឈើដែលសេសសល់តាមព្រំដែនគឺមានឈើសល់មួយចំនួនដែលមិនទាន់បានដឹកទៅប្រទេសថៃ ។ ប៉ុន្តែ ក្រោយមក ឈើទាំងនេះត្រូវបានថៃចូលមកលួចអារតាមរយៈ ហម ។ ដូច្នេះ ហម នេះចង់ទាក់ទងទិញឈើនេះដែលសល់នោះគឺសុំឲ្យកម្ពុជាចេញសំបុត្រឲ្យដើម្បីនាំឈើចូលទៅប្រទេសថៃ ។ បំណង ហម ដែលមកទាក់ទងជាមួយ ស៊ូ ប៉ុន្តែ ស៊ូ មិនបានដោះស្រាយរឿងនេះទេ ។ នៅក្នុងឱកាសនេះ ស៊ូ បានឆ្លៀតឱកាសដើម្បីស៊ើបសួរអំពីសភាពការណ៍ជនជាតិខ្មែរដែលរត់ពីកម្ពុជាទៅ តើមាននៅកន្លែងណាខ្លះ? ហើយមានសភាពយ៉ាងម៉េចខ្លះ? ក្រោយមក ហម ក៏បានប្រាប់ដំណឹងទៅកាន់ ស៊ូ ថាខ្មែរដែលរត់ពីកម្ពុជាត្រូវបានរស់នៅក្នុងជំរំដែលមានអាមេរិកកាំងជួយជំរំនេះគឺមានពួកអាមេរិកកាំងចំនួនបីនាក់ នៅក្នុងខាងសុរិន្ទមួយ នៅខាងអារញ្ញមួយ, និងខាងចាន់បូរីទល់គ្នា នឹងប៉ៃលិនមួយ ។ ជំរំទាំងបីនេះគឺនៅក្រោមការឧបត្ថម្ភរបស់អាមេរិកាំង ចំណែកឯខ្មែរដែលរត់ទៅនៅខាងជំរំទាំងបីនេះមានចំនួនប្រហែលជាមួយម៉ឺននាក់ ។ ចំណែកខាងកម្លាំងទ័ពគឺដឹងថានៅខាងភ្នំម៉ាឡៃមានចំនួនប្រហែលពីររយនាក់ ។

បន្ទាប់ពីបានទទួលដំណឹងផ្សេងអំពីក្រុមកម្លាំងក្បត់ដែលនៅខាងប្រទេសថៃ ស៊ូ ក៏បានរាយការណ៍ជូនដំណឹងទៅកាន់ សាយ តាមដំណើរគឺរៀបរាប់អំពីខ្មែរក្បត់នៅខាងប្រទេសថៃដែលមានជំរំនៅខាងខេត្តទាំងបី ហើយរាយការណ៍អំពីព័ត៌មាន អ៊ិន តាំ និង សេក សំអៀត តាមឈ្មោះ ហម ឲ្យព័ត៌មានគឺបានចេញក្រៅ

ប្រទេសថៃ គឺនៅខាងស្រុកបារាំង ចំណែក សេក សំអៀត វិញគឺនៅក្រុងបាងកកនៅឡើយ ។

នៅពេលនោះ សាយ បាននិយាយប្រាប់ថាត្រូវបន្តស៊ើបការណ៍និងព័ត៌មាននេះជា បន្តទៀត តាមរយៈឈ្មោះ ហម នេះដើម្បីធ្វើរាវរកខ្សែទាក់ទងមេសេ.អ៊ី.អា អាមេរិកកាំងនៅប្រទេសថៃឲ្យបាន ។ ចុងឆ្នាំ១៩៧៦ ស៊ូ បានរៀបចំដើម្បីជួបគ្នារវាងមេសេ.អ៊ី.អា អាមេរិកកាំងដែលមាន ហម នេះជាអ្នកទាក់ទងនិងគណៈរដ្ឋប្រហារដែលនៅខាងភាគពាយ័ព្យ ។

ដើមឆ្នាំ១៩៧៧ ពេលថ្ងៃកំណត់ធ្វើការធម្មតាជាមួយគណៈទាក់ទងថៃបាននាំមេសេ.អ៊ី.អា អាមេរិកកាំង និង សេក សំអៀត មកជួប ស៊ូ នៅកន្លែងទាក់ទងគណៈទាក់ទងនៅក្នុងទឹកដីកម្ពុជានៅពេលនោះយើងបានត្រៀមមនុស្សដែលត្រូវជួបនឹងមេសេ.អ៊ី.អា អាមេរិកកាំងនេះ គឺមាន សាយ, សាន, វ៉ើញ , ហិង, ស៊ូ និង ម៉ៃ ជាគណៈទាក់ទង ។ ខាងផ្នែកថៃ គឺមានគណៈទាក់ទងថៃគឺមានប្រធាន អនុប្រធាន ហើយនិងអាមេរិកកាំងម្នាក់ និង សេក សំអៀត រួមទាំងអ្នកបកប្រែ ។ ពេលនោះ អ្នកទាំងនោះក៏បានជួបគ្នានៅផ្ទះគណៈទាក់ទងនៅកន្លែងធ្វើការជាផ្លូវការក្នុងការទាក់ទងនេះគឺមេសេ.អ៊ី.អា បានទទួលស្គាល់ សាយ នេះជាមេរដ្ឋប្រហារ ។ សាយ មានការសប្បាយរីករាយត្រេកអរយ៉ាងខ្លាំងដោយបានជួបជាមួយមេ សេ.អ៊ី.អា ។ ក្រោយមក ហឹង ថាការទទួលខុសត្រូវនេះយើងត្រូវយកចិត្តទុកដាក់ធ្វើយ៉ាងណាដើម្បីទាក់ទងឲ្យបានល្អនិងឲ្យបានឆាប់ ដើម្បីសម្រេចផែនការរបស់យើង ដូច្នេះក្នុងភារកិច្ចទាក់ទងគឺត្រូវមានការទាក់ទងឲ្យជាប់ដើម្បីរាយការណ៍ទៅមេ សេ.អ៊ី.អា អាមេរិកកាំងនៅប្រទេសថៃ ។ ពីព្រោះពេលដែលយើងផ្ទុះផែនការរបស់យើងគឺយើងត្រូវការសម្ភារមកជំនួយដែលត្រូវមកទាន់ពេលវេលាដូចជា គ្រាប់រំសេវ ឡានដឹកជញ្ជូន និង យន្តហោះជាដើមដែលយើងប្រើជាជំនួយនៅក្នុងការសម្រេចផែនការរបស់យើង ។ នៅពេលប្រជុំនេះ អ្នកទាំងអស់គ្នាបានស្តាប់ការណែនាំរបស់ សាយ ហើយម្នាក់ៗបានបំពេញភារកិច្ចបានយ៉ាងល្អបំផុត ហើយរក្សាការសម្ងាត់ទីបំផុត ។

សាយ បានផ្តែផ្តាំទៀតថា យើងត្រូវរក្សាសម្ងាត់ឲ្យបានជាទីបំផុត ហើយសហការគ្នាឲ្យបានល្អ រៀបចំលក្ខណៈសម្បត្តិយើងគ្រប់គ្រាន់ដើម្បីឲ្យផែនការនេះបានសម្រេច ។ នៅពេលនោះ អ្នកទាំងអស់គ្នាបានបែកគ្នា ហើយត្រឡប់ទៅកន្លែងរៀងៗខ្លួនដើម្បីចាប់អនុវត្តផែនការដែល សាយ បានណែនាំ ។ ផែនការរបស់ ស៊ូ ត្រូវជួបជាមួយមេតំណាង សេ.អ៊ី.អា អាមេរិកកាំងនេះម្តងទៀត ។ ដូច្នេះគណៈទាក់ទងត្រូវទទួលភារកិច្ចរៀបចំជាមួយមេសេ.អ៊ី.អា ឲ្យបានស្រួលបួលនៅដើមខែ ។ ឯខាងគណៈទាក់ទងនៅខាងអូរជ្រៅគឺត្រូវទាក់ទងឲ្យជាប់នឹងឈ្មោះ ហម នេះដើម្បីរាយការណ៍ជាបន្តបន្ទាប់ទៅឲ្យមេ សេ.អ៊ី.អា ដើម្បីឲ្យក្តាប់សភាពការណ៍ផែនការវិវត្តយើងឲ្យបាន ។

នៅខែមេសា ឆ្នាំ១៩៧៧ ស៊ូ បានត្រឡប់មកកាន់មាតុប្រទេសវិញ ហើយនៅពេលនោះ ស៊ូ ត្រូវបានអង្គការឃាត់ទុកនៅក្រសួងការបរទេសភ្នំពេញនេះ រហូតដល់ខែឧសភា និង មិថុនា ឆ្នាំ១៩៧៧ អង្គការមិនបានប្រគល់ភារកិច្ចអ្វីឲ្យច្បាស់លាស់ទេ គឺនៅក្រសួងការបរទេសនេះ រហូតដល់ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ ស៊ូ ត្រូវបានក្រសួងសន្តិបាលចាប់ខ្លួនតែម្តង ។

**ស៊ិន សុធីតា**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១៦) ៨៧៦ ៦៩២

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: truthsocheat@dccam.org*

*Home page: www.dccam.org*

# វគ្គបណ្តុះបណ្តាលគរុនិស្សិតលើកទី១ ស្តីអំពីការបង្រៀនប្រវត្តិសា











# ស្រ្តកម្ពុជាប្រជាធិបតេយ្យពីថ្ងៃទី២៣ ដល់២៨ ខែកក្កដា ឆ្នាំ២០១២











# សំឡេងពីស្រុកអន្លង់វែង

## មរតកអតីតកាល និង ជីវិតបច្ចុប្បន្ន

ស្រុកអន្លង់វែងគឺជាទីចំណាប់អារម្មណ៍មួយសម្រាប់អ្នកដំណើរនិងភ្ញៀវទេសចរ ហើយមនុស្សម្នាមកកាន់តំបន់នេះដើម្បីមកប្រកបរបរចិញ្ចឹមជីវិតព្រោះទីនេះគឺជាទីតាំងចុងក្រោយរបស់ចលនាខ្មែរក្រហម ។ អន្លង់វែងគឺជាទីតាំងដែលចលនាខ្មែរក្រហមរលំរលាយក្នុងភាពវឹកវរនិងភាពអាប់យស ។ អន្លង់វែងគឺជាតំបន់ពិសេសមួយដែលខុសពីតំបន់ផ្សេងទៀតក្នុងប្រទេសកម្ពុជាត្រង់ថា តំបន់នេះមានបន្សល់នូវកេរដំណែលខ្មែរក្រហមជាច្រើនដូចជាផ្នូររបស់ ប៉ុល ពត នាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យនិងជាមេដឹកនាំកំពូលឯទៀតរបស់ចលនាខ្មែរក្រហម ។ ផ្នូររបស់ ប៉ុល ពត គឺជាសំណង់ឈើតូចមួយមានលក្ខណៈសាមញ្ញមានរាងចតុកោណដោយមានដីពូនជាផ្នូរ ហើយមានទីតាំងនៅពីមុខបនល្បែងកាស៊ីណូ ដែលទង្វើបែបនេះត្រូវបានហាមឃាត់ទាំងស្រុងទូទាំងរបបនៃកណ្តាប់ដៃដែករបស់ខ្មែរក្រហម ។ ព្រលឹងរបស់ ប៉ុល ពត ហាក់បីដូចជានៅទីនោះជារៀងរហូត ភ្នែកសម្លឹងមើលទៅអាគារកាស៊ីណូនោះដោយមិនអាចធ្វើអ្វីបានទាំងអស់នូវអ្វីដែលខ្លួនធ្លាប់ចាត់ទុកថាជាទង្វើរបស់ "មូលធននិយម" ។

អន្លង់វែងបានបន្សល់នូវសំណល់ជាច្រើននៃរបបកម្ពុជាប្រជាធិបតេយ្យដូចជា ផ្ទះនិងទីបញ្ជាការរបស់ តាម៉ុក ដែលមានទីតាំងនៅជ្រុងខាងត្បូងនៃបឹងដ៏ធំមួយដែលគាត់ទប់និងហើយតំបន់នេះធ្លាប់ទទួលរងនូវគ្រោះទឹកជំនន់ធំម្តងកាលពីដើមទសវត្សរ៍៩០ ។ តាម៉ុក គឺជាអតីតលេខាភូមិភាគនិរតីកាលពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយគាត់ជាបុគ្គលម្នាក់ដែលត្រូវបានគេខ្លបខ្លាចដោយសារតែផែនការបន្សុទ្ធកម្មរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឥឡូវនេះ ផ្ទះរបស់ តាម៉ុក គឺជាសំណង់ដ៏ធំបំផុតនៃទីតាំងរដ្ឋាភិបាលចុងក្រោយរបស់ខ្មែរក្រហម ។ នៅក្នុងផ្ទះនោះមានជញ្ជាំងដែលមានគំនូរនៅពីលើនោះមានសរសរធំៗជាច្រើនដែលយកដើមឈើទាំងមូលនិងមានដើមស្វាយជាច្រើនដើម ។ នៅពីមុខផ្ទះនោះមានទ្រុងដែកមួយដែល តាម៉ុក ប្រើប្រាស់ដើម្បីឃុំខ្លួនខ្មាំងដែលក្រុមរបស់គាត់ចាប់ខ្លួនបាននិងសម្រាប់ឃុំខ្លួនជនណាដែលគាត់បានចាត់ទុកថាជាសត្រូវដែលបានប្រព្រឹត្តិខុសធ្ងន់ធ្ងរដូចជា លក់អាវុធឲ្យទៅខ្មាំង អំពើលួចប្លន់ អំពើលួចលាក់ប្តីប្រពន្ធ និងអ្នកដែលបង្កភាពវឹកវរជាដើម ។

ដោយសារអន្លង់វែងគឺជាតំបន់ខ្មែរក្រហមចុងក្រោយបង្អស់តំបន់នោះក៏ឃើញមានឃ្លាំងផ្ទុកអាវុធ ផ្ទះរបស់ ប៉ុល ពត,

សុន សេន, នួន ជា, ខៀវ សំផន, កែ ពក និងផ្ទះរបស់មេដឹកនាំផ្សេងទៀតដែរ ។ ផ្ទះទាំងនោះគឺជាផ្ទះតូចៗសង់ពីឈើដែលមកដល់ឥឡូវនេះមានទំហំតូចបើប្រៀបធៀបទៅនិងផ្ទះរបស់អ្នកភូមិនៅតំបន់អន្លង់វែងដែលផ្ទះទាំងអស់នោះចាប់ផ្ដើមកសាងឡើងតាំងពីដើមទសវត្សរ៍ឆ្នាំ២០០០ក្រោយពីតំបន់អន្លង់វែងទាំងមូលចាប់ផ្ដើមសមាហរណកម្មជាមួយរដ្ឋាភិបាលក្នុងឆ្នាំ១៩៩៨ ។ អន្លង់វែងមានស្ពានជាច្រើន មានទំនប់មួយ មន្ទីរពេទ្យមួយ សាលារៀនមួយនិងផ្លូវជាច្រើនដែលសមិទ្ធផលទាំងអស់នោះត្រូវបានកសាងដោយតាម៉ុក ។ ក្នុងនោះមានកន្លែងមួយដែល ប៉ុល ពត ត្រូវបានកាត់ទោសដោយ តាម៉ុក ក្រោយពីការតស៊ូនយោបាយនាដំណាក់កាលចុងក្រោយរបស់ខ្មែរក្រហម ។ ក្នុងនាមជាអតីតតំបន់រដ្ឋបាលមួយរបស់ខ្មែរក្រហម អន្លង់វែងក៏មានទីតាំងសម្ងាប់និងជំរំអប់រំកែប្រែដែរ ។ ក្នុងនាមជាអតីតសមរភូមិប្រយុទ្ធ និងតំបន់ការពារដ៏រឹងមាំមួយរបស់ខ្មែរក្រហម តំបន់អន្លង់វែងហ៊ុមព័ទ្ធទៅដោយគ្រាប់មីន ។ មីនខ្លះត្រូវបានសម្អាតដោយក្រុមដោះមីនជាតិនិងអន្តរជាតិនិងដោយសារអ្នកភូមិនិងអតីតកម្មាភិបាលខ្មែរក្រហមដែលបានបម្រើមនោគមន៍វិជ្ជាខ្មែរក្រហមអស់រយៈពេលយ៉ាងយូរតែអ្នកទាំងនោះបានដោះមីនដោយខ្លួនឯងដើម្បីយកដីនោះមកធ្វើជាកម្មសិទ្ធផ្ទាល់ខ្លួនដើម្បីប្រកបរបរចិញ្ចឹមជីវិត ។

ឥឡូវនេះ តំបន់អន្លង់វែងមានសន្តិភាពហើយ ។ អ្នកស្រុកអន្លង់វែងនិងអ្នកមកពីចម្ងាយសុទ្ធតែមានអារម្មណ៍ចង់មានចង់បានពេលដែលមកដល់ទីនេះបន្ទាប់ពីសង្គ្រាម ។ គោលនយោបាយកណ្ដាប់ដៃដែករបស់ខ្មែរក្រហមបានវិនាសសូន្យសុងហើយ មិនត្រឹមតែរូបរាងទេ សូម្បីតែមនោគមន៍វិជ្ជារបស់ខ្មែរក្រហមក៏គ្មាននរណាអនុវត្តទៀតដែរ ។ អតីតកម្មាភិបាលថ្នាក់ទាបដែលធ្លាប់មានអំណាចតិចតួចនិងអ្នកភូមិផ្សេងទៀតកំពុងតែរស់នៅក្នុងតំបន់អន្លង់វែងនេះ តែថ្នាក់ដឹកនាំថ្នាក់ធំនិងថ្នាក់ដឹកនាំកំពូលមិនមានវត្តមានទេ ភាគច្រើនអ្នកទាំងនោះបានស្លាប់ដោយសារជំងឺនិងត្រូវបានចាប់ខ្លួនដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្ដីខ្មែរក្រហម ។ មេដឹកនាំដែលមានអំណាចតិចតួចទាំងនោះមានចរិកលក្ខណៈខុសពីប្រជាជនដែលបានរួមរស់ជាមួយរដ្ឋាភិបាលកម្ពុជា ហើយមេដឹកនាំទាំងនោះមានចិត្តរីករាយដែលបានផ្លាស់ប្ដូរនិងរស់នៅតាមបែបផែនជីវិតមានសេរីភាពនិងអាចលើកម្ពស់ជីវភាពលើសពីពេលដែលអ្នកទាំងនោះធ្លាប់នៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម ។ កាលពីដើមទសវត្សរ៍ឆ្នាំ២០០០សេដ្ឋកិច្ចតំបន់អន្លង់វែងបានរីកចម្រើនយ៉ាងខ្លាំងដោយសារតែតម្លៃដីឡើងថ្លៃខ្លាំងនិងស្របពេលដែលផ្លូវថ្នល់ត្រូវបានសាងសង់ដើម្បីភ្ជាប់ពីទីរួមស្រុកអន្លង់វែងទៅកាន់តំបន់ផ្សេងទៀតទូទាំងប្រទេសជាពិសេសផ្លូវភ្ជាប់ទៅកាន់ទីរួមខេត្តសៀមរាប និងខេត្តព្រះវិហារ ។ អន្លង់វែងមានព្រៃឈើយ៉ាងក្រាសនិងមានព្រៃធម្មជាតិជាច្រើនដែលអ្នកស្រុកអន្លង់វែងអាស្រ័យផលដើម្បីជីវភាពរស់នៅប្រចាំថ្ងៃ ។ នាពេលបច្ចុប្បន្ននេះ អ្នកស្រុកអន្លង់វែងប្រកបរបរដាំដំឡូង និងធ្វើស្រែនៅរដូវវស្សា និងដាំបន្លែតាមរដូវកាលផ្សេងទៀតដូចជាឪឡឹកត្រសក់ បន្លែ ល្ង និងសណ្ដែកដី ព្រមទាំងបន្លែផ្សេងទៀត ។

ដោយសារតែមានដីគ្រប់គ្រាន់សម្រាប់បង្កបង្កើនផល អ្នកស្រុកអន្លង់វែងហាក់បីដូចជាមានជីវភាពប្រសើរជាងប្រជាជនកម្ពុជានៅតំបន់ផ្សេងទៀតក្នុងប្រទេស ។ មានរង្វង់មូលមួយនៅចំកណ្ដាលទីប្រជុំជននៃស្រុកអន្លង់វែងដោយមានផ្ទះសង់នៅជុំវិញរង្វង់មូលនោះ រួមទាំងផ្ទះសំណាក់ ខារ៉ាអូខេ និងហាងម៉ាស្សាព្រោងព្រាត ។ តំបន់អន្លង់វែងមានសភាពខុសប្លែកកាលពីតំបន់នេះពេលគ្រប់គ្រងដោយ តាម៉ុក ដែលកាលនោះមានតែហាងលក់មួយចំនួនប៉ុណ្ណោះសម្រាប់លក់ឲ្យអ្នកភូមិ ហើយកាលពីជំនាន់នោះមានតែផ្ទះឈើតូចៗនិងការិយាល័យរដ្ឋបាលនានាដែលសាងសង់ពីឈើ ។ ដំបូងឡើយ ទីប្រជុំជនអន្លង់វែងមានទីតាំងនៅភាគខាងត្បូងនៃទីតាំងសព្វថ្ងៃ ហើយកាលនោះ អន្លង់វែងគឺជាភូមិតូចមួយហ៊ុមព័ទ្ធទៅដោយព្រៃដ៏ក្រាស់ដែលគ្មាននរណាអាចចូលទៅបាន ។ អ្នកស្រុកអន្លង់វែងដែលធ្លាប់រស់នៅតំបន់នេះជាយូរមកហើយ បាននិយាយថា ព្រៃនេះធ្លាប់ជាជម្រកសត្វព្រៃជាច្រើនប្រភេទ ដូចជា ពពួកដំរី ក្របីព្រៃ ប្រើស និងខ្លា ជាដើម ។ នៅពេលដែលខ្មែរក្រហមកាន់តែច្រើនឡើងមករស់នៅតំបន់នេះ ខ្មែរក្រហមក៏មិនកសាងសំណង់អ្វីច្រើនដែរ ព្រោះទីនេះគឺជាសមរភូមិប្រយុទ្ធដែលតែងតែបោះបង់ចោលជាប្រចាំ ។

សព្វថ្ងៃ ទីប្រជុំជនអន្លង់វែងមានផ្ទះនិងហាងលក់ទំនិញជាច្រើនដែលជាកម្មសិទ្ធរបស់អតីតកម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហម



ខ្នងទំនប់នៅភូមិទំនប់ថ្មី ឃុំត្រពាំងតាវ ដែលកសាងឡើងដោយ តាម៉ុក



ទំនប់អូរជីក នៅក្បែរផ្ទះរបស់ តាម៉ុក

ក្នុងនោះកូនម្នាក់របស់ ខៀវ សំផន គឺជាម្ចាស់ស្ថានីយសាំងមួយនៅជិតវង្វង់មូល ។ កូនរបស់អតីតមេដឹកនាំខ្មែរក្រហមមិនបានប្រកបកិច្ចការជំនួយនិងមានជីវភាពប្រចាំថ្ងៃប្រសើរប៉ុន្មានទេ ដោយសារតែឪពុករបស់ខ្លួនដែលធ្លាប់ជាជនកុម្មុយនីស្តដ៏ស្វិតស្វាញមិនបានបន្សល់កេរដំណែលអ្វីដល់កូនរបស់ខ្លួនទេមុននិងស្លាប់ ។

កាលពីដើមទសវត្សរ៍៩០ ក្រោយពីតំបន់ខ្មែរក្រហមជាច្រើនត្រូវបានរដ្ឋាភិបាលវាយដណ្តើមយកបានឬកន្លែងខ្លះទៀតបានចុះចូលជាមួយរដ្ឋាភិបាល មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ជាច្រើននាក់បានផ្លាស់មកនៅអន្លង់វែងដែលធ្វើឲ្យអន្លង់វែងក្លាយជាតំបន់មួយដែលសុទ្ធតែអតីតមេដឹកនាំខ្មែរក្រហមរស់នៅ ។ ដូច្នេះតំបន់អន្លង់វែងនេះផ្តល់អំណោយផលយ៉ាងល្អដល់ការសិក្សាអំពីថ្នាក់ដឹកនាំ រដ្ឋបាលនិងរចនាសម្ព័ន្ធដឹកនាំរបស់ខ្មែរក្រហមដើម្បីឲ្យដឹងអំពីបែបផែននៃការគ្រប់គ្រងនិងការកសាងនិរន្តរភាពអស់រយៈពេលជាច្រើនឆ្នាំនៃការស្វែងរកជំនួយសព្វាវុធ ការគ្រប់គ្រងប្រជាជននិងការវាយប្រយុទ្ធក្នុងសមរភូមិ ។

ការសិក្សាអំពីស្ថានភាពរស់នៅរបស់ប្រជាជនសាមញ្ញក៏ជាប្រធានបទមួយសំខាន់ដែរដើម្បីឲ្យដឹងថាតើប្រជាជនអន្លង់វែងរស់នៅបែបណា ចិញ្ចឹមកូនដោយវិធីណា រស់នៅដោយប្រថុយប្រថានបែបណាអំឡុងពេលសង្គ្រាម ហើយថាអ្នកស្រុកអន្លង់វែងចាត់ទុកមេដឹកនាំខ្មែរក្រហមបែបណា និងតើអ្នកស្រុកអន្លង់វែងចាត់ទុកខ្លួនឯងយ៉ាងដូចម្តេច និងតើអ្នកស្រុកអន្លង់វែងចង់បានអ្វីនៅថ្ងៃអនាគត ។

ខ្ញុំបានជួបជាមួយអ្នកស្រុកអន្លង់វែងជាច្រើនគ្រួសារដែលបានមករស់នៅតំបន់នេះតាំងពីដើមទសវត្សរ៍៩០ឬមុននោះទៀតដើម្បីនិយាយទៅកាន់អ្នកស្រុកអំពីទស្សនៈក្នុងនាមជាប្រជាជនសាមញ្ញដែលកំពុងរស់នៅតំបន់អន្លង់វែងនេះ ។ នេះគឺជាផ្នែកមួយនៃគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការសិក្សាឲ្យបានលម្អិតពីតំបន់អន្លង់វែងដោយសហការជាមួយក្រសួងទេសចរណ៍ ។

## ជា អ៊ឹម

ជា អ៊ឹម គឺជាស្ត្រីម្នាក់វ័យ៦៥ឆ្នាំមានស្រុកកំណើតនៅស្រុកត្រាំកក់ ខេត្តតាកែវ ។ គាត់បានចូលជាមួយចលនាខ្មែរក្រហមក្នុងឆ្នាំ១៩៧៣និងបានធ្វើការនៅស្រុកត្រាំកក់ទូទាំងរបប



កម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់១៩៧៩ ។ ក្នុងឆ្នាំ១៩៧៩ គាត់បានភៀសខ្លួនទៅនៅព្រំដែនថៃនិងរស់នៅជំរំខាវអ៊ីដាងប្រទេសថៃ ។ គាត់បានស្នាក់នៅទីនោះពេញមួយទសវត្សរ៍៨០ ។ គាត់និងគ្រួសាររបស់គាត់ធ្វើមាតុភូមិនិវត្តិមកកាន់ស្រុកកំណើតឯស្រុកត្រាំកក់វិញក្នុងឆ្នាំ១៩៩១ ដែលពេលនោះគ្រួសាររបស់គាត់ត្រូវបានអង្គការផ្តល់ដីកន្ទះហិចតាដើម្បីបង្កបង្កើនផលសម្រាប់ចិញ្ចឹមកូនប្រាំពីរនាក់នៅក្នុងបន្ទុក ។ ក្រោយពីរស់នៅស្រុកកំណើតបានមួយឆ្នាំ អ៊ឹស្រី ជា អ៊ឹម សម្រេចចិត្តនាំគ្រួសារមករស់នៅអន្លង់វែងក្រោមការគ្រប់គ្រងរបស់ តាម៉ុក ។ អ៊ឹស្រី ជា អ៊ឹម មានប្អូនប្រុសពីរនាក់បើកបររថយន្តឲ្យ តាម៉ុក ហើយម្តាយរបស់គាត់រស់នៅក្នុងស្រុកអន្លង់វែងដែរនៅពេលនោះ ។ អ៊ឹស្រីបាននិយាយថា ប្អូនប្រុសរបស់គាត់បានសុំ តាម៉ុក ដើម្បីឲ្យគាត់មករស់នៅអន្លង់វែង ។ តាម៉ុក បានឆ្លើយថា "មិនជាស្អីទេ! ឲ្យគាត់មកនៅទីនេះមក" ។ អ៊ឹស្រីបាននិយាយថា តាម៉ុក បានឆ្លើយភ្លាមៗនិងដោយសម្តីស្រទន់ពេលដែលប្អូនប្រុសរបស់គាត់ស្នើសុំទៅគាត់ ។ តាម៉ុក បានផ្ញើលុយឲ្យគាត់ចំនួនមួយពាន់បាតថៃដើម្បីឲ្យអ៊ឹស្រីនិងក្រុមគ្រួសាររបស់គាត់ធ្វើដំណើរមកអន្លង់វែង ។ កាលនោះ ក៏មានកិញខ្មែរក្រហមនៅស្រុកត្រាំកក់ដែរដែលប្រាប់អ៊ឹស្រីអំពីការរៀបចំកន្លែងរស់នៅនិងនាំគាត់មករស់នៅអន្លង់វែងដោយឆ្លងកាត់សមរភូមិប្រយុទ្ធជាច្រើនមុននិងទៅដល់តំបន់អន្លង់វែង ។ អ៊ឹស្រីបានមកដល់អន្លង់វែងដោយជោគជ័យ ។ គាត់បាននិយាយថា ពេលនោះការធ្វើដំណើរឆ្លងកាត់សមរភូមិមិនជាពិបាកប៉ុន្មានទេ ។ ពេលមកដល់អន្លង់វែង តាម៉ុក បានឲ្យលុយប្រាំរយបាតទៀតដើម្បីឲ្យគាត់

មានដើមទុនចិញ្ចឹមជីវិត ។ អ៊ឹ ស្រី បានយកលុយនោះទៅទិញឆ្នាំងបាយ ឆ្នាំងសម្ល ខ្ទះ និងរបស់របរសម្រាប់ដាំផ្ទះពីហាងលក់ដែលជាកម្មសិទ្ធរបស់កម្មាភិបាលខ្មែរក្រហមនិងអ្នកលក់ដែលជាជនជាតិថៃ ។ អ៊ឹ ស្រីទទួលបានដីមួយកន្លែងហើយគាត់បានកាប់ឈើក្នុងព្រៃដើម្បីយកមកធ្វើផ្ទះនៅលើដីនោះ ។

ពេលដែលគាត់រស់នៅអន្លង់វែង អ៊ឹ ស្រី បាននិយាយថា គាត់បានចាកចេញពីផ្ទះពីរបីដងដែរ ។ ពេលមួយនោះ ផ្ទះរបស់គាត់ត្រូវបានដុតបំផ្លាញដោយទាហានខ្មែរក្រហមដើម្បីកុំឲ្យទ័ពរបស់រដ្ឋាបាល "បង្កើតមូលដ្ឋានរឹងមាំ" នៅទីនោះបាន ។ មាន់និងជ្រូករបស់គាត់ត្រូវបានទ័ពរដ្ឋាភិបាលចាប់យកអស់ ។ ពេលដែលគាត់ត្រឡប់មកវិញ គាត់ត្រូវតែសង់ផ្ទះថ្មីដើម្បីនៅ ។ បទពិសោធន៍នេះជំរុញឲ្យគាត់រស់នៅជាលក្ខណៈមិនមានទីតាំងច្បាស់លាស់ក្រោមការដឹកនាំរបស់ តាម៉ុក ។ អ៊ឹ ស្រីមិនអាចបង្កបង្កើនផលទៀតទេ ហើយក៏ឈប់ផ្ទុកស្រូវក្នុងក្រង់ច្រើនដូចមុនទៀតដែរ ហើយក៏ឈប់ចិញ្ចឹមសត្វទៀតដែរ ។

អ៊ឹ ស្រី ជា អ៊ឹម បាននិយាយថា ទោះបីជាគាត់រស់នៅដោយផ្លាស់ប្តូរពីកន្លែងមួយទៅកន្លែងមួយក៏ដោយ ក៏គាត់រីករាយពេញចិត្តនិងផ្លាស់ប្តូរទីលំនៅពីត្រាំកក់មកអន្លង់វែង ។ តាម៉ុក គឺជាមនុស្សល្អនិងចិត្តល្អម្នាក់ ។ ពេលនេះកូនរបស់អ៊ឹ ស្រីមានដីជាងមួយហិចតាក្នុងម្នាក់ដែលដីនោះកូនៗរបស់គាត់អាចធ្វើស្រែនិងដាំបន្លែបង្កាផ្សេងៗដើម្បីចិញ្ចឹមជីវិត ។ ខ្មែរក្រហមដែលបានរស់នៅតំបន់អន្លង់វែងមុននិងគាត់មករស់នៅមិនដែលរើសអើងនិងគាត់ដែលជាអ្នកចំណូលថ្មីទេ ។ កាលពីនៅត្រាំកក់ គាត់មានដីតែកន្លះហិចតាប៉ុណ្ណោះ ហើយមិនគ្រប់គ្រាន់សម្រាប់បង្កបង្កើនផលដើម្បីចិញ្ចឹមជីវិតទេ ។ គាត់បានឲ្យដីនោះទៅឲ្យពូរបស់គាត់មុនពេលគាត់មកអន្លង់វែង ។

## ជា ផល

ជា ផល មានកំណើតកើតជានៅស្រុកត្រាំកក់ ខេត្តតាកែវ ។ ពេលនេះគាត់មានអាយុ៥២ឆ្នាំ ។ គាត់បានរៀបការជាមួយប្តីរបស់គាត់ក្នុងឆ្នាំ១៩៨០ ឈ្មោះ ឈឹម ផុន ពេលនេះមានអាយុ៥៣ឆ្នាំ ។ អ្នកទាំងពីរមានកូនពីរនាក់ ។ ពិធីរៀបការរបស់គាត់ត្រូវបានរៀបចំដោយខ្មែរក្រហមដោយក្នុងពិធីនោះមានច្រាំគូ ផ្សេងទៀត ។ សព្វថ្ងៃ ប្តីរបស់គាត់ពិការដៃស្តាំម្ខាងក្រោយពីត្រូវគ្រាប់កាំភ្លើងពេលដែលគាត់កំពុងឡើងភ្នំជាមួយទាហានខ្មែរក្រហមផ្សេងទៀតក្នុងឆ្នាំ១៩៧៩ ។ ដៃដែលត្រូវរបួសបានជារលួយអស់រយៈពេលជាច្រើនសប្តាហ៍មុននិងធ្វើដំណើរទៅដល់មន្ទីរពេទ្យខ្មែរក្រហម ។ ឆ្អឹងកំភួនដៃរបស់គាត់មិនអាចបណ្តុះឆ្អឹងបានទេ ។



ក្នុងឆ្នាំ១៩៧៤ ជា ផល បានចាកចេញពីផ្ទះដើម្បីបម្រើបដិវត្តន៍ក្រោយពីមានការបញ្ចុះបញ្ចូលនិងអូសទាញពីមេភូមិ ។ គាត់ត្រូវបានចាត់តាំងឲ្យធ្វើជានិរសារឲ្យសាលាឃុំ ហើយក្រោយមកក្នុងឆ្នាំ១៩៧៥ គាត់ចាត់តាំងឲ្យធ្វើជានារីពេទ្យនៅមន្ទីរពេទ្យ១៧ មេសា "បច្ចុប្បន្នពេទ្យរុស្ស៊ី" ។ មីង ផល បាននិយាយថា ពេទ្យរបស់គាត់ប្រើប្រាស់ថ្នាំបុរាណផង និងថ្នាំសម័យផង ។

មីង ផល ចេះពីវិធីធ្វើអាលកុលនិងថ្នាំដើម្បីព្យាបាលជម្ងឺឈឺក្បាល រាគ និងគ្រុនក្តៅ ។ មីងបាននិយាយថា របៀបធ្វើអាលកុលគឺធ្វើតាមធាតុផ្សំមួយចំនួនដូចជា ៈ ស្កត្នោត ដើមរំដេង វល្លិ៍ឈើឯម និងស្លឹកឫស្សី ។ ដំបូង ត្រូវបុកគ្រឿងទាំងនោះជាមួយគ្នា ហើយក្រោយមកចាក់ទឹកចូល រួចលាយច្របល់គ្នា និងត្រាំទុកប្រហែលជាមួយអាទិត្យរហូតវាក្លាយជាមេ ។ ក្រោយពីទឹកពុះហើយ ចំហាយនោះបង្កើតទៅជាអាលកុល ។ មីង ផល បាននិយាយថា គាត់ត្រូវសាកល្បងមើលថា តើអាល់កុលនោះសុទ្ធឬអត់តាមរយៈចាក់អាល់កុលនោះមួយស្លាបព្រាចូលក្នុងភ្លើង ។ បើសិនជាសុទ្ធ អាកុលនិងឆាបឆេះ ។

ថ្នាំឈឺក្បាលគឺធ្វើពីម្សៅក្តួច ទឹកក្រូចឆ្មា និងសារធាតុគីមីមួយប្រភេទទៀត ។ ថ្នាំរាគធ្វើពីដើមកន្ទួលដោយដាំទឹកឲ្យពុះ ។

ក្រោយពីដាំទឹកពុះហើយ ត្រូវយកទឹកនោះទៅលាយជាមួយម្សៅក្តួច រួចមូរឲ្យទៅជាគ្រាប់ថ្នាំ ។ ថ្នាំគ្រុនក្តៅធ្វើពីវល្លិ៍បណ្តូលពេជ្រដំណាប់ស្ពៃនិងទឹក ។

ក្នុងខែមករា ឆ្នាំ១៩៧៩ គាត់បានជិះរថភ្លើងទៅខេត្តបាត់ដំបង រួចជិះរថយន្តធំទៅស្រុកសំឡូត ។ ក្រោយពីធ្វើដំណើរពីភូមិមួយទៅភូមិមួយ គាត់បានទៅដល់ជំរំភៀសខ្លួនក្នុងព្រៃក្នុងទឹកដីថៃជិតខេត្តកោះកុង ។ ដោយសារតែគាត់ជាអតីតនារីពេទ្យ ក្រោយមកខ្មែរក្រហមបាននាំគាត់ទៅបន្ទាយយោធារបស់ខ្មែរក្រហមជាច្រើនដងនៅត្រង់ចំណុច៨០៨នៅលើភ្នំដងរែក ។ នៅទីនោះ ខ្មែរក្រហមបានបង្កើតមន្ទីរពេទ្យចល័តមួយដើម្បីព្យាបាលអ្នករងរបួសនិងអ្នកជំងឺ ។ ក្រោយមក គាត់ត្រូវបានបញ្ជូនទៅចំណុច១០០៣ដែលមានចម្ងាយប្រហែលជាដប់ប្រាំគីឡូម៉ែត្រពីច្រកជាំស្រង៉ាំ ។ ក្នុងឆ្នាំ១៩៩០ គាត់បានផ្លាស់ទៅនៅភូមិលំទងចាស់វិញ ។ ក្នុងឆ្នាំ១៩៩៨ គាត់ប្តូរទៅនៅជំរំហ៊ួណ្ហយវិញមុនប្តូរទៅរស់នៅភូមិអូរគគីរ ឃុំលំទង ស្រុកអន្លង់វែង ។

មីង ផល បាននិយាយថា ពេលគាត់នៅអន្លង់វែងកាលនោះ គាត់មានអាហារហូបចុកគ្រប់គ្រាន់ ។ គាត់ត្បាញកន្ទេលកក់ដើម្បីលក់ឲ្យប្រជាជនថៃនៅព្រំដែន ហើយគាត់បានសន្សំលុយបានមួយម៉ឺនប្រាំពីរពាន់បាត តែគាត់បានចាយលុយអស់ហើយពេលដែលគាត់រស់នៅជំរំហ៊ួណ្ហយក្នុងឆ្នាំ១៩៩៨ ។ គាត់គិតថា តាម៉ុក គឺជាមនុស្សល្អម្នាក់ ។ តាម៉ុក ធ្លាប់ស្រែកគំហកនិងជេរអ្នកនៅក្រោមបង្គាប់របស់គាត់តែគាត់តែងតែផ្តល់ម្ហូបអាហារដល់អ្នកទាំងនោះជានិច្ច ។ ពេលមានជម្លោះប្រដាប់អាវុធក្នុងឆ្នាំ១៩៩៧ មីង ផល បាននិយាយថា គាត់ខ្លាចមានគ្រោះថ្នាក់ដល់ជីវិត ។ អ្នកណាក៏ខ្លាចគ្រោះថ្នាក់ដល់ជីវិតដែរព្រោះមេបញ្ជាការខ្មែរក្រហមបានតម្រង់កាំភ្លើងដាក់គ្នា ។

នៅពេលឆ្លុះបញ្ចាំងពីលទ្ធផលនៃការចូលរួមពាក់ព័ន្ធនិងការតស៊ូទាំងអម្បាមានជាមួយខ្មែរក្រហម មីង ផល បាននិយាយថា ក្រោយពីតស៊ូនិងរស់នៅក្នុងព្រៃអស់រយៈពេល២៥ឆ្នាំ អ្វីដែលគាត់ទទួលបានក្នុងឆ្នាំ១៩៩៩គឺមានតែបាតដៃទទេ ។ ប្តីរបស់គាត់ពិការហើយគាត់និងប្តីរបស់គាត់មានវ័យកាន់តែចាស់ហើយដែលជាហេតុធ្វើឲ្យមានការលំបាកក្នុងការកសាងជីវិតថ្មីណាស់ ។ មីង ផល បាននិយាយថា វាជាការលំបាកណាស់សម្រាប់គាត់ដែលធ្លាប់នៅរស់ដោយទទួលរបបអាហារអស់រយៈពេលជាច្រើនឆ្នាំហើយ ក្រោយមក គាត់បានប្រកបរបរដើម្បីចិញ្ចឹមជីវិតខ្លួនឯង ។ មីង ផល បាននិយាយទៀតថា ជីវភាពរបស់គាត់ទើបតែកើនឡើងនៅដើមឆ្នាំ២០០០នេះទេ នៅពេលដែលតម្លៃដីនៅអន្លង់វែងឡើងថ្លៃបន្តិច ។ គាត់បានលក់ដីរបស់គាត់មួយផ្នែក ហើយបានយកលុយនៅសង់ផ្ទះមួយខ្នងក្នុងឆ្នាំ២០០៧ ។ ប្តីរបស់មីង ផល បានឈប់ធ្វើទាហាន រួចមកធ្វើស្រែវិញក្នុងឆ្នាំ១៩៩៩ព្រោះតែខឹងនិងខ្មែរក្រហមដែលមិនបានផ្តល់លទ្ធផលអ្វីសោះ ។ ហើយពេលនេះគ្រួសាររបស់មីង ផល ក៏មិនទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ជនពិការដែរ ។ មីង ផល និយាយថា ប្តីរបស់គាត់ចង់ផ្តាច់ខ្លួនចេញពីខ្មែរក្រហមជាច្រើនលើកច្រើនសារហើយ តែគាត់មិនអាចយកគ្រួសារចេញពីតំបន់ខ្មែរក្រហម ។

## ហៀម យឿន



ហៀម យឿន មានស្រុកកំណើតនៅភូមិត្នោតជ្រុំ ឃុំដូនកែវ ស្រុកពួក ខេត្តសៀមរាប ។ ពេលនេះ មីង យឿន មានអាយុ៤៧ឆ្នាំ និងរស់នៅជាមួយប្តីទីពីររបស់គាត់ឈ្មោះ ក្រេន ការ៉េ ។ អ្នកទាំងពីរមានកូនពីរនាក់ ។ ប្តីរបស់គាត់ពិការដៃឆ្វេងនាចុងទសវត្សរ៍៨០ នៅពេលដែលគាត់ព្យាយាមដោះកឹមគ្រាប់មីន ។ ពូ ការ៉េ បាននិយាយដោយសាមញ្ញថា កាលនោះគាត់មិនទាន់មានជំនាញដោះកឹបគ្រាប់មីននៅឡើយទេ ។ ដោយសារពិការដៃម្ខាង ពូ ការ៉េ មានការលំបាកខ្លះក្នុងការបង្កបង្កើនផល ហើយដោយសារមិនមានកូនច្រើនផង គ្រួសាររបស់គាត់ត្រូវតែជួលអ្នកភូមិឲ្យជួយភ្ជួរស្រែ

ស្ងួន និងប្រួតកាត់ ។ ចំណែកឯមីង យឿន វិញ ក៏មិនសូវជាមានកម្លាំងកំហែងប៉ុន្មានដែរ ។ គាត់មានសុខភាពខ្សោយដោយសារតែគាត់មានជំងឺរបេងរ៉ាំរ៉ៃជាយូរមកហើយ ។ គាត់មិនអាចធ្វើការបានយូរទេ ។ ប្តីទីមួយរបស់គាត់គឺជាទាហានដែលបានស្លាប់ពេលប្រយុទ្ធគ្នានៅស្រុកអង្គរជុំ ខេត្តសៀមរាប ។

កាលពីជំនាន់ខ្មែរក្រហម មីង យឿន គឺជាកុមារីម្នាក់ ។ ឪពុករបស់គាត់ស្លាប់ដោយសារជំងឺក្នុងឆ្នាំ១៩៧៥ ។ ម្តាយរបស់គាត់ស្លាប់ក្នុងឆ្នាំ១៩៨២ ដែលកាលនោះ មីង យឿន មានអាយុត្រឹម១២ឆ្នាំប៉ុណ្ណោះ ។ គាត់មានប្អូនប្រុសម្នាក់ទៀតឈ្មោះ ហៀម លឿន ដែលពេលនេះមានអាយុ៤៤ឆ្នាំ ។ លឿន បានចូលធ្វើទាហាននាពាក់កណ្តាលទសវត្សរ៍៨០ ។ ចំណែកឯមីង យឿនវិញមិនដែលធ្វើជាកម្មាភិបាលខ្មែរក្រហមទេតាំងពីមុនមក ។

ក្នុងឆ្នាំ១៩៩១ មីង យឿន បានសម្រេចចិត្តចូលមកស្វែងរកប្អូនប្រុសរបស់គាត់នៅក្នុងទឹកដីរបស់ខ្មែរក្រហម ។ មីង យឿន និយាយថា គាត់នឹកប្អូនប្រុសរបស់គាត់ខ្លាំងណាស់ ហើយកាលនោះគាត់ដឹងថាប្អូនប្រុសរបស់គាត់រស់នៅអន្លង់វែង ។ ក្រោយពីដូច្នេះ មីង យឿន បានសម្រេចចិត្តធ្វើដំណើរមកអន្លង់វែងដើម្បីស្វែងរកប្អូនប្រុសរបស់គាត់ ។ គាត់បានដើរកាត់តំបន់ត្រួតពិនិត្យរបស់ខ្មែរក្រហមជាច្រើនកន្លែង ហើយទាហានខ្មែរក្រហមបានសួរគាត់ជាច្រើនសំនួរតែពេលដែលគាត់ប្រាប់ទៅទាហានខ្មែរក្រហមនោះថាគាត់កំពុងស្វែងរកប្អូនប្រុសរបស់គាត់ដែលធ្វើទាហានខ្មែរក្រហមដែរនោះ ទាហានទាំងនោះក៏អនុញ្ញាតឲ្យគាត់ធ្វើដំណើរទៅមុខទៀត ។ ពេលធ្វើដំណើរកាន់តែជិតដល់អន្លង់វែង គាត់បានជួបប្រទះមនុស្សមួយក្រុមទៀតដែលមានគ្នាពីរបីនាក់ ហើយមីង យឿន ក៏ដើរទៅជាមួយក្រុមនោះដែរ ។ ពេលគាត់មកដល់អន្លង់វែងគាត់បានជួបប្អូនប្រុសរបស់គាត់ភ្លាមសមដូចបំណងដែលកាលនោះប្អូនប្រុសរបស់គាត់កំពុងរស់នៅជាមួយមេបញ្ជាការរបស់គាត់នៅក្នុងទីបញ្ជាការក្បែរសាលាស្រុកអន្លង់វែងសព្វថ្ងៃ ។ ពេលដែលបានជួបភ្លាម មីង យឿន យំយ៉ាងខ្លាំង តែប្អូនប្រុសរបស់គាត់មិនយំទេ តែគាត់មានអារម្មណ៍រំជួលចិត្តយ៉ាងខ្លាំង ។

មីង យឿន បន្តនៅបម្រើមេបញ្ជាការរបស់ប្អូនប្រុសរបស់គាត់និងរស់នៅជាមួយប្អូនរបស់គាត់នៅផ្ទះរបស់មេបញ្ជាការនោះ ។ គាត់ជួយធ្វើស្រែនិងកិច្ចការផ្សេងទៀត ។ ប្អូនប្រុសរបស់គាត់ផ្តាច់ខ្លួនមកចូលជាមួយរដ្ឋាភិបាលក្នុងអំឡុងឆ្នាំ១៩៩៣ឬ ១៩៩៤ពេលដែលគាត់ត្រូវបានបញ្ជូនទៅចុះបេសកកម្មនៅខេត្តសៀមរាប ។ កាលនោះគាត់ផ្តាច់ខ្លួនចូលជាមួយរដ្ឋាភិបាលតែម្នាក់ប៉ុណ្ណោះ ។ មីង យឿន មិនដឹងថា ប្អូនប្រុសរបស់គាត់ផ្តាច់ខ្លួនទេ ហើយក៏គ្មាននរណាប្រាប់គាត់ដែរ ។ នៅពេលដែលគាត់ទៅសួរអំពីដំណឹងរបស់ប្អូនប្រុសគាត់ទើបមានគេប្រាប់ថា ប្អូនប្រុសរបស់គាត់បានផ្តាច់ខ្លួនបាត់ទៅហើយ ។ តែការផ្តាច់ខ្លួនរបស់ប្អូនប្រុសរបស់គាត់មិនបង្កឲ្យមានទុក្ខទោសដល់មីង យឿន នៅអន្លង់វែងទេ ។ មីង យឿន មិនដែលត្រូវបានបញ្ជូនទៅភូមិទួលគ្រួសដោយសារតែជាមនុស្សប្រភេទទីពីរឡើយ ។ មីង យឿន បានផ្លាស់មកនៅភូមិករដែលគាត់កំពុងរស់នៅសព្វថ្ងៃនាពាក់កណ្តាលទសវត្សរ៍៩០ ។ ក្នុងអំឡុងពេលនៃការប្រយុទ្ធគ្នាក្នុងឆ្នាំ១៩៩៨ គាត់បានផ្លាស់ទៅនៅជំរំហ៊ូណ្វយក្បែរភ្នំជាមួយអ្នកផ្សេងទៀត ហើយបានត្រឡប់មកកាន់លំនៅដ្ឋានរបស់គាត់វិញក្នុងឆ្នាំ១៩៩៩ ។ ពេលគាត់ត្រឡប់មកវិញ គាត់ឃើញមានគ្រួសារមួយកំពុងរស់នៅក្នុងផ្ទះរបស់គាត់ ហើយមីង យឿន បង់លុយមួយចំនួនដល់គ្រួសារនោះដើម្បីឲ្យគ្រួសារនោះចេញពីផ្ទះរបស់គាត់ ។

មីង យឿន និយាយថា ក្នុងជំនាន់ តាម៉ុក គាត់មានអាហារហូបចុកគ្រប់គ្រាន់ ។ គាត់អាចធ្វើបុណ្យទានខ្លះៗ ។ គាត់ក៏បានត្បាញកន្ទេលដើម្បីលក់ឲ្យអ្នកជំនួញថៃដែរ ។ នៅពេលឲ្យគាត់ប្រៀបធៀបពីសម័យកាលក្រោមការគ្រប់គ្រងរបស់ តាម៉ុក និងសម័យកាលបច្ចុប្បន្ន មីង យឿន បាននិយាយថា សម័យបច្ចុប្បន្នមានភាពប្រសើរជាងសម័យ តាម៉ុក ឆ្ងាយណាស់ ។ ប្តីរបស់គាត់ក៏យល់ព្រមដូច្នេះដែរ ។ ទោះបីជាគ្រួសាររបស់គាត់កំពុងតែតស៊ូជាមួយនិងជីវភាពរស់នៅប្រចាំថ្ងៃ ហើយមើលទៅជីវភាពរស់នៅហាក់បីដូចជាមិនសូវធូរធារប៉ុន្មាន មីង យឿន បាននិយាយថា ស្ថានភាពរស់នៅពេលឥឡូវនេះមានការប្រសើរជាងកាលពីជំនាន់ តាម៉ុក ច្រើនណាស់ ។ ឥឡូវនេះ យើងមានសន្តិភាព មានផ្លូវច្រើនផ្សែងផ្សាត់ និងមានសេរីភាពច្រើន ។

***(នៅមានត)***

**អេង កុកថាយ**

# សិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមនៅអតីតតំបន់ខ្មែរក្រហម

ក្រោយឆ្នាំ១៩៧៩ ប្រទេសកម្ពុជាស្ទើរតែទាំងស្រុង បានរងនូវការបំផ្លិចបំផ្លាញដោយសាររបបខ្មែរក្រហមនិងសង្គ្រាមដែលនៅតែអូសបន្លាយ ។ ប្រជាជនខ្មែរដែលជាជនរងគ្រោះបានក្លាយទៅជាអ្នកមានជំងឺបាក់ស្បាត និងមានការប៉ះទង្គិចផ្លូវចិត្ត ដោយសារការបាត់បង់សមាជិកគ្រួសារ មនុស្សជាទីស្រឡាញ់ និងបទពិសោធន៍រស់នៅក្រោមរបបខ្មែរក្រហម ។ ទំនាក់ទំនងក្នុងចំណោមប្រជាជនខ្មែរនៅទូទាំងប្រទេស ជាពិសេស រវាងជនរងគ្រោះនិងជនដៃដល់ដែលជាអតីតកម្មាភិបាលខ្មែរក្រហមមិនអាចធ្វើឲ្យមានភាពធូរស្រាលនូវកំហឹងនិងការសងសឹកបានទេ ។ ទាំងជនរងគ្រោះ និងជនដៃដល់រស់នៅក្នុងភូមិនិងធ្វើការជាមួយគ្នា ។ កូនចៅរបស់ជនរងគ្រោះ និងជនដៃដល់ជាច្រើនបានសិក្សានៅតាមសាលារៀនជាមួយគ្នា ។ អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនតូចនៅតែមានជំនឿលើមេដឹកនាំរបស់ខ្លួនថាមិនបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរណាមួយនៅក្នុងអំឡុងពេលកាន់កាប់អំណាចនោះទេ ។ មានប្រជាជនខ្មែរជាច្រើនលាននាក់មានការយល់ឃើញខុសៗគ្នាអំពីរឿងរ៉ាវប្រវត្តិសាស្ត្រខ្មែរក្រហមដែលនាំឲ្យមានការលំបាកដើម្បីឈានទៅរកទស្សនៈរួមគ្នាលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដែលកើតមានឡើងនៅក្នុងអំឡុងរបបខ្មែរក្រហម ។

បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា ផ្នែកខ្លះនៃប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា នៅកម្រិតមធ្យមសិក្សាលើមុខវិជ្ជាប្រវត្តិវិទ្យា អក្សរសាស្ត្រខ្មែរ និង សីលធម៌-ពលរដ្ឋពីថ្នាក់៩ដល់ថ្នាក់ទី១២ដើម្បីឲ្យសិស្សានុសិស្សបានសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្ររបស់ខ្លួន ។ ជាការឆ្លើយតបទៅនឹងការបញ្ជ្រាបប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសម្ពោធពាក្យស្លោកទប់ស្កាត់អំពើប្រល័យពូជសាសន៍និងការចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាល័យអន្លង់វែងស្ថិតក្នុងស្រុកអន្លង់វែងដែលជាអតីតតំបន់តស៊ូចុងក្រោយរបស់ខ្មែរក្រហមកាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២ ។

ពិធីសម្ពោធពាក្យស្លោកនេះបានប្រព្រឹត្តិទៅក្រោមអធិបតីភាពរបស់លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការ



ពីឆ្វេងទៅស្តាំ អ៊ីង បូរ៉ាត់ (ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្តឧត្តរមានជ័យ), លោក យឹម ដាន់ណា (អភិបាលស្រុកអន្លង់វែង) និងលោកជំទាវ ទន់ សាអ៊ីម នៅក្នុងពីធីសម្ពោធពាក្យស្លោក

ក្រសួងអប់រំ យុវជន និងកីឡា, លោក វ៉ាន់ថាន់ ពៅដារ៉ា និងលោក អេង កុកថាយ នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា, លោក យឹម ដាន់ណាអភិបាលនៃគណៈអភិបាលស្រុកអន្លង់វែងនិងមានការអញ្ជើញចូលរួមពីលោកគ្រូ-អ្នកគ្រូ សិស្សានុ-សិស្ស និងប្រជាពលរដ្ឋដែលភាគច្រើនជាអតីតខ្មែរក្រហមប្រមាណជាងប្រាំមួយរយនាក់ ។ ថ្លែងទៅកាន់អ្នកចូលរួម លោកជំទាវមានប្រសាសន៍ថា "ការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជា

ប្រជាធិបតេយ្យនៅក្នុងកម្មវិធីសិក្សានៅតាមសាលារៀនគ្រាន់តែជាការសិក្សាមួយនិយាយដោយសង្ខេបនិងមានកម្រិតស្រាលនៅឡើយគឺមិនបានស៊ីជម្រៅដូចព្រឹត្តិការណ៍ដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហមទេ ។ ដូចនេះទាមទារឲ្យក្មួយៗដែលជាមនុស្សជំនាន់ក្រោយត្រូវខិតខំយកចិត្តទុកដាក់សិក្សាស្វែងយល់លម្អិតបន្ថែមទៀតដើម្បីពង្រឹងសមត្ថភាពចំណេះដឹងក្នុងការស្វែងយល់ពីជីវិតរស់នៅលំបាកវេទនានិងការឈឺចាប់ខ្លោចផ្សារបស់ប្រជាជនខ្មែរ» ។


លោកជំទាវ ទន់ សាអ៊ឹម

លោកជំទាវបានបន្ថែមថា «យើងគ្រប់គ្នាត្រូវតែសិក្សាពីប្រវត្តិសាស្ត្ររបស់ខ្លួនឲ្យបានច្បាស់លាស់ ។ ការសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រខ្លួនឯងមិនមែនមានន័យថាដើម្បីបំបែកបំបាក់គ្នានោះទេ គឺដើម្បីជាការទប់ស្កាត់និងជៀសវាងយកគំរូតាមបទពិសោធន៍មិនល្អ ហើយត្រូវយកអ្វីៗដែលជាបទពិសោធន៍ល្អៗសម្រាប់កសាងនិងអភិវឌ្ឍន៍ប្រទេសជាតិវិញ» ។ តាមរយៈការសិក្សានេះ លោកជំទាវបានរំពឹងទុកថាសិស្សានុសិស្សដែលជាមនុស្សជំនាន់ក្រោយនឹងមានលទ្ធភាពបណ្តុះខ្លួនឲ្យក្លាយទៅជាអ្នកសិក្សាស្រាវជ្រាវដើម្បីចងក្រងនិងថែរក្សាប្រវត្តិសាស្ត្រនេះសម្រាប់ក្មេងជំនាន់ក្រោយបន្តទៀត ។ ជាក់ស្តែងការបែកបាក់នៅក្នុងសង្គមខ្មែរគឺដោយសារតែមានឥទ្ធិពលនៃមនោគមវិជ្ជាបរទេសនិងការចោទប្រកាន់គ្នា ។ ទាំងនេះបានបង្ហាញថា ខ្មែរមានទស្សនយល់ឃើញផ្ទុយគ្នាទៅលើការដឹកនាំប្រទេសជាតិតាមវិធីសាស្ត្ររៀងៗខ្លួនដោយមិនបានផ្អែកទៅលើទស្សនរួមនោះទេ ។ ទាក់ទងទៅនឹងបញ្ហាខាងលើលោកជំទាវបានបញ្ជាក់ថា «សង្គ្រាមគឺមិនបានផ្តល់ការរីកចម្រើននៅក្នុងប្រទេសនោះទេ ។ ដូច្នេះ យើងចង់ឲ្យមានការបញ្ចប់សង្គ្រាមដើម្បីទទួលបានសន្តិភាពនិងមានឱកាសក្នុងការអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ» ។

ជាមួយគ្នានោះដែរ លោក យឹម ផាន់ណា អភិបាលនៃគណៈអភិបាលស្រុកអន្លង់វែង និងជាអតីតប្រធានកងពលខ្មែរក្រហមក្នុងតំបន់អន្លង់វែងដែលបានផ្តាច់ខ្លួនមកចុះចូលជាមួយរដ្ឋាភិបាលក្នុងឆ្នាំ១៩៩០ ហើយក្រោយមកបានដើរតួនាទីជាអ្នកចរចាដ៏សំខាន់ម្នាក់រវាងខ្មែរក្រហម និងរដ្ឋាភិបាលសម្តេច ហ៊ុន សែន បានលើកឡើងថា «បងប្អូនអតីតខ្មែរក្រហមមិនមែនជាមនុស្សអាក្រក់ទាំងអស់នោះទេ ។ ទោះបីយ៉ាងណាក៏ទឹកចិត្តបងប្អូនដែលជាអតីតទាហានខ្មែរក្រហមនៅក្នុងតំបន់អន្លង់វែងនេះមានឆន្ទៈជារួមមួយគឺចង់មានការបញ្ចប់សង្គ្រាមនិងការបញ្ចប់ការបង្ហូរឈាមរវាងខ្មែរនិងខ្មែរ ហើយរួមគ្នាកសាងប្រទេសជាតិឡើងវិញ» ។ ជាងនេះទៅទៀត លោក យឹម ផាន់ណា ក៏បានជំរុញឲ្យអតីតកម្មាភិបាលខ្មែរក្រហមដទៃទៀតចូលរួមក្នុងការសិក្សាពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនិងការចែករំលែកដល់កិច្ចការស្រាវជ្រាវពីប្រវត្តិសាស្ត្រសហគមន៍ស្រុកអន្លង់វែងដែលជាគម្រោងសិក្សាស្រាវជ្រាវថ្មីមួយ ។

ជាការចូលរួមជាមតិយោបល់ លោកជំទាវបានបន្ថែមទៅលើការលើកឡើងរបស់លោកអភិបាលស្រុកថា «បើខ្វះការជួបជុំនិងខ្វះភាពសុខដុមគឺមិនអាចធ្វើឲ្យយើងមានសន្តិភាពបានទេ ។ ជាពិសេស សន្តិភាពមិនត្រឹមតែមាននៅខាងក្រៅខ្លួននោះទេ គឺត្រូវតែមានក្នុងចិត្តថែមទៀតផង» ។

ជាចុងក្រោយ លោកជំទាវជំរុញឲ្យប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេសជនរងគ្រោះ និងជនដៃដល់ ចេះអត់ឱននិងយល់អធ្យាស្រ័យគ្នាទៅវិញទៅមកក្នុងគោលបំណងឆ្ពោះទៅរកការផ្សះផ្សា ដើម្បីបញ្ឈប់ជម្លោះនិងការរើសអើង ។

ប្រជាជននៅតំបន់អន្លង់វែងនិងអតីតខ្មែរក្រហមតំបន់ផ្សេងរួមទាំងប្រជាជនខ្មែរទាំងអស់សុទ្ធតែមិនចង់បានការវិលត្រឡប់មកវិញនូវរបបប្រល័យពូជសាសន៍និងសង្គ្រាមទេ ។ ជាងនេះទៀត ដើម្បីកសាងជីវិតថ្មី ក្រោយសង្គ្រាមដ៏រ៉ាំរ៉ៃក្នុងតំបន់មួយនេះប្រជាជនមិនប្រាថ្នាអ្វីក្រៅពីសេចក្តីសុខ រស់នៅជួបជុំបងប្អូនក្រុមគ្រួសារនិងចង់ឲ្យកូនចៅរបស់ខ្លួនទទួលបានការអប់រំត្រឹមត្រូវនៅក្នុងសាលារៀនដើម្បីរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ។

**ម៉ម សុវណ្ណ**

# អ្នកដាំបាយនៅអង្គភាពក-៦

ហេង គាក់ អាយុ៥០ឆ្នាំ មានស្រុកកំណើតនៅភូមិត្រពាំងប្រៃ ឃុំត្រពាំងរាំង ស្រុកឈូក ខេត្តកំពត ។ គាក់ មានឪពុកឈ្មោះ ហេងដាន និងម្តាយ សៀង សេង ព្រមទាំងមានបងប្អូនបង្កើតប្រាំពីរនាក់ ។ សព្វថ្ងៃគាក់រស់នៅស្រុកជុំគិរី ខេត្តកំពត ។

មុនសម័យខ្មែរក្រហម គាក់ បានរៀនសូត្រត្រឹមថ្នាក់ទី៣ ប៉ុណ្ណោះ ។ ក្រោយពេលខ្មែរក្រហមចូលគ្រប់គ្រងអំណាចនៅក្នុងភូមិ គាក់ ត្រូវបានអង្គការចាត់តាំងឲ្យទៅរស់នៅកន្លែងមួយឆ្ងាយពីក្រុមគ្រួសាររបស់គាត់ ។ គាក់ នៅចាំបានថា ថ្ងៃមួយមានកម្មាភិបាលពីរនាក់គឺដុច និងផន ដែលជាគ្រូគ្រៀននៅក្នុងកងកុមារបានដឹកនាំកុមារជាច្រើននាក់ទៅកាប់ទន្រ្ទានខែត្រនិងលើកទំនប់នៅភូមិព្រៃផ្តៅឆ្ងាយពីភូមិ ។ នៅទីនោះ ប្រធានភូមិឈ្មោះ អ៊ុន តែងតែបញ្ជាយកមនុស្សទៅសម្លាប់ចោលនៅក្បែរភូមិជារៀងរាល់ថ្ងៃ ។ ដោយសារតែគាត់ជាប្រធានភូមិមិនមាននរណាម្នាក់ហ៊ានប្រកែកជាមួយទេនៅពេលដែលគាត់មិនសប្បាយចិត្ត ឬមិនពេញចិត្តទៅលើនរណាម្នាក់នោះ អ៊ុន តែងតែបញ្ជាឲ្យកងឈ្លបចាប់យកទៅសម្លាប់ចោលដោយមិនរើសមុខឡើយ ។ នៅថ្ងៃមួយ អ៊ុន បានលេងល្បែងភ្នាល់ជាមួយអ្នកភូមិម្នាក់ឈ្មោះ ម៉ាន ដោយនិយាយថាតើនរណារែកដីបានច្រើនជាងគេ? ចំណែក ម៉ាន ដោយសារតែខ្លាចរែកចាញ់ អ៊ុន ក៏បានខិតខំប្រឹងប្រែងតស៊ូរែកដីរហូតបានច្រើនជាង អ៊ុន មែន ។ ប៉ុន្តែមិនយូរប៉ុន្មាន អ៊ុន បានបញ្ជាឲ្យកងឈ្លបនាំ ម៉ាន ទៅសម្លាប់ចោល ។

និយាយពីបងប្អូនរបស់ គាក់ ឈ្មោះ អាត ដែលទើបជម្លៀសពីភ្នំពេញក៏ត្រូវបានអង្គការចាប់យកទៅសម្លាប់ដែរ ដោយចោទថាជាគិញរបស់អង្គការ ។ គាក់ រៀបរាប់បន្តទៀតថា មានថ្ងៃមួយ នៅពេលកំពុងហូបបាយជុំគ្នា ឈ្លបឃុំបានដើរមកហើយបញ្ជាឲ្យ អាត ដាក់ដៃទៅក្រោយហើយឈ្លបនោះក៏បានអារក ។ គាក់ នៅចាំបានថា អ៊ុន តែងតែហៅប្រជាជនមកជួបជុំគ្នាហើយនិយាយប្រាប់ថានឹងបោសសម្អាតប្រជាជន១៧មេសា ។ មិនតែប៉ុណ្ណោះ ពីមួយថ្ងៃទៅមួយថ្ងៃ អង្គការតែងតែបង្ខំ គាក់ ក៏ដូចជាប្រជាជនដទៃទៀតឲ្យធ្វើការលើកទំនប់ទាំងយប់ទាំងថ្ងៃស្ទើរគ្មានពេលសម្រាក ។ មួយរយៈក្រោយមក អង្គការបានផ្លាស់ គាក់ ទៅធ្វើការកន្លែងផ្សេងមួយទៀតនៅទីនោះស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានឃុំឈ្មោះ ដែន (មកពីខេត្តព្រៃវែង) ដែលមានរូបរាងស្គម សម្បុរសនិងជាមនុស្សមិនសូវកាចទេ ។ ដែន តែងតែធ្វើពិធីប្រជុំមួយដើម្បីនិយាយអំពីផែនការនយោបាយ និងលើកទឹកចិត្តទៅដល់ប្រជាជនដើម្បីធ្វើស្រែប្រាំងឲ្យបានល្អតាមផែនការរបស់អង្គការ ។


ហេង គាក់

នៅក្នុងឆ្នាំ១៩៧៧ អង្គការបានស្នើ គាក់ ឲ្យទៅធ្វើការងារនៅភ្នំពេញវិញ ។ ពេលនោះ គាក់ មានបំណងចង់រត់ចេញដោយសារតែមិនចង់ទៅរស់នៅឆ្ងាយពីម្តាយ តែជាអកុសល ពេលដែលរៀបនឹងរត់ គាក់ ក៏ត្រូវអង្គការចាប់ខ្លួនបានតែម្តង ។ បន្ទាប់មក អង្គការបានបញ្ជូន គាក់ ឲ្យទៅដកស្ទូងជាមួយកុមាររាប់ពាន់នាក់ផ្សេងទៀតដោយស្នាក់នៅ

ខេត្តតាកែវរយៈពេលបួនថ្ងៃ ។ នៅថ្ងៃមួយ គាត់ បានឃើញបុរសម្នាក់ដែលគេគ្រប់គ្នាស្គាល់ថាជា តាម៉ុក មកមើលកុមារជម្រះស្មៅនៅតាមផ្លូវថ្នល់ ។ នៅទីនោះបានមួយរយៈអង្គការបានផ្លាស់កុមារមួយចំនួនទៀតឲ្យចេញទៅធ្វើការផ្សេងពីគ្នា ចំណែក គាត់ ជាមួយនឹងកុមារដប់ពីរនាក់នៅក្នុងភូមិរបស់គាត់ត្រូវបានអង្គការបញ្ជូនតាមរថភ្លើងមកភ្នំពេញវិញ ។

មកដល់ភ្នំពេញបានរយៈពេលបីខែ នៅខាងជើងស្តាតអូឡាំពិក គាត់ បានឃើញគណៈឃុំ និងគណៈស្រុកមកពីគ្រប់ខេត្តគ្រប់តំបន់បានមកស្នាក់នៅ និងរៀនសូត្រនយោបាយមានចំនួនប្រហែលជា៥០០ទៅ១,០០០នាក់ ។ នៅទីនោះ គាត់ ជាអ្នកលើកបាយជូនគណៈឃុំនិងគណៈស្រុកទាំងនោះ ។ គាត់និយាយថា គាត់បានជួប តា ផែន ដែលជាគណៈឃុំនៅខេត្តតាកែវ ពេលនោះតា ផែន បានសួរគាត់ថា «នៅទីនេះឬ?» រួច គាត់ បានឆ្លើយថា «ខ្ញុំនៅទីនេះ» ។ គាត់ សួរ តា ផែន ថាមកទីនេះដើម្បីអ្វី? ទើបតា ផែន និយាយថា អង្គការឲ្យគាត់មករៀនសូត្រ ។ បន្ទាប់ពីគណៈឃុំ និងគណៈស្រុកហូបបាយរួច ការងាររបស់ គាត់ និងកុមារផ្សេងទៀតគឺប្រមែប្រមូលចានឆ្នាំងយកទៅលាង ។ ក្រៅពីការងារទទួលភ្ញៀវ គាត់ ត្រូវបានបញ្ជូនឲ្យទៅចិតបន្លែ និងបោសសម្អាតថ្នល់ថែមទៀត ។ ការងារទាំងអស់ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឡុន ជាប្រធានអង្គភាពក-៦ តែងតែហៅប្រជាជនមកប្រជុំដើម្បីនិយាយប្រាប់អំពីការងារនីមួយៗ ។ លើសពីនេះទៅទៀត នៅពេលដែលមានកម្មវិធីប្រគុំតន្ត្រីសិល្បៈម្តងៗ អង្គការតែងតែបានចាត់តាំងឲ្យទៅទស្សនាការប្រគុំតន្ត្រីសៀកកូរ៉េនេះដែរ ។ គាត់ បន្តទៀតថា មានគណៈប្រតិភូមកអបអរសាទរនៅក្នុងស្តាតនេះម្តងម្កាលដែរ ហើយ គាត់ និងកុមារផ្សេងទៀតក៏ដូចជាប្រជាជនផ្សេងទៀតបានមកបោសសម្អាត និងដកស្មៅឲ្យបានស្អាតនៅក្នុងស្តាតជារៀងរាល់ពេល ។

ថ្ងៃមួយ គាត់ និងកុមារផ្សេងទៀតបានទៅចូលរួមឈរដង្ហែនៅនឹងថ្នល់ព្រមទាំងកាន់បាច់ផ្កា គ្រវីដោយ ស្រែកថា «ជ័យយោ! ជ័យយោៗ!» មិនយូរប៉ុន្មាន ក្រោយពីបានទទួលការអបអរសាទររួចមក គាត់បានឃើញ ប៉ុល ពត និង ខៀវ សំផន ព្រមទាំងជនបរទេសផ្សេងទៀតចុះមកសួរសុខទុក្ខប្រជាជនកំពុងធ្វើការ ។ អ្វីដែលជាការចម្លែកនោះ កុមារមួយចំនួនដែលនៅក្នុងក្រុមរបស់គាត់តែងតែមានការបាត់ខ្លួនខ្លះទៀតត្រូវបានអង្គការផ្លាស់ចេញពីកន្លែងមួយទៅកន្លែងផ្សេងទៀត ។ ដោយសារតែមានការបាត់ខ្លួនសមាជិកនៅក្នុងក្រុមយ៉ាងនេះ គាត់តែងតែមានការភ័យខ្លាច ហើយគិតក្នុងចិត្តថា មិនដឹងពេលណាប៉ះមកលើខ្លួនគាត់នោះទេ ។

មិនយូរប៉ុន្មាន ប្រធានគណៈស្រុកបានបញ្ជាឲ្យកុមារជាច្រើននាក់ចាកចេញពីកន្លែងស្តាតនេះដោយប្រាប់ឲ្យរត់ទៅមុខព្រោះឮថាវៀតណាមជិតចូលមកក្រុងភ្នំពេញ ។ គាត់ និងកុមារផ្សេងទៀតបានរៀបចំបង្កិចខោអាវប្រញាប់ប្រញាល់នាំគ្នាឡើងជិះរថភ្លើងទៅខាងលិចបាត់ដំបងវិញ ។ កុមារនៅក្រុមផ្សេងទៀតបាននាំគ្នារត់ទៅពេជ្រនិល អ្នកខ្លះទៀត រត់ទៅកន្លែងផ្សេងៗ ។ មិនយូរប៉ុន្មាន គាត់ បានមកដល់វត្តបាកាន ហើយឈប់សម្រាកជាមួយអ្នកភូមិ ។ នៅទីនោះ គាត់ ត្រូវបានអង្គការឲ្យទៅប្រូតស្រូវនៅរំលេច ខេត្តពោធិ៍សាត់បានរយៈពេលមួយឆ្នាំ ។

ក្រោយថ្ងៃ៧មករា ១៩៧៩ គាត់ បានត្រលប់មកស្រុកកំណើតវិញ ដោយប្រកបរបរធ្វើស្រែចម្ការជាមួយក្រុមគ្រួសាររបស់គាត់រហូតសព្វថ្ងៃ ។

ទាក់ទិនទៅនឹងដំណើរការតុលាការខ្មែរក្រហមដែលទាក់ទងទៅនឹងសំណុំរឿង០០២ មាន នួន ជា, ខៀវ សំផន, និង អៀង សារី និងបន្ទាប់ពីបានចូលរួមស្តាប់ដំណើរការនៃការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនោះរួចមក គាត់មានសេចក្តីសប្បាយរីករាយខ្លាំងព្រោះនេះជាលើកដំបូងសម្រាប់រូបគាត់ ដែលមានឱកាសបានមកចូលរួមនៅក្នុងសវនាការដោយផ្ទាល់បែបនេះ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ គាត់ នៅតែមិនពេញចិត្ត ហើយនៅតែខឹងមេដឹកនាំខ្មែរក្រហមដែលមិនព្រមសារភាពការពិតនូវអ្វីដែលខ្លួនប្រព្រឹត្តមកលើប្រជាជនខ្មែរក្នុងអំឡុងដែលបក្សពួកខ្លួនគ្រប់គ្រងដែលបានឆក់យកជីវិតប្រជាជនអស់ជិតពីរលាននាក់នៅក្នុងរបបខ្មែរក្រហម ។ ដូច្នេះយុត្តិធម៌មិនទាន់សមស្របនោះទេ គាត់សំណូមពរឲ្យតុលាការកាត់ទោសមេដឹកនាំទាំងនេះឲ្យឆាប់ និងកុំពន្យារពេលទៅលើការកាត់ទោសនេះទៀត ដើម្បីជាគំរូសម្រាប់ក្មេងជំនាន់ក្រោយកុំឲ្យយកតម្រាប់តាម និងជៀសវាងកុំឲ្យមានរបបនេះកើតឡើងម្តងទៀត ។

**ស៊ិន សុធីតា**

# ស្រុកកំណើតរបស់ នួន ជា នៅភូមិវត្តគរ

ភូមិវត្តគរដែលជាភូមិមួយស្ថិតនៅតាមបណ្តោយដងស្ទឹងសង្កែក្នុងឃុំសង្កែ ក្រុងបាត់ដំបង ខេត្តបាត់ដំបងគឺជាស្រុកកំណើតរបស់ នួន ជា ។ មុនពេលរបបខ្មែរក្រហម ប្រជាជនដែលរស់នៅក្នុងភូមិនោះមានផ្ទះធំៗនិងមានជីវភាពល្អប្រសើរ ។ សព្វថ្ងៃផ្ទះរបស់ នួន ជា ក៏នៅទីនោះដែរ ហើយក្មួយរបស់ នួន ជា កំពុងរស់នៅផ្ទះនោះ ។

តាមរយៈការជំណាលតៗគ្នាពីប្រជាជនដែលរស់នៅក្នុងភូមិនោះបានបញ្ជាក់ថា គ្រួសាររបស់ នួន ជា គឺជាអ្នកមានជីវភាពធូរធារ ។ ដូច្នេះប្រជាជនដែលរស់នៅជិតខាងមិនសូវមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រួសារ នួន ជា ឡើយ ។ នៅពេលកម្លាំងខ្មែរក្រហមបានចូលមកដល់ ប្រជាជននៅក្នុងភូមិវត្តគរត្រូវបានជម្លៀសទៅនៅតំបន់ផ្សេងៗ ហើយព្រះសង្ឃដែលគង់នៅក្នុងវត្តគរក៏ត្រូវបានផ្សឹកទាំងអស់ ។ ដោយឡែកបងស្រីរបស់ នួន ជា ឈ្មោះ រឿត និងកូននៅតែបន្តរស់នៅក្នុងភូមិនោះជាលក្ខណៈគ្រួសារនិងមិនធ្វើការអ្វីទាំងអស់ ។ ចំណែកផ្ទះមួយដែលមានចម្ងាយប្រហែលមួយរយម៉ែត្រពីផ្ទះរបស់ នួន ជា ដែលបានសាងសង់តាំងពីឆ្នាំ១៩២០ ជាផ្ទះរបស់អតីតលោកឧកញ៉ា នូ ពិនិត្យ ភីង ជាអតីតមេធាវីកាលពីសម័យសង្គមរាស្ត្រនិយមនិងលោកជំទាវកើត យ៉ិន ។ ដោយសារតែផ្ទះនោះត្រូវបានសាងសង់ឡើងដោយឈើល្អប្រណីតមានសភាពមាំទាំនិងមានទំហំធំដូច្នេះខ្មែរក្រហមបានយកផ្ទះនេះមកធ្វើជារោងបាយនិងកន្លែងសម្រាប់បញ្ចាន់ស្រូវតែប៉ុណ្ណោះដោយមិនមានការបំផ្លិចបំផ្លាញអ្វីឡើយ ។


ផ្ទះបុរាណ នៅភូមិវត្តគរ ឃុំសង្កែ

បន្ថែមពីលើនេះ លោកយាយ រួម អាយុ៨៨ឆ្នាំដែលមានស្រុកកំណើតនិងរស់នៅក្នុងភូមិវត្តគរបានមានប្រសាសន៍ថា នៅពេលខ្មែរក្រហមចូលមកដល់ភូមិនេះលោកយាយត្រូវបានជម្លៀសទៅនៅច្រកក្រសាំងដែលនៅទីនោះផ្ទះធំៗរបស់ប្រជាជន




ត្រូវបានខ្មែរក្រហមចូលទៅរើរុះដើម្បីធ្វើជាផ្ទះគំរូតូចៗសម្រាប់ឲ្យប្រជាជនរស់នៅ ។ នៅទីនោះ ខ្មែរក្រហមបានឲ្យគាត់ធ្វើស្រែចម្ការ ហើយរបបអាហារដែលទទួលបាននោះគឺមានតែបបរប៉ុណ្ណោះ ។ ក្រោយពេលរបបខ្មែរក្រហមដួលរលំ លោកយាយបានត្រឡប់មកនៅស្រុកកំណើតវិញ ដោយសង្កេតឃើញថាស្ថានភាពនៅក្នុងភូមិវត្តគរនៅតែមានសភាពជាភូមិចាស់ដដែល ដោយសារស្ថានភាពផ្ទះដែលនៅក្នុងភូមិរបស់គាត់មិនមានការបំផ្លិចបំផ្លាញលើកលែងតែផ្ទះបាយរបស់គាត់មួយប៉ុណ្ណោះដែលខ្មែរក្រហមបានរើរុះយកទៅធ្វើជារោងគោ ។ ចំណែកផ្ទះរបស់លោកខុកញ៉ាវទៀតសោតសព្វថ្ងៃត្រូវបានបន្សល់ទុកជាផ្ទះបុរាណដែលមានការទទួលស្គាល់ពីមន្ទីរទេសចរណ៍ខេត្តបាត់ដំបងនិងមានភ្ញៀវចូលមកទស្សនានៅទីនេះជាញឹកញាប់ទៀតផង ។



ផ្លាកសញ្ញាដែលដាក់នៅពីមុខផ្ទះបុរាណ

លោក យាយ រួម បាននិយាយថា ផ្ទះរបស់គាត់និងផ្ទះរបស់អ្នកភូមិផ្សេងទៀតមិនត្រូវបានខ្មែរក្រហមបំផ្លាញចោលទេ ដោយសារតែទីនោះជាភូមិកំណើតរបស់ នួន ជា ។ **ឆាយ ឈុនលី**

# ឈប់រៀនដើម្បីបម្រើសិល្បៈបដិវត្តន៍ តែបដិវត្តន៍សម្លាប់ឪពុកម្តាយ

ប្រជាជននៅក្នុងប្រទេសកម្ពុជាបានឆ្លងកាត់នូវភាពលំបាកវេទនាព្រាត់ប្រាស់ឪពុកម្តាយ ញាតិមិត្ត និងទទួលរងនូវផលប៉ះពាល់ផ្សេងៗគ្នាក្នុងអំឡុងរបបខ្មែរក្រហម១៩៧៥-១៩៧៩ ។ ការចងចាំនូវអតីតកាលបែបនេះកាន់តែមានលក្ខណៈស្មុគស្មាញថែមទៀតខណៈដែលអ្នកខ្លះខំបំភ្លេចអ្នកផ្សេងទៀតមិនអាចបំភ្លេចបានឡើយ ។ ការចង់ឲ្យមានការទទួលស្គាល់នូវការឈឺចាប់បានជំរុញចិត្តឲ្យអ្នករស់រានមានជីវិតជាច្រើនចាប់ផ្តើមនិយាយអំពីការពិតរបស់ខ្លួន ។

អ៊ឹស្រី ឆែម សុភី អាយុ៤៥ឆ្នាំ ស្រុកកំណើតនៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ គាត់ជាកូនច្បងក្នុងចំណោមបងប្អូនប្រាំមួយនាក់ (ស្រីប្រាំ ប្រុសម្នាក់) ។ ឪពុកគាត់មានឈ្មោះ ឆែម សុផល មុខងារជាប្រធានគមនាគមន៍ ។ ចំណែកម្តាយគាត់មាន



កងសិល្បៈខ្មែរក្រហម

ឈ្មោះ កុល សាវិន ជាមេផ្ទះ ។ ឪពុករបស់ សុភី ធ្វើការជាមួយ សោ ភឹម លេខាភូមិភាគបូព៌ា ។ សុភី រៀនបានតិចតួចប៉ុណ្ណោះ ដោយសារតែស្រុកមានសង្គ្រាម ។ ស្ថានភាពបែបនេះបានជំរុញឲ្យ សុភី ចូលបម្រើក្នុងចលនាបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧២ ។

នៅពេលដែលខ្មែរក្រហមចូលមកកាន់កាប់ស្រុកត្បូងឃ្មុំ គ្រួសាររបស់ សុភី មិនត្រូវបានជម្លៀសទៅណាទេ ។ ពេលនោះ សុភី បានចូលជាអ្នកសិល្បៈប្រចាំស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ពេលនៅកងសិល្បៈ សុភី ឆ្លៀតពេលខ្លះរៀនអក្សរជាមួយនឹងកូនកម្មាភិបាលដទៃទៀតរហូតចេះល្មមអាចអានបាន ។ នៅដើមឆ្នាំ១៩៧៦ ហ៊ូ នឹម បានទៅជ្រើសរើសអ្នកសិល្បៈចំនួនម្ភៃនាក់ដែលមានទេពកោសល្យទៅសម្តែងនៅភ្នំពេញ ។ ក្នុងចំណោមនោះក៏មាន សុភី ម្នាក់ដែរដែលត្រូវបានជ្រើសរើសទៅភ្នំពេញ ។

សុភី មិនចាំថាគាត់និងអ្នកសម្តែងផ្សេងទៀតត្រូវបាននាំយកទៅស្នាក់នៅកន្លែងណាទេ ប៉ុន្តែនៅទីនោះ គាត់បានហាត់រៀនសិល្បៈបន្ថែមទៀតដើម្បីចូលរួមកម្មវិធីសម្តែងសម្រាប់គណៈប្រតិភូនិងសមាជិកបក្សកុម្មុយនីស្តកម្ពុជា ។ សុភី បានរំឭកថា កម្មវិធីសម្តែងមានជារៀងរាល់ថ្ងៃសម្រាប់បក្សកុម្មុយនីស្តហើយពេលខ្លះក៏មានការចូលរួមពីសំណាក់គណៈប្រតិភូអន្តរជាតិផងដែរមានដូចជាមកពីប្រទេសគុយបា យូហ្គោស្លាវី ឡាវ វៀតណាម ចិនភាគច្រើន ។ សុភី បន្តទៀតថា ជាទូទៅកម្មវិធីចប់នៅម៉ោង១០ព្រឹក រាល់ពេលការសម្តែងចប់ ក៏មានជារបាំជូនពរ និងចម្រៀងបដិវត្តន៍ទៀតផង ។ នៅពេលដែលក្រុមអ្នកសម្តែងរបស់ សុភី សម្តែងបានល្អ នួន ជា តែងតែលើកសរសើរថា “ល្អហើយ ក្មួយៗ! ខំធ្វើការដើម្បីអង្គការ” ។

ទាក់ទងនឹងការហូបចុកប្រចាំថ្ងៃវិញ សុភី បាននិយាយថា គាត់ទទួលបានរបបអាហារចំនួនបីពេលគឺពេលព្រឹកមានដូចជានំប៉័ង ចំណែកពេលថ្ងៃនិងពេលល្ងាចគឺបាយ ។ ការហូបគឺមិនមានការខ្វះខាតអ្វីទេ ។ ក្រៅពីការហ៊ឹកហាត់សម្តែងអ្នកសិល្បៈទាំងអស់ត្រូវបានអង្គការចាត់តាំងឲ្យធ្វើការងារមិនឲ្យទំនេរឡើយគឺឲ្យទៅធ្វើចម្ការអំពៅ ។ សុភី បន្តទៀតថារាល់រដូវចូលឆ្នាំ

គាត់និងក្រុមសិល្បៈត្រូវបានចាត់តាំងឲ្យទៅសម្តែងនៅតាមបណ្តាខេត្តនានា ដូចជា ខេត្តកំពង់ធំ កំពង់ចាម តាកែវ ខាងស្រែអំបិល នៅក្នុងខេត្តកំពតជាដើម ។

ក្រោយមក ខែមករា ឆ្នាំ១៩៧៨ សុភី ត្រូវបានអង្គការបញ្ជូនទៅឃុំរលាប ខេត្តពោធិ៍សាត់វិញ ។ នៅទីនោះ សុភី ត្រូវអង្គការតំបន់ចាត់តាំងឲ្យធ្វើស្រែ ។ សុភី កត់សម្គាល់ឃើញថារាល់យប់គាត់ឮសំឡេងឡានមកដឹកមនុស្សចេញពីភូមិ ប៉ុន្តែមិនដឹងថាដឹកទៅណាទេ ហើយចំនួនមនុស្សក្នុងភូមិក៏ចាប់ផ្តើមបាត់ខ្លួនជារៀងរាល់ថ្ងៃ ។ ស្ថិតក្នុងស្ថានភាពបែបនេះ សុភី មានអារម្មណ៍ភ័យខ្លាចនិងខិតខំធ្វើការងារដែលអង្គការបានចាត់តាំងឲ្យដោយស៊ូទ្រាំមិនថាឈឺឬជាទេ ។ បន្ថែមលើនេះការហូបចុកនៅឃុំរលាបមិនបានគ្រប់គ្រាន់ដូចកាលគាត់នៅសម្តែងក្នុងក្រុមសិល្បៈនៅភ្នំពេញទេគឺមានតែបបររាវៗ ម្នាក់ៗធ្វើការរហូតបាក់កម្លាំងដោយសារការហូបចុក និងការសម្រាកមិនគ្រប់គ្រាន់ ។ ថ្ងៃមួយមិនដឹងជាមានរឿងអ្វីទេ សុភី បានឃើញយោធាខ្មែរក្រហមបាញ់រះយ៉ាងសាហាវមកលើប្រជាជនដែលកំពុងធ្វើការ ។ អ្នកដែលឃើញហេតុការណ៍ទាំងនេះបានត្រឹមតែមានចិត្តសង្វេគក្នុងចិត្តឈ្ងោកមុខចុះប្រឹងធ្វើការងាររបស់ខ្លួនបន្តទៀតដើម្បីរក្សាជីវិតរស់ ។

ក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ សុភី បានវិលត្រឡប់ទៅស្រុកកំណើតវិញដើម្បីទៅជួបជុំគ្រួសារ ។ ប៉ុន្តែជាអកុសលនៅពេលដែល សុភី ទៅភូមិកំណើតទើបដឹងថាគ្រួសាររបស់ សុភី ត្រូវខ្មែរក្រហមយកទៅសម្លាប់តាំងពីឆ្នាំ១៩៧៨មកម្ល៉េះ ។ សុភី បាននិយាយថា អ៊ំប្រុសម្នាក់ឈ្មោះ សាមុត ប្រាប់គាត់ថា ឪពុករបស់ សុភី បានលួចរត់ទៅវៀតណាម ហើយត្រូវយោធាខ្មែរក្រហមចាប់បាន ហើយក៏យកសមាជិកគ្រួសារ សុភី ទាំងអស់ទៅសម្លាប់តែម្តងដោយចោទថាក្បត់ ។ សុភី គឺជាមនុស្សតែម្នាក់គត់ក្នុងគ្រួសារដែលមានសំណាងរួចជីវិតមកដល់សព្វថ្ងៃនេះ ។ អស់រយៈពេលជាងសាមសិបឆ្នាំកន្លងមកនេះ គាត់បានរំសាយកំហឹងនិងការឈឺចាប់របស់គាត់ទៅតាមពេលវេលា ។ អ្វីដែលពិសេសគឺថាអាចស្វែងរកការពិតយុត្តិធម៌ជូនឪពុកម្តាយនិងសមាជិកគ្រួសារបានតាមរយៈអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬហៅថាតុលាការខ្មែរក្រហម ។

ក្រោយពី សុភី បានស្តាប់សាលដីកាសម្រេចចុងក្រោយរបស់តុលាការកំពូលដោយសម្រេច ឲ្យ កាំង ហ្កេចអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ ឲ្យជាប់ពន្ធនាគារអស់មួយជីវិតនោះ សុភី សប្បាយចិត្តខ្លាំងណាស់ ពីព្រោះគាត់យល់ថាការកាត់ទោសនេះគឺជាយុត្តិធម៌មួយយ៉ាងពិតប្រាកដមែន ។ ប៉ុន្តែគាត់បានបញ្ជាក់ថា គាត់មានបំណងចង់ឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដូចជា នួន ជា, អៀង សារី, ខៀវ សំផន និង អៀង ធីរិទ្ធ ឲ្យសមទៅនឹងអំពើសាហាវព្រៃផ្សៃដែលមេដឹកនាំទាំងអស់នេះបានប្រព្រឹត្តមកលើប្រជាជនខ្មែរស្លូតត្រង់ ។ លើសពីនេះ សុភី ចង់ឲ្យតុលាការចាត់វិធានការយ៉ាងណាធ្វើឲ្យមេដឹកនាំទាំងអស់នេះសារភាពថាខ្លួនពិតជាមានគោលបំណង សម្លាប់ប្រជាជនខ្មែរប្រាកដមែន ដើម្បីឲ្យអ្នករស់រានមានជីវិតពីខ្មែរក្រហមស្ងប់អារម្មណ៍និងធូរស្បើយពីអតីតកាល ។

ជាចុងក្រោយ សុភី សំណូមពរឲ្យតុលាការពន្លឿនការងាររបស់ខ្លួនក្នុងការកាត់ទោសមេដឹកនាំទាំងអស់នេះឲ្យបានឆាប់រហ័ស ពីព្រោះមេដឹកនាំទាំងបួននាក់នេះមានសុខភាពទ្រុឌទ្រោមហើយ មិនអាចរស់បានយូរទេ ហើយសូម្បីតែជនរងគ្រោះក្នុងអំឡុងរបបខ្មែរក្រហមក៏បានស្លាប់ជាបន្តបន្ទាប់ដែរ ។

តាមរយៈការស្តាប់រឿងរ៉ាវនិងបទពិសោធន៍ជីវិតរបស់អ៊ំស្រី ឆែម សុភី បានធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់ពីរបបឃោរឃៅរបស់ខ្មែរក្រហម ។ ខ្ញុំគឺជាក្មេងជំនាន់ក្រោយដែលមិនបានឆ្លងកាត់ព្រឹត្តិការណ៍ជូរចត់និងឈឺចាប់ដូចជាការកាប់សម្លាប់ និងការបង្អត់អាហារទេ ។ ដើមឡើយ ខ្ញុំមិនជឿថា “ខ្មែរហ៊ានសម្លាប់ខ្មែរ” គ្នាឯងនោះទេ ។ ប៉ុន្តែក្រោយពេលដែលខ្ញុំស្តាប់ឮរឿងរ៉ាវនិងបទពិសោធន៍ជីវិតរបស់អ៊ំស្រី សុភី ក្នុងរបបខ្មែរក្រហម ខ្ញុំមានអារម្មណ៍ថាឈឺចាប់ជំនួសគាត់ពីព្រោះសមាជិកគ្រួសាររបស់គាត់ទាំងអស់ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងចោទប្រកាន់ថាក្បត់ ។ ខ្ញុំកត់សម្គាល់ឃើញថា ពាក្យថា “ក្បត់” គឺហេតុផលតែមួយដែលខ្មែរក្រហមតែងតែលើកឡើងដើម្បីសម្លាប់ប្រជាជនខ្មែរ ។ អ៊ំស្រី សុភី បាននិយាយដោយអស់សង្ឃឹមទៅនឹងរបបខ្មែរក្រហមថា គាត់ខំបម្រើខ្មែរក្រហម រស់នៅស៊ីអត់ស៊ីឃ្លាន តែខ្មែរក្រហមនៅតែសម្លាប់ឪពុកម្តាយគាត់ដដែល ។ **ពៅ ពុទ្ធាទី**

# បែកម្តាយតាំងកុមារភាព

*កែវ តេង កើតភូមិព្រៃខ្លា ស្រុកបាទី ខេត្តតាកែវ ។ កាលពីក្មេង តេង បានចូលរៀននៅបឋមសិក្សាត្រាំខ្នារ ខេត្តតាកែវ ។*

*នៅចុងឆ្នាំ១៩៧០ គ្រួសាររបស់ តេង បានផ្លាស់មករស់នៅភ្នំពេញដោយសារមានចលាចលក្នុងភូមិ ។ នៅឆ្នាំ១៩៧២ តេង បានចូលរៀននៅបឋមសិក្សាទួលស្វែង ។ រហូតដល់ឆ្នាំ ១៩៧៥ ទើបគាត់និងគ្រួសារត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញដោយត្រឡប់ទៅស្រុកកំណើតវិញ ។ កាលនោះ គ្រួសាររបស់ តេង ត្រូវចំណាយពេលប្រហែលរយៈពេលមួយខែទើបបានមកដល់ស្រុកកំណើត ។*

*តេង ត្រូវបំបែកចែកចេញពីឪពុកម្តាយឲ្យទៅរស់នៅជុំជាមួយកងចល័តកុមារ ។ កងកុមារចល័តមានការងារជាច្រើន ដូចជារែកដី លើកទំនប់ ជីកប្រឡាយ និងជាកុមារដែលសកម្មក្នុងភូមិ ។ តេង បញ្ជាក់ថា “ការងាររបស់ខ្ញុំវាប្រហាក់ប្រហែលនឹងការងាររបស់យុវជនដែរ” ។ ពេលលើកដី តេង ត្រូវរែកដីជាក្រុមដែលមានគ្នាបួននាក់ ។ ការងារនោះ តេង ប្រាប់ថា “ខ្ញុំត្រូវតែលើកដោយខ្លួនឯងដោយគ្មានអ្នកណាអាចជួយលើកបានទេ” ។ តេង ត្រូវតែធ្វើការងារជារៀងរាល់ថ្ងៃដោយគ្មានបានរៀនសូត្របន្តទេ ។*

*គាត់រំឭកបន្តថា “ការរៀនសូត្រវាពិបាកណាស់ គឺខ្ញុំមិនបានរៀនទេ” ។ និយាយទាំងអួលដើមក តេង បានត្អូញត្អែរចំពោះការហូបចុកដែលមិនបានគ្រប់គ្រាន់ពេលណាឈ្លបខ្មែរក្រហមតាមទាន់នឹងចាប់យកទៅវាយចោល ។ តេង បានរំឭកថា “ថ្ងៃមួយពេលយប់ ខ្ញុំបានឡើងដើមត្នោតដើម្បីលួចទឹកត្នោតហូបហើយជាមួយមិត្តភក្តិក្នុងកងជាមួយគ្នា ។ ពេលនោះ ឈ្លបតាមមកទាន់ក៏នាំគ្នាចុះពីលើដើមរត់ស្ទើរតែមិនទាន់” ។ កងកុមារទាំងអស់សុទ្ធតែលួចហូបនៅតាមសហករណ៍ពេលខ្លះជួបគ្នានៅកន្លែងលួចក៏មាន ។ នៅពេលដែលខ្មែរក្រហមទាំងនោះដេញមក តេង ត្រូវរត់ឲ្យលឿនដើម្បីកុំឲ្យឈ្លបខ្មែរក្រហមតាមទាន់ ។ ពេលខ្លះ តេង ក៏ដូចជាកុមារដទៃទៀតតែងតែនឹករឭកឪពុកម្តាយ ហើយបានលួចរត់ទៅលេងផ្ទះដោយគ្មានការអនុញ្ញាតពីមេកង ។*

*ជារឿយៗ តេង បានលួចរត់មកលេងផ្ទះបែបនេះ ។ ពេលដែលបាត់មួងៗ មេកងចល័តរបស់ តេង បានដេញចាប់ តេង យកទៅកងចល័តវិញ ។ ហើយ តេង ត្រូវធ្វើការលុតជុំជាងពេលធម្មតា ពីព្រោះតែមកលេងផ្ទះដោយគ្មានការអនុញ្ញាតពីមេកង ។ តេង តែងសម្គាល់ឃើញថា នៅពេលដែលកុមារណានៅតែចង់មកជួបឪពុកម្តាយតែចាប់បានពីរឬបីដងត្រូវចាប់យកទៅសម្លាប់ចោល ។*

*ជាក់ស្តែង ពេលមួយ តេង បានលួចរត់ទៅជួបឪពុកម្តាយ ហើយត្រូវប្រធានកងឈ្មោះ យ៉ុម ចាប់បានហើយចងបណ្តើរជាមួយឈ្មោះ ហង្ស ផល្លីមធុរ៉ា ដែលរត់ទៅជាមួយគ្នា ។ យ៉ុម បានបណ្តើរ តេង និង មធុរ៉ា ទៅរណ្តៅគល់ប្រាំងខាងត្បូងភ្នំបន្ទាយ ។ ហើយ យ៉ុម បានលើកត្បូងចបប្រុងនឹងសម្លាប់ តេង និង មធុរ៉ា ដោយសារតែខស្សរាហ៍មកលេងជាមួយឪពុកម្តាយពេក ។ ប៉ុន្តែ ដោយក្តីអាណិត យ៉ុម មិនបានប្រព្រឹត្តរឿងនេះទេ ។ យ៉ុម បានដោះលែង តេង និង មធុរ៉ា ឲ្យត្រឡប់មកកងចល័តវិញ ។*

*តេង បាននិយាយខ្មែរក្រហមពុំមានអ្វីទាំងអស់ក្រៅពីការងារហួសកម្លាំង មិនបានរៀនសូត្រ ហូបមិនគ្រប់គ្រាន់និងពុំបានរស់នៅជួបជាមួយឪពុកម្តាយ ។ តេង បន្ថែមថា “វាពិបាកណាស់សឹងតែនិយាយមិនចេញពីព្រោះកុមារមិនបានត្រូវទៅរៀនទៅសូត្រគឺមានតែធ្វើការសត្វធាតុ ។ យើងវេទនាជាងគោទៅទៀត” ។*

*នៅឆ្នាំ១៩៧៩ តេង បានដឹងយ៉ាងច្បាស់ថា ក្នុងចំណោម ១០៦គ្រួសារដែលមករស់នៅភូមិព្រៃខ្លានៅសល់តែប្រាំមួយគ្រួសារប៉ុណ្ណោះដែលនៅរស់ ។ ចំណែក តេង បានក្លាយជាក្មេងកំព្រាម្តាយ និងស្លាប់ប្អូនប្រុសបីនាក់និងជីដូនម្នាក់ ។*

តែក្រោយមកឆ្នាំ១៩៧៩ មិត្តភក្តិរបស់ គេង ប្រាប់គាត់ឲ្យទៅសងសឹកវិញ ។ តែ គេង មិនចង់សងសឹកទេ ក្រោយមក គេង បានត្រឡប់មករស់នៅទីក្រុងភ្នំពេញដើម្បីបន្តការសិក្សា ។ នៅឆ្នាំ១៩៨៧ គេង បានចូលរៀននៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកគីមីវិទ្យា ។ នៅឆ្នាំ២០១១ គេង បានក្លាយជានាយកវិទ្យាល័យទួលអំពិល ។

ទាក់ទងនឹងការចុះមកធ្វើការរបស់ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា គេង មានការរំភើបដែលនេះជាឱកាសឲ្យក្មេងៗបានដឹងថាតើរបបខ្មែរក្រហមមានទារុណកម្មបែបណា ។ គេង ប្រាប់ថា "ការផ្សព្វផ្សាយជាការល្អ ដើម្បីឲ្យក្មេងឆ្លុះបញ្ចាំងឲ្យឃើញថាពីសម័យមុនធ្វើបាបទារុណកម្មទៅលើប្រជាពលរដ្ឋ ។ ជាក់ស្តែង កុំឲ្យភ្លេចរបបដែលធ្វើបាបប្រជាពលរដ្ឋ ។ ជាការល្អឲ្យក្មេងបានដឹង" ។ ចំពោះដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនេះគឺត្រូវកាត់ទោសរាល់ទង្វើដែលប្រព្រឹត្តខុសឆ្គងនឹងរបស់អ្នកដឹកនាំសម័យនោះ ។ គេង បន្ថែមថា "ខ្ញុំពេញចិត្តចំពោះការកាត់ទោសនេះ ។ តាមការតាមដានជាប់លាប់មកខ្ញុំយល់ថា ឌុច ថាគេបញ្ជាអីចឹងប្រហែលមានអ្នកនៅពីលើគាត់ ។ ជួនកាលខ្ញុំនឹកឃើញថា គេបញ្ជាមកតិច តែគាត់អនុវត្តច្រើន" ។ ជាចុងក្រោយ គេង យល់ថា "តុលាការខ្មែរក្រហមធ្វើឡើងដើម្បីស្វែងរកការពិតកុំឲ្យចេះតែមកធ្វើហើយទុកចោលមិនបានកាត់ទោសអ្នកណាដែលធ្វើខុស ថ្ងៃក្រោយចេះធ្វើតទៅទៀតបានចឹងអ្នកដែលប្រព្រឹត្តខុសយកមកកាត់ទោសដើម្បីឲ្យក្មេងបានរៀនសូត្រជាគំរូមិនឲ្យអំពើនេះកើតឡើងម្តងទៀត" ។

ក្នុងនាមជានាយកសាលា គេង ចង់ឲ្យក្មេងជំនាន់ក្រោយរៀនសូត្រឲ្យបានខ្ជាប់ខ្ជួននូវប្រវត្តិសាស្ត្ររបស់ប្រទេសខ្លួន "ការរៀនសូត្រធ្វើឲ្យខ្ញុំឆ្លុះបញ្ចាំងនូវអ្វីដែលបានកើតឡើងពីសម័យមុន" ។

**ហ៊ិន សុធានី**



កងកុមារវែកដីក្នុងរបបខ្មែរក្រហម

# ត្រូវចងស្លាបសេកដោយសាររត់ទៅជួបម្តាយ

សេ គឹមសាន្ត ជាគ្រូបង្រៀនមុខវិជ្ជាសង្គ្រោះនិងមានឋានៈជាវរសេនីយ៍ទោនៅវិទ្យាស្ថានទ័ពជើងគោកខេត្តកំពង់ស្ពឺ ។ គឹមសាន្ត បានធ្វើជាទាហានតាំងពីទសវត្សរ៍៨០មកម៉្លេះ ។

គឹមសាន្ត បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពីការបង្រៀន "ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ១៩៧៥-១៩៧៩" ដល់និស្សិតទាហាននៅវិទ្យាស្ថានទ័ពជើងគោកកាលពីព្រឹកថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១២ ។ នៅក្នុងឱកាសទទួលទានអាហារថ្ងៃត្រង់ជាមួយក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា យោធាបាននិយាយរៀបរាប់ប្រាប់គ្នាទៅវិញទៅមកពីរឿងរ៉ាវជីវិតនៅសម័យខ្មែរក្រហម ។

ខណៈនោះ គឹមសាន្ត ក៏ចាប់ផ្តើមរៀបរាប់ពីប្រវត្តិរបស់គាត់នៅក្នុងរបបខ្មែរក្រហមថានៅសម័យនោះគាត់មានអាយុទើបតែប្រាំទៅប្រាំមួយឆ្នាំប៉ុណ្ណោះ ខ្មែរក្រហមបានបំបែកគាត់ពីម្តាយឲ្យទៅនៅកងកុមារ ។ គឹមសាន្ត មានការនឹករឮកម្តាយយ៉ាងខ្លាំង ហើយគាត់តែងតែរត់មករកម្តាយជារឿយៗ ។ នៅពេលដែលមិនជួបម្តាយម្តងៗ គឹមសាន្ត តែងតែថើបនិងស្រង់ក្លិនខោអាវម្តាយរបស់គាត់ដើម្បីបំបាត់ការនឹករឭកម្តាយ ។ គឹមសាន្ត ឲ្យដឹងថាទោះជាគាត់មិនបានជួបមុខម្តាយក៏ដោយ ក៏ការស្រង់ក្លិនខោអាវម្តាយគាត់នោះបានធ្វើអារម្មណ៍គាត់ធូរស្រាលបន្តិចដែរ ។

នៅពេលមួយ អង្គការបានអនុញ្ញាតឲ្យ គឹមសាន្ត នៅជួបម្តាយនៅពេលព្រឹកថ្ងៃបន្ទាប់ ប៉ុន្តែដោយសារគាត់នឹករឭកម្តាយខ្លាំងពេកគាត់ក៏សម្រេចចិត្តប្រព្រឹត្តល្មើសនឹងបញ្ជារបស់អង្គការដោយរត់ទៅជួបម្តាយនៅយប់នោះតែម្តង ។ គឹមសាន្ត ត្រូវឈ្លបចាប់បានជាមួយនឹងក្មេងតូចៗនិងក្មេងជំទង់ប្រហែលជាងដប់នាក់ទៀត ។ នៅពេលនោះ ខ្មែរក្រហមដាក់ទោស គឹមសាន្ត និងក្មេងទាំងនោះឲ្យរត់ពីមុខសេះ ។ គឹមសាន្ត មិនហ៊ានឈប់ទេព្រោះខ្លាចសេះបោលបុក និងជាន់ពីលើ ។ ក្មេងជំទង់ដែលធំជាង គឹមសាន្ត បន្តិចបានរត់គេចពីមុខសេះចេញទៅផ្លូវតាមបណ្តោយទ្រើងនៅផងក្បៀនផ្ទះបាត់អស់នៅសល់តែក្មេងតូចៗរត់យ៉ាងលឿនត្របាញ់ជើងខ្លាចសេះបោលបុក ។




ខ្មែរក្រហមចាប់ក្មេងៗទាំងនោះ រួមទាំង គឹមសាន្ត ចងស្លាបសេកដាក់នៅក្រោមរោងសហករណ៍ដែលជាផ្ទះបុរាណដែលមានសរសរមូលរលោងស្រិល រួចហើយចងក្មេងៗទាំងនោះផ្ដោបគ្រប់សរសរផ្ទះទាំងអស់ ។ គឹមសាន្ត នៅចងចាំថា អ្នកដែលចងគាត់ និងក្មេងៗទាំងនោះគឺយាយចែម (អ៊ុម

ចែម អតីតគណៈស្រុកព្រះនេត្រព្រះ) និងកងឈ្លបប្រុសៗពីរបីនាក់ទៀត ។ នៅក្នុងចំណោមអ្នកដែលចាប់គាត់ចង គឹមសាន្ត នៅចំណាំ យាយចែម ច្រើនជាងគេព្រោះគាត់ជាស្រីនិងមានឋានៈធំជាងគេ ។ នៅពេលនោះ គឹមសាន្ត មិនដឹងថា យាយចែម គំរាមឬនិយាយលេងនោះទេ ពេលដែលគាត់និយាយថា «តោះរៀបចំយកពួកហ្នឹងទៅវាយចោល» ។ ក្រោយមក កងឈ្លបក៏យកក្ដៅរទេះ គល់ឫស្សី និងត្បូងចបមក ។ គឹមសាន្ត និយាយទាំងកំប្លែងថា ដោយសារតែភាពក្មេងវ័យគាត់មិនដឹងថាការស្លាប់នឹងយ៉ាងម៉េចទេ ហើយក៏ចង់ដឹងដែរថាតើការស្លាប់នោះយ៉ាងម៉េច? សំណាងល្អថ្ងៃនោះមានភ្លៀងផ្គរខ្លាំង យាយចែម និងកងឈ្លបនោះក៏ដោះលែងគាត់និងក្មេងៗនោះឲ្យទៅនៅវត្តវិញ ។ ប៉ុន្តែ គាត់បានគំរាមថា បើថ្ងៃក្រោយហ៊ានរត់ទៀតនឹងយកទៅវាយចោលមិនខាន ។

នៅពេលសួរថាហេតុអ្វីបានជាចងចាំថា អ្នកចងនោះជា យាយចែម? គឹមសាន្ត ឆ្លើយថា នរណាក៏ស្គាល់ យាយចែម ដែរនៅពេលនោះ ។ នៅពេលសួរបន្តថា យាយចែម ជាគណៈស្រុកដែលមានឋានៈធំហេតុអ្វីបានជាមកចាត់ចែងរឿងកុមារតូចតាចដូចនេះ? គឹមសាន្ត បានប្រាប់ថា ពេលនោះ គាត់ជួប យាយចែម ដោយផ្ទាល់ទេ ។

គឹមសាន្ត រៀបរាប់ថា នៅពេលគាត់នៅក្នុងកងកុមារ មានការសម្លាប់មនុស្សយ៉ាងឃោរឃៅបំផុតនៅមុខក្មេងៗ ហើយធ្វើឲ្យគាត់មានអារម្មណ៍តក់ស្លុតយ៉ាងខ្លាំង ។ គាត់នៅតែព្រឺសម្បុរនៅឡើយ ពេលដែលរំឭករឿងនេះឡើងវិញម្ដងៗ ។ គឹមសាន្ត នៅចាំថាខ្មែរ ក្រហមបាននាំកុមារតូចៗនៅវត្តប៉ោយស្វាយទៅមើលឈ្លបពេលគេវាយមនុស្សចោលម្ដងៗ ។ គឹមសាន្ត បានឃើញកងឈ្លបសម្លាប់មនុស្សពីរដងដោយកងឈ្លបនេះឲ្យអ្នកទោសជីករណ្ដៅខ្លួនឯង ហើយឲ្យក្មេងៗពទ្ធ័វង់ជុំវិញ ហើយស្រែកប្ដេជ្ញាមិនយកគំរូតាម ។ បន្ទាប់ពីស្រែកចប់ ឈ្លបយកត្បូងចប និងក្ដៅរទេះវាយលើកញ្ចឹងក ប៉ុន្តែពេលពេលឈ្លបយាដៃវាយ គាត់មិនហ៊ានមើលទេ គឺគាត់បែរមុខចេញ ហើយបន្ទាប់ពីវាយរួចទើបឈ្លបយកដីមកកប់ ។ លើកទីមួយដែល គឹមសាន្ត បានចូលរួមនោះគឺកងឈ្លបយកមនុស្សពីរនាក់ទៅសម្លាប់ដោយអ្នកទោសនោះស្លៀកខោខ្លីនិងអត់ពាក់អាវ ។ លើកទីពីរ កងឈ្លបយកមនុស្សម្នាក់ទៅសម្លាប់ ប៉ុន្តែ ដោយសារគាត់នៅក្មេងពេកគាត់មិនបានចាំឈ្មោះអ្នកទោសនោះទេ ។ គឹមសាន្តដឹងតាមរយៈប្រជាជននៅក្នុងភូមិថា អ្នកដែលឈ្លបយកទៅសម្លាប់នោះគឺ លួចអាហារហូប ។

ខ្មែរក្រហមឲ្យក្រុមក្មេងៗទាំងអស់ទៅមើលការសម្លាប់ផ្ទាល់នោះគឺដើម្បីកុំឲ្យយកគំរូអាក្រក់តាមអ្នកប្រព្រឹត្តកំហុសទាំងនោះ ។ ខ្មែរក្រហមបានចាត់ទុកក្មេងៗថា ជាអ្នកដែលបរិសុទ្ធសម្រាប់បដិវត្តន៍ដោយប្រៀបក្មេងៗទាំងនោះទៅនឹងក្រដាសសដែលមិនមាននិន្នាការនយោបាយអ្វីទាំងអស់ ។ ក្មេងទាំងអស់នោះហើយដែលជាអនាគតរបស់បដិវត្តន៍ បន្តការងារបដិវត្តន៍ ។ ដូច្នេះក្មេងត្រូវតែអប់រំឲ្យ បានត្រឹមត្រូវ និងហ្មត់ចត់បំផុត ។

គឹមសាន្ត រៀបរាប់ថា នៅពេលនោះគ្មាននរណាម្នាក់ដែលថាមិនស្គាល់ យាយចែម ទេ ហើយគ្រាន់ឮសូរឈ្មោះគាត់ប្រជាជនទាំងអស់នៅក្នុងភូមិខ្លាចគ្រប់គ្នា ។ គឹមសាន្ត បានស្ដាប់វិទ្យុដែលចាក់ផ្សាយពីបទសម្ភាសន៍ជាមួយ យាយចែម ដែលធ្វើឲ្យគាត់នៅចាំនិងនឹកឃើញឡើងវិញពេលដែល យាយចែម បានចាប់គាត់ចងនៅក្រោមផ្ទះបុរាណដោយសារតែគាត់ចង់ទៅជួបម្ដាយមុនថ្ងៃកំណត់ ។ ចំណែកក្មេងៗដែលត្រូវបានចាប់ចងជាមួយ គឹមសាន្ត ក៏គាត់មិនដែលបានជួបដែរ ក្រោយមកព្រោះបែកគ្នាអស់ហើយ ។

ចាប់តាំងពីរបបខ្មែរក្រហមដួលរលំទៅ គឹមសាន្ត បានត្រឡប់ទៅព្រះនេត្រព្រះដើម្បីតាមរកសាកសពលោកយាយរបស់គាត់ ព្រោះពេលនោះឪពុក និងពូរបស់គាត់ជាអ្នកកប់សពយាយរបស់គាត់ ។ ប៉ុន្តែ គួរឲ្យសោកស្ដាយ គឹមសាន្ត មិនអាចរកឃើញឆ្អឹងយាយរបស់គាត់ទេ គឺគាត់គ្រាន់តែយកដីនៅទីនោះមកខបកិច្ចប៉ុណ្ណោះ ព្រោះពេលនោះមានសាកសពជាច្រើនកប់ជាន់លើគ្នា ហើយមិនអាចចំណាំណាមួយពិតប្រាកដទេ ។

គឹមសាន្ត អះអាងថា ពេលដែលខ្មែរក្រហមដួលរលំទៅ នៅឆ្នាំ១៩៧៩ យាយចែម បានរត់ទៅនៅអូរជ្រៅជាកន្លែងដែលឪពុកគាត់ធ្វើជាមេឃុំ ។ យាយចែម បានសូមអង្វរឪពុកគាត់ឲ្យជួយលាក់ប្រវត្តិដែលគាត់ធ្លាប់ធ្វើការងារធំនៅក្នុងរបបខ្មែរក្រហម ។ ពេលនោះ ឪពុករបស់ គឹមសាន្ត ក៏បានយល់ព្រមទទួលពាក្យអង្វរកនោះ ដោយសារឪពុកគាត់ជាអ្នកប្រណិប័តន៍ធម៌ ។

**ហ៊ុយ សម្ផស្ស**

# បែកម្តាយបីឆ្នាំ ចំណាំមុខម្តាយលែងបាន

នៅ សុគន្ធ អាយុ៤៨ឆ្នាំស្រុកកំណើតស្រុកស្អាង ខេត្តកណ្តាល ជាគ្រូបង្រៀនប្រវត្តិសាស្ត្រនិងអក្សរសាស្ត្រខ្មែរនៅវិទ្យាល័យមួយក្នុងខេត្តកោះកុង ។



សុគន្ធ រៀបរាប់ថា "គាត់ បាន បែក ពី ម្តាយ របស់រយៈពេលឆ្នាំក្នុងរបបខ្មែរក្រហមរហូតធ្វើឲ្យគាត់លែងចាំមុខម្តាយ ។" សុគន្ធ មានបងប្អូនប្រាំមួយនាក់ និងឪពុកម្តាយជាអ្នកដែលមានទ្រព្យធននិងមានមុខមាត់នៅក្នុងភូមិដោយសាររបរធ្វើចម្ការនិងទិញដូរផ្លែកនៅសម័យ លន់ នល់ ។ នៅឆ្នាំ១៩៧៣ មានចលនាខ្មែរក្រហមនៅជុំវិញក្រុង ហើយមានកម្មាភិបាលខ្មែរក្រហមមួយចំនួនបានចូលទៅក្នុងភូមិរបស់គាត់ដើម្បីរៃអង្គាសលុយកាក់ ស្រូវអង្ករ និងថ្នាំពេទ្យពីប្រជាជន ។ ពេលនោះ ទោះបីឪពុករបស់ សុគន្ធ ស្ថិតក្នុងតំបន់ដែលគ្រប់គ្រងដោយរដ្ឋាភិបាល លន់ នល់ ក៏ដោយ ក៏គាត់តែងតែលួចខបត្តម្ភថវិកានិងថ្នាំពេទ្យដល់កងទ័ពរំដោះតាមរយៈខ្មែរក្រហមនៅក្នុងភូមិម្នាក់ដែលស្គាល់គាត់ដើម្បីយកផ្គត់ផ្គង់កម្លាំងតស៊ូប្រឆាំងនឹង លន់ នល់ ប៉ុន្តែអ្នកដែលទទួលយកទៅហើយមិនបានប្រគល់ឲ្យថ្នាក់លើទេ ។

យប់មួយ មានយោធាខ្មែរក្រហមមួយក្រុមបានមកគោះទ្វារផ្ទះ សុគន្ធ ពេលនោះឪពុកគាត់ក៏ចេញមកបើកទ្វារ ។ ភ្លាមនោះយោធាភ្ជង់កាំភ្លើងដាក់ឪពុកគាត់តែម្តងដោយចោទថាមិនបានជួយខបត្តម្ភដល់អង្គការ ។ ឃើញដូច្នេះម្តាយ សុគន្ធ ស្រែកតបទៅវិញថា "ប្តីខ្ញុំបានធ្វើអ្វីខុស?" ទោះបីយ៉ាងណាក៏យោធាទាំងនោះមិនស្តាប់ដែរ ហើយបានចាប់ឪពុក សុគន្ធ ទៅបាត់ ។

យប់នោះ ម្តាយរបស់ សុគន្ធ មានការភិតភ័យយ៉ាងខ្លាំង រួចហើយក៏នាំកូនទាំងអស់ចេញពីផ្ទះដែលសង់នៅក្នុងដីចម្ការទៅនៅផ្ទះមួយទៀត (មានចម្ងាយប្រមាណមួយគីឡូម៉ែត្រពីគ្នា) ដែលសង់នៅជាប់នឹងផ្លូវថ្នល់ ។ ដើរបានពាក់កណ្តាលផ្លូវស្រាប់តែម្តាយគាត់ឮសំឡេងយោធាខ្មែរក្រហមដើរតម្រង់មកផ្ទះគាត់ទៀតភ្លាមនោះគាត់ក៏បាននាំកូនៗរត់ទៅពួននៅគុម្ពចេករហូតយោធានោះដើរទៅផុតទើប គាត់បន្តដំណើរទៅមុខទៀត ។

រយៈពេលបីថ្ងៃក្រោយមក ម្តាយរបស់ សុគន្ធ បានរកឃើញសាកសពប្តីដែលខ្មែរក្រហមបាញ់ចោលនៅខាងក្រោយភូមិ ហើយគាត់ក៏យកមករៀបចំធ្វើបុណ្យតាមប្រពៃណី ។ បន្ទាប់ពីធ្វើបុណ្យសពប្តីរួច ម្តាយរបស់ សុគន្ធ បាននាំកូនៗទាំងអស់ទៅរស់នៅភ្នំពេញដោយសុំសំយ៉ាបផ្ទះម្តាយមីងខាងឪពុកដែលពេលនោះម្តាយមីងគាត់មានប្តីធ្វើទាហានពាក់សក្តិ៥ (និងជាអ្នកបើកយន្តហោះ) នៅមន្ទីរពេទ្យចិនដើម្បីធ្វើខ្ទមស្នាក់នៅបណ្តោះអាសន្ន ។ ការរស់នៅរបស់គ្រួសារ សុគន្ធ នៅភ្នំពេញជួបការលំបាកព្រោះម្តាយគាត់គ្មានមុខរបររកស៊ី ហេតុដូច្នេះហើយទើបក្រោយមកម្តាយ សុគន្ធ យក សុគន្ធ ទៅផ្ញើនឹងប្អូនបង្កើតរបស់គាត់ (ម្តាយមីងខាងម្តាយ) ដែលប្រកបរបរលក់សាច់ជ្រូកនៅផ្សារកណ្តាល ។ ចំណែកបងៗបីនាក់ទៀត ម្តាយ សុគន្ធ យកទៅផ្ញើជាមួយនឹងបងប្អូនផ្សេងទៀតដោយប្អូនៗពីរនាក់ប៉ុណ្ណោះទៅនៅជាមួយនៅខេត្តបាត់ដំបង ។

សុគន្ធ រស់នៅជាមួយម្តាយមីងរហូតដល់ខ្មែរក្រហមវាយចូលដល់ទីក្រុងភ្នំពេញ ។ ពេលនោះ បងប្រុសទីមួយរបស់ សុគន្ធ បានដើរប្រមូលប្អូន (បងស្រីទីពីរ និងបងស្រីទីបី) រួមទាំង សុគន្ធ ដែលទើបមានអាយុប្រាំឆ្នាំមកជុំគ្នា រួចធ្វើដំណើរជាមួយគ្រួសារម្តាយមីង និងអ៊ំជាច្រើនគ្រួសារទៀតចេញទៅតាមស្ពានមុន្នីវង្ស ហើយឆ្លងទៅផ្លូវជាតិលេខ១ ។ សុគន្ធ មានការភ័យខ្លាចយ៉ាងខ្លាំងដោយសារគាត់ឃើញសាកសពនៅពាសពេញផ្លូវ ។ បងប្អូន សុគន្ធ បានធ្វើដំណើរទៅដល់វត្តត្រើយស្លា (ស្ថិតក្នុងស្រុកកៀនស្វាយ) និងបានសម្រាកនៅទីនោះ ។

នៅទីនោះបានមួយរយៈ ខ្មែរក្រហមបានយកឡានទៅដឹកបងប្អូនគាត់ទាំងបួននាក់ រួមទាំងគ្រួសារ ម្តាយមីងមួយគ្រួសារ និងគ្រួសារជម្លៀសផ្សេងទៀតត្រឡប់មកវិញ ។ មកដល់ក្រុងភ្នំពេញ

អ្នកជិះក្នុងឡានទាំងអស់បានស្រែកព្រមថា “មកដល់ភ្នំពេញៗ” ។ ពេលនោះ សុគន្ធ បានខំប្រឹងសម្លឹងចេញទៅខាងក្រៅខាងដើម្បីរកមើល ប៉ុន្តែគាត់មិនបានឃើញអ្វីទាំងអស់ព្រោះងងឹតមើលពុំយល់ដោយមិនមានភ្លើងអគ្គិសនីដូចមុនទេ ។

ខ្មែរក្រហមបានដឹកប្រជាជនទាំងអស់ មកដាក់នៅស្ថានីយ៍រថភ្លើងស្ថិតនៅម្តុំផ្សារថ្មីដើម្បីជម្លៀសបន្តទៅខេត្តបន្ទាយមានជ័យ ។ នៅតាមផ្លូវ សុគន្ធ មិនបានចាំរឿងរ៉ាវកើតឡើងទេ ព្រោះគាត់នៅក្មេងពេក ម្យ៉ាងទៀតដោយសារគាត់ដេកលក់នៅពេលធ្វើដំណើរ ។ នៅពេលមកដល់ផ្សារស្វាយស៊ី ទើប សុគន្ធ ដឹងខ្លួន ហើយបងប្អូន និងគ្រួសារម្តាយមីងចុះពីលើ រទេះភ្លើង ។

បន្ទាប់មក ខ្មែរក្រហមយករទេះគោមកដឹកយកទៅដាក់នៅភូមិមួយគឺភូមិរំពាក់ស្ថិតនៅឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះតំបន់៥ ដែលមានចម្ងាយប្រមាណ១៩គីឡូម៉ែត្រពីស្វាយស៊ីសុផុន ។ សុគន្ធ នៅចងចាំថា ភូមិមួយចំនួននៅតំបន់នោះ ដូចជាគោកគ្រាច សំរោងទ្រាស ភូមិពង្រ ភូមិស្រមោច ពេលដែលគាត់ទៅដល់ ។ នៅទីនោះ សុគន្ធ ឃើញមានវាលស្រែល្វឹងល្វើយលាតសន្ធឹងដាច់កន្ទុយភ្នែកនិងមានដើមឈើដុះខៀវស្រងាត់ ។

ខ្មែរក្រហមបានបំបែកឲ្យ សុគន្ធ រស់នៅជាមួយបងស្រីទីពីរ (អាយុ១៨ឆ្នាំ) ចំណែកបងប្រុស និងបងស្រីទីបីទៅធ្វើការនៅក្នុងកងចល័ត ។ មូលហេតុដែលប្រធានកងមិនបានបញ្ជូនបងស្រី សុគន្ធ ឲ្យទៅធ្វើការនៅកងចល័ត ព្រោះគាត់ត្រូវនៅមើលថែ សុគន្ធ ដែលគ្មានម្តាយនៅជាមួយ ។ ខ្មែរក្រហមបានចាត់ទុកបងស្រីទីពីររបស់ សុគន្ធ ជាស្ត្រីមេម៉ាយ ហើយឲ្យទៅនៅជាមួយកងម៉ែៗក្នុងភូមិ ។

សុគន្ធ បានរៀបរាប់ថា ប្រធានភូមិបានហៅ សុគន្ធ និងក្មេងនៅក្នុងទាំងអស់ឲ្យទៅរៀននៅរោងធំមួយក្នុងភូមិដោយគ្រូសរសេរអក្សរលើក្តាខៀន រួចហើយឲ្យសិស្សដែលកកកុញនៅក្នុងរោងនោះអាន ។ ប៉ុន្តែ សុគន្ធ មិនដឹងថាគ្រូសរសេរពីអ្វីទេព្រោះគាត់ដែលបានចូលសាលាពីមុនមក ។ ហេតុដូច្នេះហើយទើបនៅថ្ងៃបន្ទាប់មកគាត់ឈប់ទៅរៀន ។

សុគន្ធ បន្ថែមថា ការរស់នៅរបស់គាត់មិនសូវជាមានការលំបាកខ្លាំងទេ ព្រោះប្រជាជនមូលដ្ឋាននៅភូមិរំពាក់នោះមានសណ្តានចិត្តល្អនិងតែងតែជួយអ្នកដែលជម្លៀសទៅថ្មី ។ មានថ្ងៃមួយ សុគន្ធ បានទៅតាមបងប្រុសដែលធ្វើការនៅការដ្ឋាននៅព្រៃឆ្ងាយ ប៉ុន្តែដោយសារនឹកផ្ទះខ្លាំងពេក គាត់ក៏ត្រឡប់មកវិញ ។ ពេលមកដល់ភូមិវិញ អ្នកភូមិម្នាក់បាននាំ សុគន្ធ ទៅហូបបាយនៅរោងបាយសហករណ៍ដោយសារការអាណិតអាសូរមកលើរូបគាត់ ។ ប៉ុន្តែ ចុងភៅមិនបានបើករបបអាហារឲ្យទេដោយប្រាប់ថាគាត់មិនមានរបប ។ ឃើញដូច្នេះ អ្នកមូលដ្ឋាននោះបានប្រាប់ចុងភៅថាឲ្យយករបបរបស់គាត់ចែកទៅឲ្យ សុគន្ធ ហូបវិញ ។ រហូតមកដល់សព្វថ្ងៃ សុគន្ធ នៅនឹកឃើញពីអំពើរបស់អ្នកមូលដ្ឋាននោះដែលគាត់តែងតែហៅថា“ម៉ែទួន” ។

ក្រៅពីរបបអាហារដែលអង្គការចែកឲ្យ សុគន្ធ បានទៅបេះត្រកួន និងជីកដំឡូង ដើររើសក្តាម ខ្យង មកស្ងោរហូបជាមួយបបរ ។ ហេតុដូច្នេះ ពេលប្រធានភូមិហៅបងប្រុសរបស់ សុគន្ធ ទៅជួយកិនស្រូវម្តងៗគាត់តែងតែសុំអង្ករមួយកញ្ជើរដោយប្រាប់ថាយកមកដុតតាមពិតគាត់លួចយកអង្ករទៅបង្កប់នៅក្រោមអង្គាមនោះដើម្បីយកឲ្យប្អូនៗដាំបាយហូប ។ ចំណែក បងស្រីទីបី សុគន្ធ ដែលមានរូបរាង មនុស្សប្រុស និងមានអាយុបង សុគន្ធ (៨ឆ្នាំ) តែងតែនាំ សុគន្ធ ទៅរកកណ្តុរនៅវាលស្រែពេលសម្រាកពីការងារ ។ មុននឹងជីករន្ធកណ្តុរ សុគន្ធ បានដើរបិទរន្ធបង្ហុយព្រោះខ្លាចកណ្តុររត់ចេញទើបបងស្រីគាត់ ចាប់ផ្តើមជីកដោយមួយពេលៗបងប្អូនគាត់រកបានពីបួនទៅដប់កណ្តុរ ទើបត្រឡប់មកផ្ទះវិញ ។

ក្រោយមកទៀត ដោយសារខ្វះខាតរបបអាហារ បងស្រីទីបីរបស់ សុគន្ធ បាននាំ សុគន្ធ ទៅលួចបូតស្រូវ ។ សុគន្ធ បានចូលទៅបូតក្នុងវាលស្រែដើម្បីកុំឲ្យឈ្លបមើលឃើញព្រោះពេលនោះគាត់ទាប ហើយមានដើមស្រូវខ្ពស់ៗបាំង ចំណែកបងស្រីគាត់នៅលើភ្លឺស្រែ ។ ចៃដន្យថ្ងៃនោះ ឈ្លបខ្មែរក្រហម ម្នាក់បានមកទាន់ និងរត់ដេញចាប់ ភ្លាមនោះបងស្រី សុគន្ធ ក៏រត់ចោលគាត់ ។ រីឯ សុគន្ធ ដែលទើបនឹងដឹងខ្លួនក៏រត់តាមក្រោយ ប៉ុន្តែសំណាងល្អឈ្លបនោះបានរអិលដួលធ្លាក់ស្រែទើប សុគន្ធ បានរួចខ្លួន ។

ថ្ងៃមួយ មានក្មេងប្រុសជំទង់ម្នាក់បានទៅលួចពោតនៅចម្ការក៏ត្រូវឈ្លបចាប់បាន ហើយយកផ្លែពោតនោះចងពាក់នឹងកក្មេងប្រុសនោះ ហើយឲ្យស្រែកប្រាប់អ្នកភូមិពីកំហុសដែលបានប្រព្រឹត្តិ ។ មានអ្នកភូមិក្មេងៗ រួមទាំង សុគន្ធ ផងបានស្រែកបន្ទរ

ជាមួយការសើចលេងសប្បាយ ព្រោះពេលនោះគាត់នៅក្មេង មិនដឹងថាមានរឿងអ្វីកើតឡើងនោះទេ ។ បន្ទាប់ពីស្រែកចប់ ខ្មែរក្រហមបានយកប្រុសនោះទៅសម្លាប់ចោលនៅក្រោយផ្ទះចោលទៅ ។

រយៈពេលពីបីថ្ងៃក្រោយ ចាស់ៗនៅក្នុងភូមិនាំគ្នាផ្អើលទៅមើលរណ្តៅសាកសពក្មេងប្រុសនោះដែលហើមព្រោះឈូបកប់មិនជិត ។ ក្រោយពីព្រឹត្តិការណ៍នេះ សុគន្ធ បានទៅមើលសាកសពនោះដែរ ដែលធ្វើឲ្យគាត់ភ័យខ្លាច និងរន្ធត់យ៉ាងខ្លាំង ។ ថ្ងៃមួយត្រឡប់ពីការដ្ឋានវិញ បងប្រុសទីមួយរបស់ សុគន្ធ ក៏បានប្រាប់ សុគន្ធ ពីការសម្លាប់មនុស្សដោយគាត់រៀបរាប់ថា មានអ្នកធ្វើការនៅកងចល័តពីរនាក់បានធ្វើខុសសីលធម៌ ។ ក្រោយមក ប្រធានកងបានដឹងបានក៏យកកងចល័តទាំងពីរនាក់ទៅចងផ្អោបនឹងដើមឈើនៅចំពោះមុខមហាជន បន្ទាប់មកបានយកកាំបិតវះពោះម្តង ។

នៅក្នុងភូមិ ក្មេងៗជាច្រើនរួមទាំងអ្នកមូលដ្ឋានបានកើតពិសដំបៅហើម ហើយអ្នកទាំងនោះកម្រនឹងបានជាណាស់ព្រោះពុំមានថ្នាំព្យាបាល ។ អ្នកជំងឺនេះមួយចំនួនដែលអត់អាហារបានហូបសាច់គោ (តាមទម្លាប់អ្នកកើតជំងឺនេះគេមិនឲ្យហូបសាច់គោទេ ។) បន្ទាប់ពីបរិភោគរួចអ្នកជំងឺនោះស្លាប់តែម្តង ។ សុគន្ធ បន្តថា នៅក្នុងភូមិគ្មានមន្ទីរពេទ្យទេ ហើយយូរៗម្តង គាត់ឃើញពេទ្យយកថ្នាំដបទឹកទៅចាក់ឲ្យអ្នកជំងឺក្នុងភូមិ ប៉ុន្តែគាត់មិនដឹងថាអ្នកជំងឺបានធូរស្បើយនោះទេ ។

ពេលមួយ បងប្អូនរបស់ សុគន្ធ ទាំងបួននាក់បានធ្លាក់ខ្លួនឈឺគ្រុនចាញ់ ហើយរៀងរាល់ព្រឹក គាត់តែងនាំគ្នាមកហាលថ្ងៃព្រោះរងារខ្លាំង ។ ឃើញដូច្នេះ នារីសេនាជនម្នាក់ដែលធ្លាប់ស្គាល់និងធ្លាប់ ស្រឡាញ់បងប្រុសបានយកថ្នាំពីរគ្រាប់មកឲ្យ សុគន្ធ និងបងស្រីទីបីរបស់គាត់លេប ចំណែកបងប្រុសទីមួយ និងបងស្រីទីពីរបានទៅឲ្យគ្រូខ្មែរអុជទើបបងប្អូនគាត់បានជាសះស្បើយ ។

នៅចុងឆ្នាំ១៩៧៨ ប្រធានកងកុមារបានចាត់តាំង សុគន្ធ និងកងកុមារនៅក្នុងភូមិឲ្យជញ្ជូនកណ្តាប់ស្រូវដាក់លើរទេះរួចដឹកចេញពីភូមិយកទៅដាក់កន្លែងមួយ (មិនចាំឈ្មោះ) ស្ថិតនៅជិតស្ពាយស៊ីសុផុនដោយពេលនោះគាត់ត្រូវរស់នៅបែកពីបងស្រី ។ នៅទីនោះបានមួយរយៈ សុគន្ធ ក៏ទៅសុំប្រធានកងដោយសារតែគាត់នឹកបងស្រីនិងនឹកភូមិដែលគាត់ធ្លាប់រស់នៅខ្លាំងពេក ប៉ុន្តែ ប្រធានកងបានបដិសេធ ។ ខណៈនោះ សុគន្ធ និងកូនអ្នកមូលដ្ឋានម្នាក់ទៀតបានសម្រេចចិត្តរត់ចេញពីកង ។ មកដល់ភូមិ បងរបស់ៗរបស់ សុគន្ធ ត្រេកអរនិងសប្បាយរីករាយយ៉ាងខ្លាំងព្រោះឃើញប្អូនត្រឡប់មកវិញ និងបានសួរនាំ សុគន្ធ ពីការដែលរត់ចេញពីកង ។ ពេលនោះ បងស្រីរបស់ សុគន្ធ បានឃាត់មិនឲ្យគាត់ត្រឡប់ទៅកងវិញទេ ។ ស្រាប់តែមួយថ្ងៃក្រោយមក សុគន្ធ ឃើញប្រធានកងបញ្ជូនកុមារៗចូលមកភូមិវិញទាំងអស់ដោយសារពេល នោះសភាពការណ៍កាន់តែច្របូលច្របល់ខ្លាំង ។ សុគន្ធ និងបងៗក៏បានធ្វើដំណើរដោយថ្មើរជើងត្រឡប់មករកស្រុកកំណើត ។ ប៉ុន្តែ ពេលខ្លះ សុគន្ធ បានឡើងជិះលើអង្រែកដែលមានបងៗជាអ្នករែក ។ សុគន្ធ និងបងៗបានមកស្នាក់នៅបាត់ដំបងមួយរយៈដើម្បីតាមស្វែងរកម្តាយដែលចេញមករកស៊ីនៅខេត្តនេះតាំងពីឆ្នាំ១៩៧៥ម្ល៉េះ ។ រៀងរាល់ព្រឹក បងៗរបស់ សុគន្ធ បានចេញទៅបង់សំណាញ់ ហើយថ្ងៃត្រង់ ទើបត្រឡប់មកវិញដោយមានទាំងឃ្លូរត្រីមកជាមួយផងដើម្បីធ្វើម្ហូប ។ ប៉ុន្តែ ថ្ងៃមួយ សុគន្ធ បានរងចាំបងរបស់គាត់រហូតដល់ថ្ងៃរសៀល ដោយមិនឃើញត្រឡប់មកផ្ទះវិញ ។ សុគន្ធ មានការភ័យខ្លាច និងបារម្ភយ៉ាងខ្លាំង ហើយជាញឹកញាប់គាត់អើតមើលពីមាត់ទ្វារទៅរកផ្លូវ ។

មួយសន្ទុះក្រោយមក សុគន្ធ ឃើញបងរបស់គាត់បណ្តើរស្ត្រីចំណាស់ពីរនាក់តម្រង់មកផ្ទះ ។ ពេលមកដល់ផ្ទះ ស្ត្រីម្នាក់បានស្រែកហៅ សុគន្ធ ថា«កូន» ប៉ុន្តែ សុគន្ធ មិនចំណាំ និងស្គាល់ថាគាត់ជានរណាទេ ហើយ សុគន្ធ បែរជាភ័យខ្លាចនឹងរត់ឱបបងស្រីវិញ ។ ភ្លាមនោះបងស្រីរបស់ សុគន្ធ ប្រាប់ សុគន្ធ ថាជាម្តាយ ទើបគាត់ស្គាល់ ។ ម្តាយរបស់ សុគន្ធ បានយំយ៉ាងខ្លាំងហើយរត់ទៅឱបគាត់ដោយក្តីនឹករលឹក ។ សុគន្ធ រៀបរាប់ថា តាំងពីម្តាយគាត់បែកចេញទៅនៅបាត់ដំបង គាត់មានតែបងស្រីប៉ុណ្ណោះជាអ្នកមើលថែទាំង ហើយគាត់ មានអារម្មណ៍ថាបងស្រីគាត់ដូចជាម្តាយគាត់អ៊ីចឹងដែរ ។ គ្រួសារ សុគន្ធ ដើរពីបាត់ដំបងត្រឡប់មកមកស្រុកកំណើត ។ មកដល់តាខ្មៅ សុគន្ធ បានជួបយាយ ហើយបានទៅរស់នៅជាមួយគាត់រយៈទើបប្តូរមករស់នៅភ្នំពេញ ។ ពេលនោះ សុគន្ធ ក៏សុំគ្រូចូលរៀននៅសាលាវត្តព្រះពុទ្ធ និងរៀនបន្តនៅសាលាបាក់ទូក ។

ក្រោយមក បងស្រីដែលមានប្តី ហើយទៅរស់នៅខេត្ត

កោះកុងបានហៅគាត់ទៅនៅជាមួយ ហើយគាត់ក៏ត្រូវផ្លាស់រៀននៅទីនោះរហូតដល់បានប្រលងជាប់បាក់ឌុបនៅឆ្នាំ១៩៩៣ ។ នៅឆ្នាំដដែល សុគន្ធ បានប្រលងចូលរៀនគ្រូបឋមសិក្សារយៈពេលពីរឆ្នាំនិងចេញទៅបង្រៀនរយៈពេលប្រាំបួនឆ្នាំទើបរៀនបន្ថែមដើម្បីបំពេញក្របខណ្ឌជាគ្រូមធ្យមសិក្សា (គ្រូអនុវិទ្យាល័យ) វិញ ។

នៅឆ្នាំ២០១១ សុគន្ធ បានប្រឡងផ្លាស់ប្តូរក្របខណ្ឌម្តងទៀតពីគ្រូមធ្យមសិក្សាមកគ្រូវិទ្យាល័យ ហើយបច្ចុប្បន្នគាត់ជាគរុនិស្សិតនៅវិទ្យាស្ថានជាតិអប់រំ ។

សុគន្ធ បានបញ្ជាក់ថា មូលហេតុដែលគាត់ចង់រៀនផ្នែកប្រវត្តិវិទ្យាព្រោះវាជាចំណង់ចំណូលចិត្តរបស់គាត់ដែលចង់រឿងរ៉ាវដែលបានកើតឡើង ។ គាត់បន្តថា ប្រវត្តិវិទ្យាមានសារប្រយោជន៍ដោយធ្វើឲ្យគាត់ដឹងពីអតីតកាល ហើយយើងនឹងទទួលបានបទពិសោធន៍ក្នុងសម័យកាលនីមួយៗ ។

នៅអំឡុងពេលចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការបង្រៀន «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩» រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយវិទ្យាស្ថានជាតិអប់រំ សុគន្ធ បានឲ្យដឹងថា វគ្គបណ្តុះបណ្តាលបានធ្វើឲ្យគាត់កាន់តែមានចំណេះដឹងថែមទៀតពីវិធីសាស្ត្រដែលគ្រូខ្ទេសបានណែនាំគាត់ ។ សុគន្ធ បន្តថា ជាការប្រសើរដែលគាត់បានទទួលនូវបទពិសោធន៍ថ្មីៗគួបផ្សំនឹងវិធីសាស្ត្រដែលគាត់មានស្រាប់ដើម្បីបង្រៀនសិស្សឲ្យឆាប់យល់ ។

សុគន្ធ លើកឡើងថា គាត់បានយករឿងរ៉ាវនៅសម័យខ្មែរក្រហមប្រាប់ទៅក្មួយ ប៉ុន្តែគេមិនជឿនោះទេ ។ ហេតុដូច្នេះហើយដោយសារចង់ប្រាប់ការពិតដល់ក្មួយគាត់បានហៅក្មួយរបស់គាត់ទៅជួបនឹងអ្នកដែលធ្លាប់ជួយគាត់ និងទៅមើលកន្លែងដែលធ្វើការងារនិងរស់នៅនៅភូមិរំពាក់ ឃុំឈ្នួរមានជ័យ ស្រុកព្រះនេត្រព្រះ ទើបគេជឿ ។ ដូចគ្នាដែរ គាត់នឹងយកបទពិសោធន៍ដែលគាត់ឆ្លងកាត់និងបានរៀនសូត្រនៅក្នុងថ្នាក់ទៅចែករំលែកជាមួយសិស្សនៅពេលគាត់ចេញទៅបង្រៀន ។

**សោម ប៊ុនថន**



នៅ សុគន្ធ កំពុងបង្រៀនសាកល្បងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅវិទ្យាស្ថានជាតិអប់រំ

# ខ្សែសង្វាក់នៃការចាប់ខ្លួនមនុស្សនៅក្រសួងការបរទេស

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ គឺជាថ្ងៃទីបី ដែលអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី រចឹម ទន់ ជាអតីតកម្មាភិបាលជាន់ខ្ពស់ម្នាក់នៅក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងសវនាការនេះ សាក្សី រចឹម ទន់ផ្តល់សក្ខីកម្មជាច្រើនអំពីរឿងរ៉ាវដែលបានកើតនៅក្នុងក្រសួងការបរទេសជាពិសេសពាក់ព័ន្ធនឹងខ្សែសង្វាក់នៃការចាប់ខ្លួនកម្មាភិបាលនិងបុគ្គលិកនៅក្នុងក្រសួងមួយនេះ ។ រចឹម ទន់ ហៅ ភី ភួន ហៅ ចៀម អាយុ ៦៥ឆ្នាំ មានស្រុកកំណើតនៅភូមិកែប ឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនៈគិរី បច្ចុប្បន្នរស់នៅស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ រចឹម ទន់ ចូលរួមក្នុងចលនាបដិវត្តន៍ចាប់ពីឆ្នាំ១៩៦៣ ហើយសម្រេចចូលព្រៃតស៊ូក្នុងឆ្នាំ១៩៦៦ ។ ក្នុងឆ្នាំ១៩៦៧ គាត់បានជួប ប៉ុល ពត នៅមន្ទីរ១០០ និង អៀង សារី នៅមន្ទីរ១០២ ដែលមន្ទីរទាំងពីរនេះមានទីតាំងនៅខេត្តរតនៈគិរី ។

ឆ្នាំ១៩៧០បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចព្រះបាទនរោត្តម សីហនុ ចេញពីអំណាច រចឹម ទន់ បានផ្លាស់ទីលំនៅមកស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដោយមានតួនាទីជានិរសារផ្ទាល់របស់ ប៉ុល ពត ។ រហូតមកដល់ឆ្នាំ១៩៧៣ រចឹម ទន់ បានមកស្នាក់នៅជាមួយ ប៉ុល ពត នៅមន្ទីរប-៥ ដែលមានទីតាំងក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ មន្ទីរនេះគឺជាបញ្ជាការដ្ឋានទ័ពសមរភូមិជួរមុខទូទាំងប្រទេសកម្ពុជាដែលគ្រប់គ្រងលើសមរភូមិផ្សេងៗទៀតក្នុងការវាយយកទីក្រុងភ្នំពេញ ។ អំឡុងពេលនោះ រចឹម ទន់ មានតួនាទីជានិរសារ និងជាកងការពារសន្តិសុខសម្រាប់ ប៉ុល ពត ។ ការងាររបស់គាត់គឺបញ្ជូនសំបុត្រពី ប៉ុល ពត ប្រគល់ជូនមន្ទីរបញ្ជាការដ្ឋានសមរភូមិផ្សេងៗទៀត ដែលដឹកនាំដោយ តាម៉ុក, សុន សេន, វ៉ន វេត, កុយ ធួន និង នួន ជា នៅមន្ទីរ៧៤ ជិតស្ទឹងត្រង់) ។ ជាពិសេសគាត់ត្រូវអមដំណើរនិងការពារសន្តិសុខជូនកិច្ចប្រជុំដែលធ្វើដោយ ប៉ុល ពត, នួន ជា, ខៀវ សំផន និងមេដឹកនាំផ្សេងៗទៀត ដែលពិភាក្សាអំពីការវាយរំដោះយកទីក្រុងភ្នំពេញនិងការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុង ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រចឹម ទន់ ត្រូវបានចាត់តាំងឲ្យបំពេញការងារនៅក្រសួងការបរទេស(មន្ទីរប-១) ដោយមានតួនាទីជាអ្នកទទួលនិងជូនដំណើរគណៈប្រតិភូបរទេសទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានទូទាំងប្រទេសកម្ពុជា ។ ជាងនេះទៅទៀត រចឹម ទន់ បានអមដំណើរមេដឹកនាំជាន់ខ្ពស់របស់បក្សដូចជា ប៉ុល ពត, នួន ជា, អៀង សារី ចុះទៅធ្វើទស្សនកិច្ចនៅតាមមូលដ្ឋានជាញឹកញ៉ាប់ ។ ក្រៅពីនេះ គាត់មានតួនាទីជានិរសារនាំសំបុត្រពី អៀង សារី ប្រគល់ជូនមេដឹកនាំផ្សេងទៀតដូចជា ប៉ុល ពតនៅមន្ទីរ (ក-១), នួន ជា នៅមន្ទីរ (ក-៣), ខៀវ សំផន ក្នុងឋានៈជាប្រធានមន្ទីរ៨៧០ បន្ទាប់ពី ឌឿន បាត់ខ្លួន), វ៉ន វេត នៅក្រសួងពាណិជ្ជកម្ម) និង សុន សេន នៅក្រសួងការពារជាតិ) ។ ការងារសំខាន់មួយទៀតគឺគាត់ជាអ្នកនាំយកកម្មាភិបាលនិងបុគ្គលិកនៅក្រសួងការបទេសអ្នកទោសដែលត្រូវបានគេសង្ស័យថាជាប់ខ្សែស្រឡាយសេ. អ៊ី. អា ឬ កា. ហ្សេ. បេ ឬជា (យួនឈ្លានពានទឹកដី) ក្រោមការណែនាំរបស់ អៀង សារី និង សួ ហុង ដើម្បីប្រគល់ជូនមន្ទីរ៨៧០ ។ សួ ហុង ហៅ សាឡុត បាន (ក្មួយរបស់ ប៉ុល ពត) ដែលជាអតីតអគ្គលេខាធិការក្រសួងការបរទេសក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានផ្តល់សក្ខីកម្មជូនអង្គជំនុំជម្រះថា រចឹម ទន់) ដែលជាអនុប្រធានរបស់ខ្លួនគឺជាអ្នកនាំខ្លួនបុគ្គលដែលត្រូវបានចាត់ទុកថាមានសមាសភាពមិនល្អនៅក្នុងក្រសួងការបរទេសប្រគល់ជូនមន្ទីរ៨៧០ ។ ក្នុងឋានៈជាកម្មាភិបាលជាន់ខ្ពស់ម្នាក់ រចឹម ទន់ បានបំពេញការងារយ៉ាងស្អិតរមួតជាមួយថ្នាក់លើរបស់ខ្លួនពោលគឺគាត់បានទទួលការណែនាំពី អៀង សារី និង សួ ហុង ក្នុងការអនុវត្តការងាររបស់ខ្លួន ហើយគាត់តែងតែរាយការណ៍ជាប្រចាំអំពីការងាររបស់គាត់ទៅ អៀង សារី ជារៀងរាល់ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ។

នៅចំពោះមុខអង្គជំនុំជម្រះ រចឹម ទន់ បានស្រាយបំភ្លឺអំពី




ខ្សែសង្វាក់នៃការបញ្ជានិងការសម្រេចដែលនាំឲ្យមានការចាប់ខ្លួនកម្មាភិបាលនិងបុគ្គលិកជាច្រើននៅក្រសួងការបរទេស ។ រចឹម ទន់ បានរំឭកថា ក្នុងឆ្នាំ១៩៧៧និងឆ្នាំ១៩៧៨មានការចាប់ខ្លួនកម្មាភិបាលនិងបុគ្គលនៅក្រសួងការបរទេសក្នុងទ្រង់ទ្រាយធំ ។ មូលហេតុនៃការចាប់ខ្លួននេះគឺដោយសារមានការឆ្លើយដាក់ពីអ្នកទោសនៅមន្ទីរស-២១ថា បុគ្គលទាំងនោះមានការជាប់ពាក់ព័ន្ធនឹងខ្សែរបស់ សេ. អ៊ី. អា ឬ កា. ហ្សេ. បេ ឬជាយួនឈ្មានពានទឹកដី ។ រចឹម ទន់ បញ្ជាក់ថា ចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរស-២១ ដែលមានការជាប់ពាក់ព័ន្ធនឹងបុគ្គលដែលធ្វើការនៅក្រសួងការបទេសត្រូវបាន កាំង ហ្កេកអ៊ាវ ហៅ ឌុចប្រធានមន្ទីរស-២១ ប្រគល់ជូនមន្ទីរ៨៧០ ហើយមន្ទីរនេះបញ្ជូនបន្តឲ្យក្រសួងការបរទេសដើម្បីឲ្យ អៀង សារី ពិនិត្យ ។ ការជូនដំណឹងពីមន្ទីរ៨៧០ ទៅ អៀង សារី អំពីបុគ្គលដែលមានសមាសភាពមិនល្អនៅក្រសួងការទេសគឺភាគច្រើនធ្វើឡើងដោយ ប៉ុល ពត និង នួន ជា ។ បន្ទាប់ពីទទួលបានបញ្ជីឈ្មោះបុគ្គលដែលមានសមាភាពមិនល្អទាំងនោះ អៀង សារី ជាអ្នកធ្វើការកំណត់អំពីអត្តសញ្ញាណដោយបញ្ជាក់ពីតួនាទីនិងផ្នែកដែលបុគ្គលនោះទទួលបន្ទុកនៅក្នុងក្រសួងការបរទេស ។ បន្ទាប់មកបុគ្គលទាំងនោះនឹងត្រូវបានក្រសួងការបរទេសបញ្ជូនឲ្យអង្គភាពយោធា“យ-១០” ។ រចឹម ទន់ បន្ថែមថា អង្គភាពយោធា“យ-១០” គឺជាអង្គភាពដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ ។ អង្គភាពនេះដឹកនាំដោយ ហាន និង វ៉ាន់ ហើយទទួលបន្ទុកជាពិសេសគឺការពារសន្តិសុខជូនថ្នាក់មជ្ឈិម ។

ចំពោះវិធីសាស្ត្រក្នុងការចាប់ខ្លួនកម្មាភិបាល និងបុគ្គលនៅក្រសួងការបរទេស រចឹម ទន់ បញ្ជាក់ថា នៅពេលមានការជូនដំណឹងឬមានផែនការចាប់ខ្លួនបុគ្គលណាម្នាក់ បុគ្គលនោះនឹងត្រូវបានគេប្រាប់ជាមុនមិនឲ្យទៅណាឡើយពោលគឺត្រូវមានវត្តមាននៅក្នុងក្រសួង ។ បន្ទាប់មកបុគ្គលទាំងនោះនឹងត្រូវបាននាំខ្លួនទៅក្រៅបរិវេណក្រសួងដើម្បីប្រគល់ជូនអង្គភាពយោធា “យ-១០” រចឹម ទន់ បន្ថែមថា ជាទូទៅ អៀង សារី និង សូ ហុង ជាអ្នកណែនាំគាត់ឲ្យយកបុគ្គលដែលនឹងត្រូវចាប់ខ្លួនចេញទៅក្រៅក្រសួងដើម្បីប្រគល់ជូនអង្គភាពយោធា “យ-១០” នៅទីតាំងជាក់លាក់ណាមួយដែលបានកំណត់ទុកជាមុន ។ អង្គភាពយោធា“យ-២១”កម្រ


សាឡុត បាន ហៅ សូ ហុង

មកចាប់ខ្លួនអ្នកទោសដោយផ្ទាល់នៅក្នុងក្រសួងណាស់គឺរាល់ការចាប់ខ្លួនអ្នកទោសត្រូវធ្វើនៅក្រៅក្រសួង ។

ចុងក្រោយ របឹម ទន់ បញ្ជាក់ថា បុគ្គលទាំងអស់ដែលត្រូវបានក្រសួងការបរទេសប្រគល់ជូនមន្ទីរ៨៧០តាមរយៈអង្គភាពយោធា“យ-១០”គឺមិនដែលមានបុគ្គលណាម្នាក់បានវិលត្រឡប់មកក្រសួងការបរទេសវិញឡើយពោលគឺបុគ្គលទាំងនោះបានបាត់ខ្លួនរហូត ។ ប៉ុន្តែទោះបីជាយ៉ាងណា របឹម ទន់ មិនបានបញ្ជាក់ថា បុគ្គលទាំងនោះត្រូវបានគេយកទៅសម្លាប់ឬយ៉ាងណាឡើយ ។ របឹម ទន់ បានប្រាប់តំណាងសហព្រះរាជអាជ្ញាខែល លីសាក់ នៅពេលចោទសំណួរពាក់ព័ន្ធនឹងការបោសសម្អាតខ្មាំងនៅក្រសួងការបរទេស ។ លីសាក់ បានដាក់បង្ហាញឯកសារកំណត់ហេតុកិច្ចប្រជុំសន្និបាតរបស់ក្រសួងការបទេសក្រោមអធិបតីភាពរបស់ អៀង សារី ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៧ ដែលបានកត់ត្រានិងសង្ខេបដោយ សូ ហុង ។ ក្នុងឯកសារនេះមាននិយាយអំពី “ការបោសសម្អាត” និង “ការកម្ទេចខ្មាំង” ដែលជាប់ពាក់ព័ន្ធនឹង សេ.អ៊ី.អា, កា.ហ្សេ.បេ និងយួនឈ្លានពានទឹកដីដែលបានរាយការណ៍ដោយអង្គភាពក្រោមចំណុះរបស់ក្រសួងការបរទេស ។

របឹម ទន់ បញ្ជាក់ថា នៅចុងបញ្ចប់នៃសន្និបាតនេះ អៀង សារី បានណែនាំឲ្យអង្គភាពក្រោមចំណុះក្រសួងការបរទេសទាំងអស់ត្រូវបន្តបោសសម្អាតខ្មាំងដែលនៅសេសសល់ក្នុងអង្គភាពរបស់ខ្លួនឲ្យអស់ ។

**ចាន ប្រុញ**


របឹម ទន់ នៅមជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីខែវិច្ឆិកា ឆ្នាំ២០១១

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺជាឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនិងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហមនិងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

«ការិយាល័យព័ត៌មានសាធារណៈ» មានផ្តល់ជូននូវសេវាចម្បងបីយ៉ាង ៖

**១) បណ្ណាល័យ ៖** នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ ៖** មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃ ។

**៣) ក្រុមការងារផ្នែកតុលាការ ៖** ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ុំ សារីណា តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# តើច្បាប់អាចលប់លើនយោបាយដែរឬយ៉ាងណា?

ខណៈពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឈានបញ្ចប់វិស្សមកាលរដូវក្ដៅដែលមានរយៈពេលជាច្រើនសប្ដាហ៍របស់ខ្លួន ចក្ខុរបស់សាធារណជនចាប់ផ្ដើមសម្លឹងទៅមើលបុគ្គលិកថ្មីបំផុតរបស់តុលាការ «ដែលគ្រប់គ្នារំពឹងទុក» និងសម្លឹងទៅរកកិច្ចការដែលមានលក្ខណៈចម្រូងចម្រាសករណី០០៣និង០០៤ដែលអាចឈានទៅរកការបិទដំណើរការស៊ើបអង្កេត ។ ខណៈពេល ដែលប្រវត្តិនៃកិច្ចដំណើរការនៃករណី០០៣និង០០៤នេះអាចនិងលេចឡើងនូវភាពស្មុគស្មាញព្រោះតែករណីទាំងពីរនេះឋិតក្នុងភាពចម្រូងចម្រាស លទ្ធផលនៃដំណើរការករណីទាំងពីរនេះក៏អាចទស្សទាយបានដែរ ។

ករណី០០៣និង០០៤ត្រូវបានលើកយកមកពិភាក្សាកាលពីឆ្នាំ២០០៩ នៅពេលដែលលោក រ៉ូប៊ើត ប៉េទីត សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យមានការស៊ើបអង្កេតជនសង្ស័យបន្ថែមចំនួនប្រាំនាក់ទៀត ក្រៅពីករណី០០១និង០០២ ។ សំណើនេះត្រូវបានបដិសេធដោយសហការីរបស់លោកដែលជាភាគីកម្ពុជាគឺលោកជិតាវ ជា លាង ហើយជម្លោះនេះត្រូវបាននាំទៅកាន់អង្គបុរេជំនុំជម្រះដើម្បីសុំសេចក្ដីសម្រេចពីចៅក្រម ។ ជាលទ្ធផលអង្គជំនុំជម្រះមិនអាចចេញសេចក្ដីសម្រេចរួមគ្នាដោយចៅក្រមអន្តរជាតិពីររូបសម្រេចឲ្យមានការស៊ើបអង្កេតលើជនសង្ស័យបន្ថែម ចំណែកឯកចៅក្រមជាតិបីរូបសម្រេចធ្វើការជំទាស់នឹងសំណើរនោះ ។ នៅពេលអង្គបុរេជំនុំជម្រះមិនអាចចេញសេចក្ដីសម្រេចដោយសម្លេងភាគច្រើនលើសលប់ សហព្រះរាជអាជ្ញាអន្តរជាតិនៅតែបន្តកិច្ចការរបស់ខ្លួនទៅមុខក្រោមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដដែល ។

វិធានផ្ទៃក្នុង៧១ (៤) និង៧២ (៤) ចែងថា ប្រសិនបើមានការខ្វែងគំនិតគ្នានៅក្នុងការិយាល័យសហព្រះរាជអាជ្ញាឬនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតដែលមិនអាចដោះស្រាយដោយមតិភាគច្រើនលើសលប់ដោយចៅក្រមបួននាក់ក្នុងចំណោមចៅក្រមទាំងប្រាំនាក់ទេ សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញាអាចបន្តដំណើរការស៊ើបអង្កេតរបស់ខ្លួនទៅមុខបើអង្គបុរេជំនុំជម្រះមិនបានឈានដល់សេចក្ដីសម្រេចទាក់ទងទៅនិងជម្លោះស៊ើបអង្កេតនិងការកាត់ទោសបន្ថែម ភាគីនីមួយអាចផ្ដួចផ្ដើមឲ្យមានសកម្មភាពស៊ើបអង្កេត បើមិនដូច្នេះទេ ការសម្រេចនេះនិងអាចឈ្នះ ។ នៅក្នុងកាលៈទេសៈនៃការបើកនៃការស៊ើបអង្កេតករណី០០៣និង០០៤នេះ សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិត្រូវបានបញ្ជូនព្រោះសហព្រះរាជអាជ្ញាអន្តរជាតិជាអ្នកធ្វើសកម្មភាព ឬ (ដាក់សំណើ) មុន ដូច្នេះនិងបង្កើតឲ្យមានការផ្ដួចផ្ដើមនៃការស៊ើបអង្កេតតាមបែបពិនិត្យពិច័យ ។

ស្ថានភាពនិងវិធានដែលមានលក្ខណៈបោកបញ្ឆោតនេះនិងអាចកើតឡើងម្ដងទៀត ។ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង ស៊ីកហ្វ្រេដ ប្លុង បានចេញ «សេចក្ដីជូនដំណឹងស្ដីអំពីការបញ្ចប់កិច្ចស៊ើបសួរ» ដែលចៅក្រមស៊ើបអង្កេតទាំងពីបានបញ្ជាក់ថា កិច្ចការស៊ើបអង្កេតសម្រាប់ករណី០០៣ត្រូវបាន «បញ្ចប់» ជាផ្លូវការហើយ ។ តែក្រោមវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ការបិទបញ្ចប់ការស៊ើបអង្កេត មិនមានន័យថាជាការបិទបញ្ចប់សំណុំរឿងនោះទេ ។

ខណៈពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតអាចនឹងជូនដំណឹងអំពីការស៊ើបអង្កេតនេះគឺ ជាករណីអាចធ្វើទៅបានតែត្រឹមតែជាជំហានតំបូងនៃការបិទករណីនេះតែប៉ុណ្ណោះ ។ វិធាន៦៧បានបញ្ជាក់យ៉ាងច្បាស់ថា «សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់និងបញ្ជូនជនត្រូវចោទទៅអង្គជំនុំជម្រះឬលើកលែងការចោទប្រកាន់» ។

ហេតុដូច្នេះ ការស៊ើបអង្កេតមិនអាចបញ្ចប់ឬចេញសេចក្ដីសម្រេចដោយមិនមានការចេញដីកាដំណោះស្រាយដែលបង្កើត

ឲ្យមានការចោទប្រកាន់ឬលើកលែងការចោទប្រកាន់ទេ ។ មិនមានដីកាបែបនេះ ត្រូវបានចេញបន្ទាប់ពីមានការជូនដំណឹងនៃការបញ្ចប់ការស៊ើបអង្កេតដែលចេញដោយសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ទេ ។

សេចក្តីជូនដំណឹងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលថាការស៊ើបអង្កេតត្រូវបានបិទដែលមានរយៈពេល ១៥ថ្ងៃដែលសហព្រះរាជអាជ្ញាអាចអះអាងថា ការស៊ើបអង្កេតត្រូវបាន "បិទ" ឬក៏ដាក់បណ្តឹងឧទ្ធរណ៍ដោយយកមូលដ្ឋានថាការស៊ើបអង្កេតបន្ថែមគឺជាកិច្ចការចាំបាច់ដែលត្រូវធ្វើ ។

នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១១ លោក អេនឌ្រូ ខេលី សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យមានការស៊ើបបន្ថែមលើករណី ០០៣ ។ សំណើនោះត្រូវបានជំទាស់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេតដោយលើកយកហេតុផលថា វិធានផ្ទៃក្នុងមិនតម្រូវឲ្យមានការដាក់បញ្ចូលឯកសារជាលក្ខណៈឯកតោភាគីដោយអវត្តមានកំណត់ហេតុនៃការខ្វែងគំនិតរវាងសហព្រះរាជអាជ្ញាការផ្ទេរសមត្ថកិច្ចដោយសមភាគី ។ ទីបញ្ចប់ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនេះត្រូវបានបញ្ជូនទៅឧទ្ធរណ៍ ហើយខណៈពេលដែលសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតត្រូវបានប្រកាន់ភ្ជាប់ដោយយោងតាមវិធាន៧២ សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះផ្តល់នូវដំណោះស្រាយចំពោះបញ្ហាការស៊ើបអង្កេតនិងការឯកសារបន្ថែមតែប៉ុណ្ណោះ ។

ដោយសារតែការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានចេញ "ដីកាដំណោះស្រាយ" ដូចអ្វីដែលវិធានផ្ទៃក្នុង៦៧ (១) តម្រូវឲ្យធ្វើនោះ ការស៊ើបអង្កេតទាក់ទងទៅនិងករណី០០៣ នៅតែធ្វើទៅបានដោយប្រសិទ្ធភាព ។

នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេត ស៊ីកហ្វ្រីដ ប៊្លុង លាលែងពីតំណែងដោយសារតែរឿងរ៉ាវចម្រូងចម្រាសទាក់ទងទៅនិងដំណើរការមិនសូវល្អនៃកិច្ចការស៊ើបអង្កេតក្នុងករណី០០៣និងករណី០០៤ ហើយលោកបានបញ្ជាក់អំពីការជ្រៀតជ្រែកពីសំណាក់រដ្ឋាភិបាល ។ ការលាលែងពីតំណែងរបស់ចៅក្រម ស៊ីកហ្វ្រីដ ប៊្លុង បានត្រួសត្រាយផ្លូវឲ្យចៅក្រមបម្រុងថ្មីលោក ឡូរ៉ង់ កាស្ពើ អាម៉េត ចូលមកជំនួសរយៈពេលខ្លីចំពោះតំណែងដ៏ពោរពេញទៅដោយភាពចម្រូងចម្រាសនេះ ។ ក្រោយពីចូលកាន់តំណែង ចៅក្រម ឡូរ៉ង់ កាស្ពើ អាម៉េត ចាប់ផ្តើមដំណើរការស៊ើបអង្កេតករណី០០៣ និងករណី ០០៤ ។

កាលពីខែធ្នូ ឆ្នាំ២០១១ ចៅក្រម ឡូរ៉ង់ កាស្ពើ អាម៉េត បានចេញដីកាមួយដើម្បី "បើកការស៊ើបអង្កេតឡើងវិញ" ចំពោះករណី០០៣ ដែលនៅបិទពុំទាន់បញ្ចប់នៅឡើយ ។ ខាងភាគីកម្ពុជាវិញ សហចៅក្រមស៊ើបអង្កេតជាតិ យូ ប៊ុនឡេង ជំទាស់ទៅនិងសកម្មភាពរបស់ ឡូរ៉ង់ កាស្ពើ អាម៉េត ដោយអះអាងថា ចៅក្រម ឡូរ៉ង់ កាស្ពើ អាម៉េត មិនមានសិទ្ធិអ្វីនិងចេញដីកា ឬនិយាយជួសមុខឲ្យការិយាល័យស៊ើបអង្កេតទេព្រោះគាត់មិនទទួលបាននូវការតែងតាំងជាផ្លូវការពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

ខណៈពេលដែលការទាស់ទែងគ្នានេះនៅតែកើតមានឡើងក្នុងផ្លូវនយោបាយ "លេងសើច" តាមទស្សនៈនីតិវិធីកិច្ចការទាក់ទងនិងករណី០០៣នៅតែដំណើរការដោយមិនផ្លាស់ប្តូរដោយមូលដ្ឋាននៃវិធាន៧២ ។

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១១ ចៅក្រម ឡូរ៉ង់ កាស្ពើ អាម៉េត បានចេញកំណត់ត្រានៃការជំទាស់មួយដោយអះអាងថាគាត់បានកាន់តំណែងផ្លូវការមួយ ហើយគាត់ស្នើសុំឲ្យមានការវិនិច្ឆ័យចំពោះជម្លោះនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតទាក់ទងទៅនិងការបើកការស៊ើបអង្កេតករណី០០៣ឡើងវិញ ។ ក្នុងអំឡុងពេលនៃចេតនារបស់អង្គបុរេជំនុំជម្រះទាក់ទងទៅនិងសេចក្តីសម្រេចនេះ ប្រធានអង្គជំនុំ ជម្រះ លោក ប្រាក់ គីមសាន បានព្យាយាមច្រានចោលនូវសំណើររបស់ ឡូរ៉ង់ កាស្ពើ អាម៉េត ដោយការចេញអនុស្សារណៈនៃការិយាល័យនីមួយៗ ។

ដោយសារតែសំណើរបស់ចៅក្រម ឡូរ៉ង់ កាស្ពើ អាម៉េត មិនត្រូវបានដោះស្រាយ បន្តិចក្រោយមក ចៅក្រមអន្តរជាតិរបស់អង្គបុរេជំនុំជម្រះបានចេញគំនិតយោបល់មួយដោយអះអាងតាមនីតិវិធីច្បាប់ដោយបញ្ជាក់អំពីបរាជ័យរបស់អង្គបុរេជំនុំជម្រះក្នុងការដែលមិនអាចរកដំណោះស្រាយតាមរយៈមតិភាគច្រើនលើសលប់ ។ម្តងទៀត ដោយសារតែអង្គបុរេជំនុំជម្រះមិនអាចឈានទៅរកដំណោះស្រាយតាមរយៈសេចក្តីសម្រេចតាមរយៈមតិភាគច្រើនលើសលប់នេះ សកម្មភាពរបស់ចៅក្រម ឡូរ៉ង់ កាស្ពើ

អាម៉េត ដើម្បីបើកឲ្យមានការស៊ើបអង្កេតករណី (០០៣ឡើងវិញ) នៅតែតាមប្រសិទ្ធភាពដដែលតាមរយៈវិធានផ្ទៃក្នុង៧២ (៤) ។

ជាក់ស្តែង ការជំទាស់ទៅនឹងការអះអាងចំពោះអ្វីដែលបានរៀបរាប់ខាងលើនេះគឺជាអំណះអំណាងថា សំណើរបស់ចៅក្រម ឡូរ៉ង់ កាស្តេ អាម៉េត មិនត្រូវបានដោះស្រាយទេ ក្នុងដំណាក់កាលដំបូងដែលជាហេតុធ្វើឲ្យដីការរបស់ចៅក្រម ឡូរ៉ង់ កាស្តេ អាម៉េត ទុកជាមោឃៈ ។ ខណៈពេលដែលតុលាការកំណត់សម្រេចទៅនឹងបញ្ហាអ្វីមួយ ដោយផ្អែកទៅលើមូលដ្ឋានជំហរអ្វីមួយក្នុងចំណោមបញ្ហាផ្សេងទៀត វាគឺជាសញ្ញាណនៃការពន្យឺតដើម្បីច្រានចោលយ៉ាងច្បាស់ក្រឡែតចំពោះបញ្ហាសិទ្ធិអំណាចរបស់សហចៅក្រមស៊ើបអង្កេតបម្រុងដែលឋិតនៅចំចំណុចកណ្តាលនៃចេតនារបស់អង្គសេចក្តី ។

ទោះជាយ៉ាងនេះក្តី ដូចដែលករណីមួយចំនួននៅទ្រឹងដូចសព្វថ្ងៃនេះ ហើយការព្យាយាមដើម្បីធ្វើឲ្យដីការបស់ចៅក្រម ឡូរ៉ង់ កាស្តេ អាម៉េត ទៅជាគ្មានលក្ខណៈច្បាប់ហាក់បីដូចជាជំរុញឲ្យករណី០០៣និង០០៤ឲ្យចូលទៅក្នុងដំណាក់កាលមួយដែលត្រូវបានបោះបង់ចោល ។

ទោះជាយ៉ាងណាក្តី ដោយសារតែជាជាប់គាំងនៃទម្រង់បែបបទបែបនេះដំណើរការបត់បែនចុះឡើងនៃករណី០០៣ និង០០៣បានបង្ហាញអំពីអំណាចនៃ «ការចម្រាញ់ក្នុងដំណាក់កាលដំបូង» គួរឲ្យកត់សម្គាល់ ។ តាមន័យនេះ ដំណាក់កាលដំបូងក្នុងការបង្កើតឲ្យមានសកម្មភាពក្នុងហេតុការណ៍អ្វីមួយនៃជម្លោះនៅក្នុងការិយាល័យរួមគ្នាអាចឲ្យមានការបន្ទាយពេលវេលាឲ្យកាន់តែយូរ ជាពិសេស នៅពេលដែលជម្លោះនៅក្នុងការិយាល័យរួមគ្នាភាគច្រើនធ្វើឲ្យមានការបែកខ្ញែករវាងគោលការណ៍ច្បាប់ជាតិនិងអន្តរជាតិនៅក្នុងអង្គបុរេជំនុំជម្រះ ។ យើងមើលឃើញលទ្ធផលនេះ ហើយម្តងទៀត ចាប់ពីការដាក់សំណើរបឋមឲ្យមានការ «បើកឡើងវិញ» នៃករណីសំណុំរឿងនេះ ។

បើយើងប្រើពាក្យ «ចុះប្រសិនបើ» ចំពោះអតីតកាលវិញ យើងអាចឃើញថាតើភាពលំបាកស្មុគស្មាញសព្វថ្ងៃចំពោះករណី០០៣អាចនឹងមានស្ថានភាពក្រៅពីនេះ ដូចជា ការប្រើ «ការចម្រាញ់ក្នុងដំណាក់កាលតំបូង» អាចនឹងមានភាពខុសប្លែកគ្នា ។ ឧទាហរណ៍ ប្រសិនបើចៅក្រម យូ ប៊ុនឡេង ចេញ «ដីកាដំណោះស្រាយ» ច្រានចោលករណី០០៣ក្រោមវិធានផ្ទៃក្នុង៦៧ស្របពេលទៅនិងការដាក់កំណត់ហេតុស្តីពីការខ្វែងគំនិតជាមួយសហចៅក្រមស៊ើបអង្កេតជាតិដែលជាដៃគូរបស់ខ្លួននោះភាពខ្វែងគំនិតរវាងចៅក្រមជាតិ និងអន្តរជាតិអាចជម្រុញឲ្យមានការយកសេចក្តីសម្រេចដែលមាននៅក្នុងវិធានផ្ទៃក្នុង៧២ដែលថា ដីការបស់ចៅក្រម យូ ប៊ុនឡេង នឹងមានប្រសិទ្ធភាព ហើយសំណុំរឿង០០៣នឹងត្រូវច្រានចោល ។

ប៉ុន្តែដូចដែលអ្នកខ្លះចង់ឲ្យករណី០០៣ (និងករណី០០៤) ចាកឆ្ងាយពីសំណុំរឿងនោះវិធានច្បាប់និងត្រូវមានរឿងអ្វីមួយកើតឡើង ហើយដូច្នេះដែលយើងត្រូវប្រឈមមុខគឺការប្រើពាក្យ «តើនិង ត្រូវធ្វើអ្វីទៀត?» ប្រហែលជាមិនមានការភ្ញាក់ផ្អើលអ្វីទេ ចៅក្រម រ៉ូឡង់ កាស្តេ អាម៉េត បានលាលែងពីតំណែងនៅថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១២ ដោយសារតែបរិយាកាសនៅក្នុងការងារមានសភាពច្របូកច្របល់បែបនេះ ហើយថ្មីៗនេះមានពាក្យចចាមអារាមមួយថា មានការតែងតាំងសហចៅក្រមស៊ើបអង្កេតថ្មីពីររូបថែមទៀត ។

ប្រសិនបើពាក្យចចាមអារាមនេះគឺជាការពិត លោក ប៉ែន ហាម៉ុន អតីតព្រះរាជអាជ្ញារបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងលោកស្រី ខារ៉ូលីន ឆាបភេនធៀ ចៅក្រមមួយរូបដែលបានបម្រើការនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសកូសូវ៉ូនិងចាប់ដំណើរការងាររបស់ខ្លួននាពេលឆាប់ៗខាងមុខនេះ ហើយមានការរំពឹងថាចៅក្រមទាំងពីររូបនេះនិងបែរទូកកាត់ផ្ទៃទឹកដ៏សែនលំបាកនៅពេលដែលចៅក្រមទាំងពីររូបនេះស៊ើបអង្កេតករណី០០៣និងករណី០០៤ ។

ទាំងទៅនិងនៅទម្រង់ផ្លូវច្បាប់នៃករណីទាំងពីរនេះយើងអាចធ្វើការរំពឹងថានិងឃើញថាមានរឿងពីរកើតឡើងទីមួយគឺករណីទាំងពីរនេះអាចនិងច្រានចោលឬអាចនិងធ្វើការចោទប្រកាន់ទោស ។ ហើយទីបញ្ចប់ ប្រសិនបើមានភាពចម្រូងចម្រាសទាក់ទងទៅនឹងលទ្ធផលដែលទទួលយ៉ាងម៉េចក៏ដោយ ក៏លទ្ធផលនេះនឹងត្រូវបានកំណត់ដោយនរណាជាអ្នកដាក់ពាក្យបណ្តឹងមុនបាន ។

ក្នុងជម្រើសផ្សេងទៀត ក៏អាចទៅរួចដែរថា សហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និង ហាម៉ុន អាចនិងឈានទៅរកកិច្ចព្រមព្រៀងរួមមួយថាតើត្រូវលើកលែងការចោទប្រកាន់ក្នុងករណីណាមួយឬអាចនិងករណីទាំងពីរ ។ ហេតុផលនៃការលើកលែងចោទប្រកាន់ត្រូវបានចែងក្នុងវិធាន៦៧ ៖

ក) អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋដែលឋិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ

ខ) ជនប្រព្រឹត្តិបទឧក្រិដ្ឋនោះមិនទាន់កំណត់អត្តសញ្ញាណនៅឡើយ ឬ

គ) ពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ ។

ដោយមានកិច្ចព្រមព្រៀងនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតអាចយកមកប្រើប្រាស់បានវាប្រហែលជាមិនអាចយកមកប្រើទេ ។ ត្រង់ចំណុចនេះនៅក្នុងប្រវត្តិរបស់តុលាការលទ្ធភាពដែលអាចមានការបែកខ្ញែកគ្នារវាងសហចៅក្រមជាតិនិងអន្តរជាតិ (និងនៅនិងអង្គបុរេជំនុំជម្រះ) អាចនឹងកើតមាន ហើយក្រោមវិធាន៧១ និង៧២ដែលអាចបង្កឲ្យមានភាពខុសឆ្គងក៏និងអាចកើតមានដែរ ។

អ្វីដែលមិនមានភាពប្រាកដប្រជាគឺថាតើចៅក្រមអន្តរជាតិថ្មីនិងសន្និដ្ឋានករណី០០៣និង០០៤ដោយកម្រិតណាដើម្បីប្រកាន់ខ្ជាប់នូវភាពត្រឹមត្រូវនៃទម្រង់ការច្បាប់របស់តុលាការដោយមិនធ្វើឲ្យបាត់បង់នូវសិទ្ធអំណាចរបស់ភាគីកម្ពុជា ។

អ្នកពង្រាងច្បាប់របស់អង្គការសហប្រជាជាតិសុទ្ធតែដឹងអំពីភាពប្រថុយប្រថាននៅក្នុងតុលាការកូនកាត់មួយនេះ ហើយទោះជាកម្រិតណាក៏ដោយអ្នកពង្រាងច្បាប់ទាំងនោះរំពឹងថានិងមានជ័យជម្នះលើការបែងខ្ញែកគ្នានេះដោយប្រើវិធីបង្កើតយន្តការមួយដែលផ្តល់អទិភាពដល់អ្នកដែលធ្វើសកម្មភាពមុន ។

លើសពីនេះ ដូចអ្នករាល់គ្នារំពឹងដែរ អ្នកពង្រាងច្បាប់ទាំងនោះបានចែងអំពីយន្តការដើម្បីដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការនេះបានដោយ (យោងមាត្រា២៨នៃកិច្ចព្រមព្រៀង) នៅក្នុងកិច្ចដំណើរការងារ (ឬភាពអសកម្មនានា) ដែលអាចបង្កើតភាពមិនអាចដំណើរការបាននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។ ឧទាហរណ៍ដូចជាអ្វីដែលហៅថា "ចំណុចបរាជ័យ" ។ ទោះជាយ៉ាងនេះក្តីអ្វីដែលអ្នកពង្រាងច្បាប់មិនបានលើកយកមកនិយាយគឺថាយន្តការសម្រាប់តម្រែតម្រង់ផ្លូវរវាងការពិភាក្សាគ្នាគឺងមាត់គឺងករនិងកិច្ចការដ៏រឹងមាំដូចដែលបានបកស្រាយ នៅក្នុងមាត្រា២៨ ។ ជាអកុសលសម្រាប់ចៅក្រមអន្តរជាតិថ្មីសម្រាប់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលនិងចូលមកបម្រើការងាររករណី០០៣និង០០៤អាចចូលទៅក្នុងបន្ទាត់នយោបាយនេះ ហើយនេះជាភារកិច្ចរបស់ចៅក្រមស៊ើបអង្កេតថ្មីដើម្បីជំរុញករណីទាំងពីរនេះឲ្យទៅមុខ ។

**គ្រីស្ទូហ្វឺ ឌឿរ៉ែង**

# ដំណឹងសួររកបងប្អូន

នាងខ្ញុំឈ្មោះ តាំង សុគន្ធា អាយុ៤៦ឆ្នាំ សព្វថ្ងៃរស់នៅភូមិថ្នល់បត់ ឃុំប៉ុស្សីក្រាំង ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។ នាងខ្ញុំសូមសួររកប្អូនៗខាងម្តាយរបស់ខ្ញុំចំនួនបីនាក់ដែលមានស្រុកកំណើតនៅស្រុកអូររាំងឪ ខេត្តកំពង់ចាម ដែលបាត់ខ្លួនក្នុងរបបខ្មែរក្រហមមានដូចជា ៖

១) ទូច កាន ភេទស្រី ត្រូវជាម្តាយមីង មកដល់សព្វថ្ងៃអាយុជាង៥០ឆ្នាំ ។

២) ទូច ហេង ភេទប្រុស ត្រូវជាពូ ។

៣) ទូច ហ៊ាង ភេទប្រុស ត្រូវជាពូ ។

ប្រសិនជាបងប្អូនណាបានស្គាល់ឈ្មោះដូចខាងលើ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈអាសយដ្ឋានដូចខាងលើ ឬតាមរយៈទូរស័ព្ទលេខ ៖ ០៩៧ ៥១៤ ៦៩ ៣៧ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ តាមរយៈទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា www.cambodiatribunal.org គឺជា «ប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា»ទាំងមូល ។ រយៈពេលជាងប្រាំពីរឆ្នាំកន្លងមកនេះ ព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយនៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការទាំងមូលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០១ ទាក់ទិននឹងការវិនិច្ឆ័យសេចក្តីលើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនិងនៅក្រោមបទបញ្ជារបស់អតីតប្រធានមន្ទីរស-២១ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច បានឈានដល់ដំណាក់កាលបញ្ចប់សវនាការជាស្ថាពរដោយ ឌុចត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិតកាលពីខែកុម្ភៈកន្លងទៅ ។

លើសពីនេះទៅទៀត សំណុំរឿងព្រហ្មទណ្ឌលេខ០០២ ដែលទាក់ទិននឹងជនជាប់ចោទបីនាក់ទៀតគឺ ខៀវ សំផន (គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ) នួន ជា (អនុលេខាបក្ស និងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ) និង អៀង សារី (ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ) បានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបាន តាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតដោយមានផ្នែកជាច្រើន ទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ (BLOG) វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងទៅនិងសវនាការ (MULTIMEDIA) សារព័ត៌មានផ្សេងៗជុំវិញតុលាការ (NEWS) របាយការណ៍របស់តុលាការនិងអង្គការក្រៅរដ្ឋាភិបាល (ECCC & NGO REPORTS) ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ



លោក វ៉ាន់ថាន ពៅដារ៉ា ឡើងធ្វើបទបង្ហាញអំពីគេហទំព័រឃ្លាំមើលតុលាការខ្មែរក្រហមដល់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម

*(TRIAL PROCEEDINGS)* ប្រវត្តិសាស្ត្រ *(HISTORY)* ប្រវត្តិរបស់តុលាការនេះ *(TRIBUNAL BACKGROUND)* និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ *(COMMENTARY)* ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិនិងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញនិងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី «សហកម្មខក្រិដ្ឋកម្មរួម» ដែលភាសាអង់គ្លេសហៅថា *«Join Criminal Enterprise»* ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម «ផែនការខក្រិដ្ឋរួម» ដែលភាសាអង់គ្លេសហៅថា *«Common Criminal Plan»* ។ ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ *(TRIAL PROCEEDINGS)* ឬបទអត្ថាធិប្បាយរបស់អ្នកជំនាញ *(COMMENTARY)* ដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអ.វ.ត.ក? តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ឧទាហរណ៍មួយទៀត ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ (BLOG) ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានការត្រួតពិនិត្យដោយលោកសាស្ត្រាចារ្យច្បាប់ ដេវីដ ស្សេហ្វើ **(David Scheffer)** អ្នកជំនាញពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការជាមួយ *Illinois Holocaust Museum and Education Center* ជំនួយឧបត្ថម្ភពីសំណាក់ *B.J. and M.K. Pritzker Family Foundation* និង *Northwestern University School of Law's Center for International Human Rights* ។

**ខ៊ាន់ថាន់ ពៅដារ៉ា**



ក្រុមការងារគម្រោងឃ្លាំមើលតុលាការខ្មែរក្រហមថតរូបជាមួយនិស្សិតទាហាននៅមហាវិទ្យាល័យបញ្ជាការ សេនាធិការ

# សេចក្ដីសម្រេចលើការប្រព្រឹត្តខុសក្រមសីលធម៌របស់មេធាវីការពារក្ដី នួន ជា

អង្គជំនុំជម្រះបានរាយការណ៍អំពី "ការប្រព្រឹត្តខុសក្រមសីលធម៌" របស់មេធាវីការពារក្ដីអន្តរជាតិទាំងពីររូបរបស់ នួន ជា ទៅគណៈមេធាវីរបស់មេធាវីទាំងពីរនិងបានព្រមានថា អង្គជំនុំជម្រះអាចធ្វើការផ្ដន្ទាទោសមេធាវីទាំងពីររូបនេះឬក៏បដិសេធមិនស្ដាប់ការតវ៉ាក្ដីរបស់សមាជិកណាមួយនៃក្រុមមេធាវីការពារក្ដីនេះ ដោយសារតែមេធាវីទាំងពីរមិនព្រមបញ្ឈប់ឥរិយាបថប្រឆាំងតវ៉ារបស់ខ្លួន ។ ការប្រព្រឹត្តខុសក្រមសីលធម៌រួមមាន "ការរំលោភដោយចេតនាទៅលើដីការបស់តុលាការ ការផ្ដល់ព័ត៌មានសម្ងាត់ទៅកាន់ភ្នាក់ងារសារព័ត៌មានដោយគ្មានការអនុញ្ញាតឬឯកសារណាមួយដែលជាសម្ងាត់ និងមិនស្របតាមបទដ្ឋានដែលមានការទទួលស្គាល់និងវិជ្ជាជីវៈច្បាប់" (សេចក្ដីសម្រេចលើការប្រព្រឹត្តខុសក្រមសីលធម៌មេធាវីការពារក្ដី នួន ជា លេខE ២១៤ នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១២) ។ នេះគឺជាសេចក្ដីសម្រេចលើកដំបូងដែលអង្គជំនុំជម្រះបានលើកឡើងពីសេចក្ដីសម្រេចនៃវិធាន៣៨ប្រឆាំងនឹងមេធាវីការពារក្ដី ។ ទោះបីជាយ៉ាងណាក៏ដោយសមាជិកក្រុមមេធាវីការពារក្ដីទាំងបីក្រុមនៅក្នុងសំណុំរឿង០០២សុទ្ធតែទទួលសេចក្ដីរាយការណ៍អំពីការប្រព្រឹត្តខុសក្រមសីលធម៌ទៅគណៈមេធាវីរបស់ខ្លួន ។ ប៉ុន្ដែមកដល់ពេលនេះ នៅតែមិនទាន់ឃើញមានគណៈមេធាវីកម្ពុជានិងគណៈមេធាវីអន្តរជាតិបញ្ចេញសកម្មភាពឬចេញដីកាព្រមានណាមួយទេ បន្ទាប់ពីអង្គជំនុំជម្រះបានចេញសេចក្ដីរាយការណ៍នេះមក ។ ដោយសារតែយុទ្ធសាស្ត្រការពារក្ដីរបស់ក្រុមមេធាវី នួន ជា ផ្អែកទៅលើការដាក់បន្ទុកលើរាជរដ្ឋាភិបាលកម្ពុជាដែលបានជ្រៀតជ្រែកកិច្ចការរបស់តុលាការនិងលើកឡើងដដែលៗអំពីប្រធានបទដែលត្រូវបានហាមឃាត់មិនឲ្យនិយាយ ប្រការទាំងអស់នេះអាចធ្វើឲ្យអង្គជំនុំជម្រះអស់ភាពអត់ធ្មត់និងធ្វើការផ្ដន្ទាទោសទៅលើមេធាវីទាំងពីររូបនេះ ។

កាលពីឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានព្រមានមេធាវីការពារក្ដីរបស់ អៀង សារី ចំពោះការបញ្ចេញព័ត៌មានសម្ងាត់នៅក្នុងគេហទំព័រសាធារណៈទាក់ទងនឹងដំណើរការពារក្ដីរបស់ខ្លួននិងសុខភាពរបស់កូនក្ដីរបស់ខ្លួនព្រមទាំងបញ្ហាច្បាប់ដែលត្រូវបានដាក់កំហិត ។ (ដីកាសម្រេចអំពីការរំលោភបំពានលើភាពរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរលេខD១៣៨នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩) ។ ក្រុមមេធាវីការពារក្ដីបានលើកឡើងពីឯកសារមួយចំនួនរបស់តុលាការដោយអះអាងថាសហចៅក្រមស៊ើបអង្កេត "បានដាក់សម្ពាធទៅលើខ្លួនក្នុងការដាក់សំណុំរឿង" ដែលអាចជាភាពអាម៉ាស់មួយឬពាក់ព័ន្ធនឹងភាពស្របច្បាប់និងការកាត់សេចក្ដីលើសកម្មភាពនិងសេចក្ដីសម្រេចរបស់ចៅក្រម" ក្រោមការ "បិទបាំងភាពអាម៉ាស់" នៃការសម្ងាត់ (លិខិតពីមេធាវីការពារក្ដីរបស់ អៀង សារី កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨) ។ ទោះបីជាយ៉ាងណាក៏ដោយ មកដល់បច្ចុប្បន្ននៅតែមានភាពខ្វះខាតក្នុងការអះអាងបញ្ជាក់ពីភាពច្បាស់លាស់ហើយភាគីខ្លះយល់ថានៅមានភាពខ្វះខាតក្នុងការផ្ដល់ហេតុផលស្របគ្នាដើម្បីពន្យល់ថាហេតុអ្វីបានជាសំណុំរឿងនិងសេចក្ដីសម្រេចខ្លះត្រូវឡើងធ្វើជាសាធារណៈ (និងមានការរៀបចំការបោះពុម្ពផ្សាយនៅក្នុងករណីចាំបាច់) ហើយករណីផ្សេងទៀតត្រូវបានរក្សាជាការសម្ងាត់ ។ ក្រុមមេធាវីរបស់ អៀង សារី បានបន្តបង្ហោះព័ត៌មានសង្ខេបនៅក្នុងគេហទំព័រ https://sites.google.com/site/iengsarydefence/ ប៉ុន្ដែជាដាំងបង្ហោះព័ត៌មានទាំងមូលក្រុមមេធាវីបានបង្ហោះព័ត៌មានដោយសង្ខេបប៉ុណ្ណោះដោយមិនមានការយល់ព្រមពីតុលាការឡើយ ។ ក្រុមមេធាវីរបស់ នួន ជា បានដំណើរការលឿនជាងនេះគឺមិនត្រឹមតែចែកចាយសំណុំរឿងរបស់ខ្លួនទៅកាន់អ្នកកាសែតទេ ប៉ុន្ដែថែមទាំងបង្ហាញពីការមិនគោរពទៅលើវិធានរក្សាភាពស្ងៀមស្ងាត់ទៅកាន់អង្គជំនុំជម្រះទៀតផង ។ ក្នុងករណីមួយក្រុមនេះបានស្នើឲ្យអង្គជំនុំជម្រះស៊ើបអង្កេតទៅលើការផ្ដល់ព័ត៌មានដោយមិនមានការអនុញ្ញាតទាក់ទងនឹងព័ត៌មានសុខភាពកូនក្ដីរបស់ខ្លួនទៅកាន់អ្នកផ្ដល់ប្រឹក្សាសុខាភិបាលឯករាជ្យមួយ (សំណើសុំឲ្យមានការស៊ើប

អង្កេតដោយយោងទៅតាមវិធាន៣៥ លេខE១៨៧ ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១) ។ អ្វីដែលជាក្តីបារម្ភធំជាងទៀតនោះគឺថា ប៉ុន្មានម៉ោងមុនពេលដែលក្រុមមេធាវីការពារក្តីរបស់ នួន ជា ទទួលការជូនដំណឹងដោយផ្ទាល់មាត់អំពីសេចក្តីសម្រេចខុសក្រមសីលធម៌របស់អង្គជំនុំជម្រះសមាជិករបស់ខ្លួនបានផ្សព្វផ្សាយដីកាសម្ងាត់របស់តុលាការជាលើកទីមួយដោយជឿថាវាអាចគាំទ្រការទាមទាររបស់ខ្លួនឲ្យមានការកោះហៅសាក្សីដែលជាមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ។ ទោះបីជាការផ្សព្វផ្សាយនេះមិនបានបង្កើតជាផ្នែកណាមួយនៃបញ្ជីបទល្មើសរបស់អង្គជំនុំជម្រះក៏ដោយតែនេះគឺជាការរំលោភបំពានដ៏អាក្រក់បំផុតរបស់មេធាវីការពារក្តីទៅលើវិធានរក្សាការសម្ងាត់ ។

នៅឆ្នាំ២០០៩ដដែល អង្គបុរេជំនុំជម្រះបានព្រមានមេធាវីការពារក្តី ហ្សាក់ វែរហ្សេ របស់ ខៀវ សំផន ឲ្យបញ្ឈប់សកម្មភាពរំលោភបំពានឬសកម្មភាពដែលមានគោលបំណងរារាំងដល់ដំណើរការកាត់សេចក្តី ។ ការធ្វើបែបនេះបានកើតឡើងដោយផ្នែកគឺចាប់ផ្តើមពីការដកស្រង់ចេញពីការពិភាក្សាទៅលើបញ្ហានៃបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងការឃុំខ្លួនមុនពេលសវនាការរហូតដល់ការចោទប្រកាន់ពីអំពើពុករលួយ ។ នៅពេលដែល ហ្សាក់ វែរហ្សេ មិនទទួលបានការអនុញ្ញាតឲ្យនិយាយអំពីប្រធានបទនេះ គាត់បានហៅចៅក្រមថា "ជាអ្នកនៅក្រៅច្បាប់វិជ្ជាជីវៈ" និងនិយាយថា ចៅក្រម "មើលឃើញតែលុយ" ក្នុងចំណោមពាក្យរិះគន់ផ្សេងទៀត ។ អង្គបុរេជំនុំជម្រះបានដកស្រង់យុទ្ធសាស្ត្រចេញពីតុលាការពិសេសនិងតុលាការសិទ្ធិមនុស្សនៅអឺរ៉ុបនៅពេលធ្វើសេចក្តីសម្រេចថាឥរិយាបថប្រមាថឬរំលោភបំពានចៅក្រមអាចនឹងទទួលការផ្តន្ទាទោស (ការព្រមានទៅសហមេធាវីអន្តរជាតិ លេខC២៦/៥/២២ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៩) ។

មេធាវីការពារក្តី នួន ជា មិនទាន់បានបញ្ចេញសកម្មភាពដោយចំហទេ ប៉ុន្តែបានធ្វើឲ្យចៅក្រមមានការមិនពេញចិត្តនិងកាត់ផ្តាច់មេក្រូនៅពេលដែលខ្លួនលើកឡើងដដែលៗពីការចោទប្រកាន់អំពីភាពលម្អៀងឬការជ្រៀតជ្រែករបស់រាជរដ្ឋាភិបាលព្រមទាំងទាញយកឱកាសនេះដើម្បីលើកឡើងអំពីឈ្មោះមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលដែលធ្លាប់ធ្វើជាមេដឹកនាំខ្មែរក្រហម ។ នៅពេលខ្លះទោះបីជាមេធាវីការពារក្តីខិតខំប្រឹងប្រែងឲ្យមន្ត្រីជាន់ខ្ពស់ទាំងនោះឡើងផ្តល់សក្ខីកម្មយ៉ាងណាក៏ដោយ ក៏អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីនិយាយដែរ ។ ចំណុចនេះបានធ្វើឲ្យមេធាវី នួន ជា មានការអស់សង្ឃឹម ហើយចៅក្រមក៏មានការមិនពេញចិត្តចំពោះការបង្កឲ្យមានការតវ៉ាគ្នាដែលរំខានដល់ដំណើរការនីតិវិធី ។

អង្គជំនុំជម្រះមិនបានដកស្រង់យុទ្ធសាស្ត្រអ្វីមួយដើម្បីគាំទ្រការរកឃើញថាឥរិយាបថរបស់ក្រុមមេធាវីការពារក្តីមានលក្ខណៈខុសពីក្រមសីលធម៌ទេ ។ មេធាវីការពារក្តីតែងតែប្រើប្រាស់យុទ្ធសាស្ត្ររំលោភបំពាននៅពេលជំនុំជម្រះមេដឹកនាំនយោបាយនៅក្នុងតុលាការឧក្រិដ្ឋកម្មនានា ។ ផ្ទុយពី ហ្សាក់ វែរហ្សេ ទោះបីជាសកម្មភាពខ្លះរបស់ក្រុមមេធាវីមានការមិនគោរពដល់ដំណើរការជំនុំជម្រះក្តីយ៉ាងណាក៏ដោយ ក៏សមាជិករបស់ខ្លួនបានចោទជាសំណួរទៅកាន់ចៅក្រមដោយវាយប្រហារទៅលើអំណះអំណាងលើសេចក្តីរបស់អង្គជំនុំជម្រះប៉ុន្តែអ្នកទាំងនោះមិនបានប្រមាថចៅក្រមក៏ដូចជាការព្យាយាមពន្យារពេលឬរារាំងដល់ដំណើរការកាត់សេចក្តីឬមានចេតនាធ្វើដូច្នោះឡើយ ។ ដោយហេតុនេះ ការផ្តន្ទាទោសរបស់អង្គជំនុំជម្រះទៅថ្ងៃមុខដែលរារាំងដល់ការចូលរួមរបស់មេធាវីការពារក្តីនៅក្នុងដំណើរការនីតិវិធីអាចជាប្រតិកម្មជ្រុលដែលធ្វើឲ្យមេធាវីប្រើប្រាស់ចំណុចនេះជាអំណះអំណាងស្នូលក្នុងការអះអាងថាវាអាចធ្វើឲ្យមេធាវីមិនមានឱកាសប្រើប្រាស់យុទ្ធសាស្ត្រការពារកូនក្តីរបស់ខ្លួនថាតើចៅក្រមជឿថាអំណះអំណាងនេះគឺជាអំពើល្អឬដើម្បីផលប្រយោជន៍របស់ខ្លួន? នៅពេលខាងមុខអង្គជំនុំជម្រះអាចមានភារកិច្ចដ៏លំបាកមួយក្នុងការគាំទ្រសិទ្ធិរបស់ នួន ជា ក្នុងការវាយប្រហារដល់ភាពស្របច្បាប់នៃដំណើរការនីតិវិធីនិងរក្សាភាពថ្លៃថ្នូររបស់អង្គជំនុំជម្រះក៏ដូចជាដំណើរការនីតិវិធី ។ ជម្រើសមួយគឺថាអង្គជំនុំជម្រះអាចរៀបចំពេលវេលាសម្រាប់ក្រុមមេធាវីការពារក្តីដើម្បីឲ្យក្រុមនោះលើកឡើងពីអំណះអំណាងអំពីការជ្រៀតជ្រែកណាមួយហើយការធ្វើបែបនេះទើបអាចកាត់បន្ថយតម្រូវការដែលក្រុមមេធាវីចេះតែទាមទារដើម្បីបានដឹងថារដ្ឋាភិបាលនិងមិនអនុញ្ញាតតាមការទាមទាររបស់ក្រុមមេធាវីការពារក្តីទេ ។

**អេន ហាញឌុល**

# ការធានាអះអាងអំពីការមិនចោទប្រកាន់ទោសដល់សាក្សី

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាតុលាការពិសេសមួយដែលបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមមួយចំនួនតូច ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ជាតុលាការតែមួយគត់ដើម្បីកាត់ទោសបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយហេតុផលនេះ ទោះបីជាវិធានផ្ទៃក្នុងបានការពារសិទ្ធិយ៉ាងហ្មត់ចត់និងច្បាស់លាស់ក្នុងការដាក់ពិរុទ្ធលើខ្លួនឯងចំពោះសាក្សីយ៉ាងណាក្តីក៏នៅតែមានកិច្ចខិតខំប្រឹងប្រែងជាច្រើនទៀតដើម្បីធានាថាសាក្សីគ្រប់រូបមិនត្រឹមតែដឹងអំពីសិទ្ធិក្នុងការនៅស្ងៀមប៉ុណ្ណោះទេ តែសាក្សីទាំងនោះក៏ត្រូវយល់ដឹងអំពីសិទ្ធិនិងមានទំនុកចិត្តក្នុងការអនុវត្តសិទ្ធិទាំងអស់នោះដែរ ។ អ៊ីៗបានផ្លាស់ប្តូរពីមួយថ្ងៃទៅមួយថ្ងៃ ស្របពេលដែលអង្គជំនុំជម្រះបានបោះជំហានទៅមុខឆ្ពោះទៅការដាក់វិធានការខ្លាំងជាងមុនក្នុងការការពារសិទ្ធិរបស់សាក្សី ។ នៅក្នុងអង្គសវនាការក្នុងករណីទីមួយរបស់អង្គជំនុំជម្រះក្នុងករណី កាំង ហ្កេចអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធាន មន្ទីរស-២១ ដំណើរការនៃការជូនដំណឹងដល់សាក្សីអំពីសិទ្ធិក្នុងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងត្រូវបានអនុលោមតាមច្បាប់រហូតដល់៤៣ថ្ងៃនៃការចូលសវនាការនៅពេលដែលមេធាវីការពារក្តី ហ្វ្រង់ស័រ រ៉ូហ្ស បានប្រាប់ទៅសាក្សីក្នុងបន្ទប់សវនាការថាសាក្សីរូបនោះអាចនឹងទទួលនូវការកាត់ទោស ហើយសាក្សីនោះគួរតែទៅពិគ្រោះជាមួយមេធាវីរបស់ខ្លួនអំពីការទទួលខុសត្រូវដែលអាចកើតមាននៅចំពោះមុខតុលាការជាតិ ។ ភាគីព្រះរាជអាជ្ញាបានសម្តែងនូវក្តីបារម្ភថា បញ្ហានេះមិនត្រូវបានលើកយកមកនិយាយជាមុនទេ តែបែរជាលើកមកនិយាយទៅចំពោះមុខសាក្សីទៅវិញខណៈពេលដែលសាក្សីហៀបនឹងផ្តល់សក្ខីកម្មដែលការប្រើបែបនេះអាចជាសញ្ញាមួយអាចប៉ះពាល់ដល់សាក្សីក្នុងការនិយាយការពិត ។ ក្នុងអំឡុងពេលនៃការធ្វើសក្ខីកម្មក្រោយៗមកទៀត ព្រមទាំងការធ្វើសក្ខីកម្មរបស់អតីតឆ្មាំមន្ទីរស-២១ អង្គជំនុំជម្រះបានផ្តល់ជូនមេធាវីម្នាក់ដើម្បីណែនាំដល់សាក្សីក្នុងករណីដែលសាក្សីអាចនិយាយដែលនាំទៅរកការដាក់ពិរុទ្ធលើខ្លួនឯង ។

នីតិវិធីដ៏សមរម្យដើម្បីអនុវត្តសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯងត្រូវបានលើកយកមកនិយាយកាលពីពេលថ្មីៗនេះនៅក្នុងករណី០០២ប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមដែលនៅរស់រានមានជីវិតដោយសារតែមានក្តីបារម្ភថាខ្វាចក្រែងមានការលើកឡើងពីបញ្ហានេះនៅចំពោះមុខសាក្សីម្តងទៀតមុននឹងសាក្សីចាប់ផ្តើមធ្វើសក្ខីកម្មហើយបើសិនជាលើកយកមកនិយាយនៅចំពោះមុខសាក្សីបែបនេះសាក្សីអាចនឹងមានការញញើតមិនហ៊ាននិយាយរឿងរ៉ាវអំពីអង្គហេតុជាក់ស្តែងដែលពាក់ព័ន្ធ ។ ជាលទ្ធផល អង្គជំនុំជម្រះបានចេញសេចក្តីណែនាំដោយអនុលោមតាមវិធាន២៨ (សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង) កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ដោយបញ្ជាក់អំពីដំណើរការរបស់តុលាការដើម្បីឲ្យមានការធានានូវការអនុវត្តសិទ្ធិ ។ សេចក្តីណែនាំនោះរួមមានការណែនាំដល់គ្រប់សាក្សីទាំងអស់អំពីសិទ្ធិដែលខ្លួនមានកំណត់រកសាក្សីណាដែលអាចត្រូវការប្រឹក្សាផ្នែកច្បាប់និងបង្កើតលទ្ធភាពផ្តល់មេធាវីដល់សាក្សីណាដែលត្រូវការមេធាវីនិងជំនួយផ្សេងៗផ្នែកច្បាប់ ។ ដោយសារតែក្តីបារម្ភរបស់ភាគីព្រះរាជអាជ្ញាត្រង់ថាការអនុវត្តនៃវិធានការពារសាក្សីបែបនេះអាចធ្វើឲ្យសាក្សីមានចិត្តស្ទាក់ស្ទើរក្នុងការផ្តល់សក្ខីកម្មក៏ដោយ ក៏ព្រះរាជអាជ្ញាទៅតែទាមទារថាតុលាការ «បន្ថែមបន្ថ្រប់» នីតិវិធីនេះដោយផ្តល់នូវការធានាថាសាក្សីនឹងមិនជាប់ពិរុទ្ធក្នុងការយកមកកាត់ទោសទេ ។ សហព្រះរាជអាជ្ញានឹងមិនផ្តួចផ្តើមចោទប្រកាន់ណាមួយប្រឆាំងចំពោះសាក្សីនោះឡើយ ហើយ «សាក្សីនីមួយៗនឹងមិនអាចត្រូវបានចោទប្រកាន់ក្រោមច្បាប់កម្ពុជាដែលមានសព្វថ្ងៃណាមួយឡើយ» ។ គាំទ្រទៅនឹងសំណើនេះ ព្រះរាជអាជ្ញាបានអះអាងថា ទោះបីជា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាថ្មីឆ្នាំ២០០៩អនុញ្ញាតឲ្យមានការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មអន្តរជាតិនៅកម្ពុជាក៏ដោយតែ

ច្បាប់នេះមិនផ្តល់យុត្តាធិការឲ្យទៅតុលាការក្នុងស្រុកធម្មតាទាក់ទិននឹងបទឧក្រិដ្ឋក្នុងស្រុកទេក្រោមកម្មវត្ថុនៃអាជ្ញាយុកាលដែលមានរយៈពេលដប់ឆ្នាំ ។ សំណើរបស់សហព្រះរាជអាជ្ញាសុំអញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា (ថ្ងៃទី៣០ មិនា ឆ្នាំ២០១២) ។ សហព្រះរាជអាជ្ញាបានអះអាងថា មានតែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមួយប៉ុណ្ណោះ ដែលមានអំណាចផ្លូវច្បាប់ក្នុងការកាត់សេចក្តីបទឧក្រិដ្ឋដែលបានកើតឡើងពីឆ្នាំ១៩៧៥ដល់១៩៧៩ ហេតុដូច្នេះ គ្មានជនណាផ្សេងទៀតនឹងត្រូវដាក់ឲ្យទទួលខុសត្រូវពីបទឧក្រិដ្ឋដែលបានកើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះទៀតទេដែលនេះជាការព្រួយបារម្ភមួយផ្នែកខាងផ្លូវច្បាប់ ។ តុលាការកម្ពុជាក្នុងស្រុកមិនអាចយកសាក្សីដែលបានផ្តល់សក្ខីកម្មនៅអង្គជំនុំជម្រះមកកាត់ទោសទៅថ្ងៃមុខទេ ទោះមកដល់ពេលនេះគ្មានជនណាម្នាក់ត្រូវបានចោទប្រកាន់តាមផ្លូវច្បាប់ពីបទប្រព្រឹត្តអំពើឃោរឃៅដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្តី ។ ហេតុដូច្នេះ តុលាការជាតិក្នុងស្រុកក៏មិនអាចធ្វើការចោទប្រកាន់បន្ថែមទៅនឹងកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីចោទប្រកាន់សាក្សីដែរ ។

ដូចក្រុមការពារក្តីរបស់ អៀង សារី បានចង្អុលបង្ហាញហើយថាបើទោះបីជាគ្មានច្បាប់ណាមួយអនុញ្ញាតឲ្យមានដែនសមត្ថកិច្ចយុត្តាធិការតុលាការកម្ពុជាទៅលើបទឧក្រិដ្ឋដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ពិតមែនតែសភាជាតិកម្ពុជាអាចនឹងធ្វើការសម្រេចចិត្តកែប្រែច្បាប់នោះបាននៅថ្ងៃណាមួយនាពេលអនាគត ។ ដូចដែលក្រុមការពារក្តីរបស់ អៀង សារី បានរៀបរាប់ក្នុងន័យអាក់អន់ចិត្តថា “ក្នុងឆ្នាំ១៩៩៦ នៅពេលដែល អៀង សារី បានទទួលនូវការលើកលែងទោសនិងអនុគ្រោះទោសដោយព្រះមហាក្សត្រកាលនោះមិនមាននីតិកម្មដើម្បីបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ” ។ លើសពីនេះទៅទៀត សេចក្តីសម្រេចផ្ទុយមកវិញអាច “បញ្ជូនសារថា ជនរងគ្រោះមិនត្រូវរំពឹងថានឹងទទួលបានយុត្តិធម៌នៅក្នុងសណ្ឋានផ្លូវច្បាប់ណាមួយទេនៅក្នុងប្រទេសកម្ពុជា” ។ ឲ្យចម្លើយតបរបស់ អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលសុំការអនុញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានា (ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២) ។

នៅក្នុងចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំអញ្ញាតក្នុងការផ្តល់លិខិតធានាអះអាងអំពីការមិនចោទប្រកាន់ដល់សាក្សីនានាថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះបានគាំទ្រនូវសំណើរបស់ព្រះរាជអាជ្ញាតែការគាំទ្រនោះសំដៅលើគ្រាន់តែធានាអំពីការមិនចោទប្រកាន់ដោយអង្គជំនុំជម្រះប៉ុណ្ណោះដែលអង្គជំនុំជម្រះនេះត្រូវបានគាំទ្រដោយច្បាប់អន្តរជាតិ ។ ប៉ុន្តែអង្គជំនុំជម្រះបានអះអាងថា វា “ជាការមួយពុំសមស្របក្នុងការផ្តល់នូវការធានាអំពីការមិនចោទប្រកាន់នៅចំពោះមុខតុលាការកម្ពុជាផ្សេងទៀតនោះទេ” ។

ការអនុវត្តរបស់អង្គជំនុំជម្រះក្នុងការការពារសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯងបានរីកចម្រើនគួរឲ្យកត់សម្គាល់តាំងពីបញ្ហានេះបានកើតឡើងតាំងពីករណី ឌុច មក ។ ភាពខ្សោយរបស់តុលាការកម្ពុជាក្នុងការមិនអនុវត្តច្បាប់ឲ្យបានត្រឹមត្រូវត្រូវបានមើលឃើញយ៉ាងច្បាស់ក្រឡែត ដែលពេលខ្លះ ជនជាប់ចោទត្រូវប្រឈមមុខនឹងបទពិរុទ្ធដោយមិនមានភស្តុតាងបង្ហាញច្បាស់លាស់ហើយពេលខ្លះ ជនជាប់ចោទគ្មានឱកាសនឹងការពារខ្លួនទេ ។ ការធានាអះអាងថាគ្មានការចោទប្រកាន់ទោសទៅថ្ងៃអនាគតចំពោះសាក្សីក្រោមកាលៈទេសៈច្បាប់បែបនេះពិតជាគ្មានន័យអ្វីទេ ប្រមានអត្ថន័យបន្តិចបន្តួចប៉ុណ្ណោះ ។ ផ្ទុយមកវិញទង្វើរបស់អង្គជំនុំជម្រះក្នុងការដាក់ឲ្យមានការអនុវត្តសិទ្ធិប្រឆាំងនឹងការធ្វើសក្ខីកម្មប្រឆាំងខ្លួនឯងនិងក្នុងការផ្តល់ឲ្យមេធាវីក្នុងស្រុកដើម្បីធ្វើការអនុវត្តច្បាប់ឲ្យមានអត្ថន័យគឺជាវិធីមួយដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែបង្កើតឡើងក្នុងលក្ខណៈវិជ្ជមានដើម្បីធ្វើជាគំរូដល់ប្រព័ន្ធតុលាការក្នុងស្រុក ។

**អាន ហាញឌុល**

- **និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឱ្យអត់ឱន អធ្យាស្រ័យគ្នា**
- **រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍**

# ហេតុអ្វីបានជាត្រូវចាំបាច់ផ្សព្វផ្សាយកិច្ចដំណើរកាត់ទោសដល់សាធារណជន?

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការអន្តរជាតូបនីយកម្មមួយដែលត្រូវបានបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីជំនុំ ជម្រះទោសលើមេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ តុលាការនេះអនុវត្តទាំងច្បាប់ជាតិ និងអន្តរជាតិ ព្រមទាំងមានការចូលរួមពីសំណាក់អង្គការសហប្រជាតិដើម្បីធានានូវឯករាជ្យភាពរបស់តុលាការក្នុងការសម្រេចសេចក្តីប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌ ។ តុលាការនេះត្រូវបានបង្កើតឡើងក្នុងគោលបំណងស្វែងរកយុត្តិធម៌ជូនជនរងគ្រោះដែលបានស្លាប់និងអ្នករស់រានមានជីវិតពីអំពើឧក្រិដ្ឋកម្មដែលបានកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាងនេះទៅទៀត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងក្លាយជាគំរូសម្រាប់តុលាការកម្ពុជាក្នុងដំណើរការស្វែងរកយុត្តិធម៌នៅប្រទេសកម្ពុជានិងធ្វើឲ្យមានភាពប្រសើរឡើងនូវវិធានច្បាប់ដែលមានស្រាប់ដើម្បីជំរុញឲ្យក្លាយជាប្រទេសនីតិរដ្ឋពេញលេញ ។

បច្ចុប្បន្នអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែដំណើរការជំនុំជម្រះទោសលើអតីតមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលគ្រប់គ្រងប្រទេសហើយបណ្តាលឲ្យប្រជាជនស្លាប់ជាងពីរលាននាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ នេះគឺជាសំណុំរឿងប្រវត្តិសាស្ត្រដែលនឹងត្រូវលាតត្រដាងឲ្យប្រជាជនកម្ពុជានិងសហគមន៍អន្តរជាតិដឹងអំពីមូលហេតុពិតប្រាកដដែលនាំឲ្យប្រជាជនកម្ពុជាស្លាប់ដ៏ច្រើនសន្ធឹកសន្ធាប់ដោយសារអំពើអមនុស្សធម៌និងការកាប់សម្លាប់យ៉ាងសាហាវនៅក្នុងរបបនេះ ។

ដូច្នេះ ការផ្សព្វផ្សាយអំពីកិច្ចដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យបានទូលំទូលាយគឺជាកត្តាសំខាន់និងចាំបាច់ដែលត្រូវតែធ្វើ ។ អ្នករស់រានមានជីវិត


និស្សិតវិទ្យាស្ថានវ៉ាន់ដា ឡើងសួរសំណួរទាក់ទងនឹងគេហទំព័រឃ្លាំមើលតុលាការខ្មែរក្រហម

ពីរបបខ្មែរក្រហមគប្បីទទួលបានព័ត៌មានគ្រប់គ្រាន់អំពីមូលហេតុពិតប្រាកដនៃអំពើឧក្រិដ្ឋកម្មដែលខ្លួនបានឆ្លងកាត់ ។ ការផ្សព្វផ្សាយនេះដែរនឹងបង្កើនការយល់ដឹងអំពីរបបខ្មែរក្រហមដែលជួយជំរុញបន្ថែមឲ្យសម្រេចបាននូវគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបញ្ជ្រាបការយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យដល់កូនខ្មែរជំនាន់ក្រោយ ។

បន្ថែមលើនេះទៀត ការផ្សព្វផ្សាយអំពីកិច្ចដំណើរការជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺអាចជួយបង្កើនការយល់ដឹងដល់ប្រជាជនកម្ពុជាអំពីវិស័យច្បាប់ទាក់ទងនឹងសិទ្ធិទទួលបានការកាត់ក្តីប្រកបដោយត្រឹមត្រូវនិងយុត្តិធម៌ ។ ចំណេះដឹងនេះនឹងឆ្លើយតបសំណួរមួយចំនួនដែលតែងតែចោទសួរថាប្រជាជនកម្ពុជាអ្នកណាៗក៏ដឹងថារបបខ្មែរក្រហមគឺជារបបសម្លាប់មនុស្សជាច្រើន ។ ហេតុអ្វីចាំបាច់មានការរកភស្តុតាងច្រើននិងប្រើរយៈពេលយូរម្ល៉េះក្នុងការជម្រះក្តីមេដឹកនាំទាំងនោះ? ហេតុអ្វីតុលាការចាំបាច់គោរពសិទ្ធិរបស់ជនជាប់ចោទទាំងនោះច្រើនម្ល៉េះព្រោះមេដឹកនាំទាំងនោះមិនដែលគោរពសិទ្ធិរបស់ប្រជាជនកម្ពុជាឡើយ? ទាំងនេះគឺជាសំណួរសាមញ្ញដែលប្រជាជនកម្ពុជាមួយចំនួនតែងតែចោទសួរប៉ុន្តែទាមទារឲ្យមានការបកស្រាយឬផ្សព្វផ្សាយឲ្យបានច្បាស់លាស់និងទូលំទូលាយ បើពុំនោះសោតគំនិតជាអវិជ្ជមានរបស់គាត់មកលើកិច្ចដំណើរការជំនុំជម្រះក្តីរបស់តុលាការក្នុងការស្វែងរកយុត្តិធម៌នឹងកើតមានជាមិនខាន ។ ការណ៍ដែលជនរងគ្រោះយល់ដឹងអំពីការពិតនៃអំពើដែលខ្លួនបានទទួលរងនិងកិច្ចដំណើរការក្នុងការស្វែងរកយុត្តិធម៌គឺជាកត្តាសំខាន់ដែលជំរុញឲ្យមានការផ្សះផ្សាជាតិ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាខិតខំប្រឹងប្រែងរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មានដល់សាធារណជនទូទៅ បច្ចុប្បន្នមន្ត្រីកិច្ចការសាធារណៈរបស់តុលាការបានខិតខំប្រឹងប្រែងផ្សព្វផ្សាយកិច្ចដំណើរការជំនុំជម្រះក្តីរបស់តុលាការតាមរយៈការនាំយកប្រជាជនកម្ពុជាមួយចំនួនឲ្យមកចូលរួមទស្សនាសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ។ ទន្ទឹមគ្នានេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជា "បាន" និង "កំពុងបន្ត" ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទៅដល់ប្រជាជននៅតាមមូលដ្ឋានឬសកលវិទ្យាល័យផ្សេងៗនៅក្នុងប្រទេសកម្ពុជា ។ **ចាន ប្រុញ ហៅ ប្រាថ្នា**



ការបង្រៀននិងការផ្សព្វផ្សាយពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅតាមមូលដ្ឋានជនបទ

# ស៊ីវ ធួនៈ ដំណើរឆ្លងកាត់របបខ្មែរក្រហម



ស៊ីវ ធួន ឆ្នាំ១៩៨៤

**(តពីលេខមុន)**

## ការដ្ឋាននៅជុប

នៅពេលដែលការដ្ឋានកំពោរស្រះត្រូវបញ្ចប់នៅឆ្នាំ ១៩៧៧ អង្គការក៏ដកក្រុមខ្ញុំ១១នាក់ មកត្រួសត្រាយព្រៃ និងពង្រាបដីនៅជុំវិញផ្ទះមិត្ត វ៉ាល់ ។ វ៉ាល់ អាយុប្រហែលហាសិបឆ្នាំ មានមាឌស្ដើងខ្ពស់ និងរហ័សរហួន ហើយគាត់យកប្រពន្ធ ដែលពីមុនជាកងសេនាជន (យុទ្ធនារី) រស់នៅស្រុកភ្នំស្រុក តំបន់៥ ភូមិភាគពាយ័ព្យ និងមានកូនប្រុសតូចមួយអាយុប្រហែល១ឆ្នាំ ឈ្មោះ អាដួង ។ វ៉ាល់ និងប្រពន្ធបានរស់នៅលើផ្ទះឈើដំបូលក្បឿង ដែលឋិតនៅក្រោយ ផ្ទះកន្ដាំង ពីរខ្នង ជាប់នឹងផ្លូវជាតិលេខ៦ ពីស្វាយសិសុផុន ទៅសៀមរាប នៅក្បែរទីប្រជុំជនជុប ។ វ៉ាល់ និងគ្រួសារមានជីវភាពធូរធាដូចចៅហ្វាយស្រុកនៅសម័យសង្គមចាស់ដែរ មួយថ្ងៃៗ គេឃើញកងសេដ្ឋកិច្ចចុះឡើង ដោយនាំយកអាហារ បុរបបនេះរបបនោះ ដូចជា បារី ស្ករ បុទឹកស៊ីអ៊ីវ យកមកជូនជាហូរហែ ចំណែក ម៉ែអាដួង មើលកូននៅក្នុងផ្ទះ មិនសូវឃើញចេញក្រៅទេ ។ ខ្ញុំតែងតែនឹកឃើញក្លិនខ្ទឹមស ដែលធ្វើឲ្យខ្ញុំស្រក់ទឹកមាត់នៅពេលដែលប្រពន្ធគាត់ចម្អិនម្ហូបម្ដងៗ ព្រោះអស់រយៈពេលពីរឆ្នាំហើយខ្ញុំមិនដែលបានហូបម្ហូបឆាហូបទេ ចាប់តាំងពីជម្លៀសចេញពីទីក្រុងភ្នំពេញមក ។ ថ្ងៃមួយ ដោយសារឥទ្ធិពលនៃការស្រេកឃ្លាន មិត្ត យន ជាអ្នក១៧ មេសា ក៏ទៅលួចយកប្រហុកមកលាក់ទុកហូប ។ នៅពេលដែលប្រពន្ធមិត្ត វ៉ាល់ ឃើញក្រឡប្រហុកក្រហូង ក៏ប្រាប់ឲ្យមិត្ត ឡេង ដើរឆែកឆេរ ក៏ឃើញនៅក្នុងបង្វេចខោអាវមិត្ត យន ។ ឃើញដូច្នេះ វ៉ាល់ ក៏បញ្ជាឲ្យយកមិត្ត យន ទៅចងត្រាំក្នុងត្រពាំងខាងក្រោយផ្ទះអស់ពេលមួយយប់ លុះស្អែកឡើងទើបឲ្យយោធាយកទៅដាក់ក្នុងមន្ទីរឃុំឃាំងតាំងពីព្រលឹមមុនប្រជាជនចេញធ្វើការតាមមុខព្រួញអស់រយៈពេល១៨ថ្ងៃ ។ នៅថ្ងៃដោះលែង យន មានសភាពស្គមស្គាំង ស្លេកស្លាំង និងមិនអាចដើរបានទេ គាត់មានកម្លាំងត្រឹមតែវារចេញពីគុក និងនិយាយខ្សាវៗប៉ុណ្ណោះ ។

នៅជុបក៏មានកងវ័យកណ្ដាលមួយក្រុមមានគ្នាប្រហែលដប់ប្រាំពីរនាក់ក្រោមការក្ដាប់របស់ប្រធានកងឈ្មោះ វ៉ាន់ គេហៅថាពុក វ៉ាន់ ដែលជាអតីតទាហានចាស់ធ្លាប់ធ្វើទាហាននៅកោះកុង ។ លុះដល់ពេលចូលនិវត្តន៍ គាត់បានត្រឡប់មករស់នៅក្នុងភូមិកណ្ដាលឃុំព្រះនេត្រព្រះដែលមានអាយុប្រហែលហាប្រាំបីឆ្នាំរាងខ្ពស់ស្រឡះមាឌធំជាមនុស្សចិត្តល្អជាមួយអ្នកថ្មីចូលចិត្តនិយាយរឿងពីសង្គមចាស់ឲ្យស្ដាប់នៅម៉ោងសម្រាកពេលល្ងាច ។ កាលនោះ លោក ព្រាប សុខ ដែលជាសាស្ត្រាចារ្យភាសាសំស្ក្រឹតដែលបានទៅសិក្សានៅប្រទេសភូមាផ្នែកព្រះពុទ្ធសាសនា ។ ពេលនោះ លោក ព្រាប សុខ មានអាយុប្រហែល៦៥ឆ្នាំទៅហើយ ដែលមានកម្ពស់ខ្ពស់ស្រឡះ មុខទ្រវែង សម្បុរសជ្រះ និយាយសម្ដីគ្រលួ ។ ខ្ញុំនឹកឃើញកាលនៅភ្នំពេញ គាត់និយាយភាសា

អង់គ្លេសពិរោះតាមគុងអង់គ្លេសនៅសម័យនោះប្រទេសកម្ពុជាពុំមានអ្នកចេះភាសាអង់គ្លេសប្រៀបផ្ទឹមនឹងគាត់ឡើយ ។ លោក ព្រាប សុខ ធ្វើការនៅក្នុងកង តាវ៉ាន់ ដែលមានការងារដូចជា ដកស្មៅជម្រះស្មៅលកប្រឡាយទឹកជញ្ជូនដីពីទីខ្ពស់មកចាក់បំពេញទីទាប ។ គាត់ស្លៀកខោខ្លីរហែករយ៉ៃនិងអាវដៃវែងមួយចង្កេះផ្អេះនឹងខ្លួនមានជំងឺហើម ហើយកើតដំបៅនៅលើភ្នែកជើងនៅខែរងាគាត់ពុំមានភួយដណ្តប់ឡើយ ។ គាត់មានក្រណាត់បាវក្រចៅមួយប្រើជំនួសភួយដោយសារឈរត្រាំទឹកជារៀងរាល់ថ្ងៃដំបៅរបស់គាត់កាន់តែរីកធំទៅៗរហូតដល់ក្លាយជាដំបៅរងានៅពេលទំនេរគាត់ខំដើររកត្រួយ កន្ទ្រាំងបាយស ដើម្បីបិតឲ្យស្រួបខ្ទុះ ប៉ុន្តែទោះជាគាត់ខំព្យាយាមយ៉ាងណាក៏ ក៏ដំបៅនោះពុំបានសះជាឡើយ នៅទីបំផុតគាត់ក៏សុំប្រធានកងទៅរស់នៅក្នុងសហករណ៍វិញហើយក៏ស្លាប់នៅទីនោះដោយជំងឺហើមនៅដើមឆ្នាំ១៩៧៧ ។

## ចម្ការកប្បាស

នៅមុនរដូវចូលឆ្នាំខ្មែរ ឆ្នាំ១៩៧៧ ខ្មែរក្រហមបានបើកការដ្ឋានមួយទៀត ដោយកេណ្ឌកងចល័តប្រមាណ២.០០០នាក់ដើម្បីកាប់ឆ្ការព្រៃដែលលាតសន្ធឹងលើផ្ទៃដីវាលប្រមាណ៤០០ ទៅ៥០០ហិចតាជាប់ភ្នំកងវ៉ា ភ្នំស្វាយ និងភ្នំបាក់ដើម្បីដាំដើមកប្បាស ។ ខ្មែរក្រហមនិយាយថា «កប្បាសនេះមានតម្លៃណាស់សម្រាប់នាំចេញទៅទីផ្សារអន្តរជាតិ ហើយអង្គការនឹងនាំចូលមកវិញនូវគ្រឿងម៉ាស៊ីន និងគ្រឿងបន្លាស់ផ្សេងៗ ។ នៅថ្ងៃខាងមុខកម្ពុជាប្រជាធិបតេយ្យនឹងក្លាយទៅជាប្រទេសសង្គមនិយមដែលមានឧស្សាហកម្មជឿនលឿននៅអាស៊ី ហើយប្រជាជនទាំងអស់នឹងមានឡានជិះគ្រប់ៗគ្នា» ។ ខ្មែរក្រហមបានដាក់ផែនការឲ្យកងចល័តរានដីឲ្យហើយមុនរដូវភ្លៀងធ្លាក់ ។ កងចល័តទាំងអស់មានការលំបាកយ៉ាងខ្លាំង ព្រោះតំបន់នោះមានសណ្ឋានដី ជម្រាលរឹងគ្រើមដូចថ្មនៅរដូវប្រាំង ហើយស្អិតរអិលនៅរដូវវស្សា ជាប្រភេទដីអាចម៍កណ្តុរ ហើយកន្លែងខ្លះមានព្រៃក្រាស់និងមានថ្មទៀតផង ។ កងចល័តទាំងអស់ធ្វើការងារស្ទើរគ្មានពេលសម្រាក ហើយថ្ងៃខ្លះមេកងដើរដាស់ឲ្យក្រោកតាំងពីម៉ោង៤ព្រឹក ហើយធ្វើការរហូតដល់យប់ងងិត ។ ចំណែកកងចល័តមួយចំនួនដែលមានជំងឺខ្វាក់មាន់អង្គការឲ្យទៅធ្វើនៅការដ្ឋានភ្នំបាក់ ចម្ការខ្នុរដែលមានចម្ងាយប្រមាណពីប្រាំទៅប្រាំបីគីឡូម៉ែត្រពីកន្លែងស្នាក់នៅដោយចាត់ឲ្យមានអ្នកដឹកដៃពីរទៅបីនាក់ ។ កងចល័តទាំងនោះតែងតែត្រឡប់មកវិញយឺតជាងគេព្រោះមើលផ្លូវពុំឃើញហើយថ្ងៃខ្លះចូលដេកដោយមិនបានហូបបាយនិងមុជទឹកទៀតផង ។ ខ្មែរក្រហមគ្មានការអនុគ្រោះដល់ពួកខ្វាក់មាន់ឡើយ ព្រោះគេគិតថា ពួកនេះធ្វើពុតខ្ជិលធ្វើការ ក្រោយមកគេបានបញ្ជាឲ្យពួកឈ្លបយកកងខ្វាក់មាន់នេះទៅវាយចោលស្ទើរអស់រលីង ក្រោយមកគេពុំឃើញមានកងខ្វាក់មាន់ទៀតឡើយ ។

ចំណែកការដ្ឋាននៅជិតភ្នំកងវ៉ា ជាដីចម្ការសល់ពីសង្គមចាស់ មានដើមឈើទំហំប៉ុនកដៃ រហូតដល់ប៉ុនភ្លៅដុះទ្រុបទ្រុល ។ អង្គការបានបែងចែកឲ្យមនុស្សម្នាក់កាប់កូនឈើលើផ្ទៃដីទទឹងពីរម៉ែត្រ និងបណ្តោយ៥០ម៉ែត្រឲ្យហើយក្នុងមួយថ្ងៃ ប៉ុន្តែអង្គការមិនបានផ្តល់កាំបិត និងពូថៅថ្មីឲ្យទេ គឺកង ចល័តត្រូវប្រើចបជំនួសពូថៅ និងកាំបិត (កាំបិត ពូថៅ មិនសូវមានទេ ក្នុងមួយកងមានតែពីរឬបីប៉ុណ្ណោះ) ។ ការប្រើចបដើម្បីកាប់ និងគាស់ឈើធំៗធ្វើឲ្យមានការយឺតយ៉ាវការងារ ចំណែកអ្នកដែលធ្វើឲ្យបាក់ចបអង្គការនឹងយកទៅរៀនសូត្រមិនខាន ។ រៀងរាល់ថ្ងៃ កងចល័តទាំងអស់ត្រូវធ្វើការងារធ្ងន់ធ្ងរក្រោមកំដៅថ្ងៃហួតហែង ហើយគ្មានទឹកសម្រាប់ផឹកទេ គឺមានតែទឹកថ្លុកក្របីប៉ុណ្ណោះ ។ នៅទីនោះ ខ្ញុំបានមុជទឹកតែបួនដងប៉ុណ្ណោះ ទើបបណ្តាលឲ្យខ្ញុំកើតជំងឺរមាស់ពេញខ្លួន ។ នៅរដូវភ្លៀងធ្លាក់ខ្លាំង ខោអាវរបស់ខ្ញុំក៏ចាប់ផ្តើមរហែកបណ្តាលឲ្យរងាយ៉ាងខ្លាំង ហើយជាញឹកញាប់ខ្ញុំតែងតែរអិលដួលដោយសារតែហត់ហេវ ។ ចំណែករបបអាហារទទួលបានមួយចានចង្កឹះជាមួយដុំផ្សៀតត្រីប្រាផ្អកក្ដិនផ្សួរហើយប្រៃ ។ ការហូបអាហាររបៀបនេះបានធ្វើឲ្យកងចល័តជាច្រើនមានជំងឺរាករូសធ្ងន់ធ្ងរហើយត្រូវទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យស្ថិតនៅជាប់នឹងជើងភ្នំប៉ុន្តែអ្នកជំងឺភាគច្រើនមិនដែលឃើញត្រឡប់មកកងវិញទេ ។

កងចល័តខ្លះទៀត ត្រូវរងនូវការចោទប្រកាន់ថា លួចមាន់ និងលួច ផ្លែខ្នុរក៏ ត្រូវទទួលដោយអយុត្តិធម៌ ។ ថ្ងៃមួយ ខ្ញុំបានឃើញឈ្មោះ ឌុច សារឿន ជាជើងឯកកីឡាប្រដាល់ខ្មែរ (សង្គម-ចាស់) មានដើមកំណើតនៅខេត្តកំពង់ស្ពឺដែលធ្លាប់ធ្វើការនៅទំនប់កំបោរស្រះជាមួយខ្ញុំត្រូវកងឈ្លបខ្មែរក្រហមចងបណ្តើរយកទៅ

សម្លាប់ដោយសារតែគាត់និយាយតមាត់ជាមួយប្រធានកង ។ នៅមុនពេលសម្លាប់ គេបានយកគាត់ទៅចងដូចសត្វគោដោយបន្ទាយខ្សែមួយកន្ទុយនៅជិតរោងបាយដោយមានកំហឹងនឹងខ្មែរក្រហមគាត់ក៏ស្ទុះទៅធាក់នារីរោងបាយដួលពីរបីត្រឡប់ព្រោះគាត់ដឹងខ្លួនថាជីវិតត្រូវអស់ ។

**អាងត្រពាំងថ្ម**

ចាប់តាំងពីឆ្នាំ១៩៧៦ អង្គការប្រមូលកងចល័តតាមភូមិជាច្រើនទៅលើកទំនប់អាងត្រពាំងថ្ម ដែលស្ថិតនៅក្នុងភូមិត្រពាំងថ្ម ស្រុកភ្នំស្រុក ក្រោមការគ្រប់គ្រងរបស់គណៈតំបន់ឈ្មោះ ហឹង ។ ទំនប់នេះមានកម្ពស់១៥ម៉ែត្រ និងជើងទេរប្រវែង៧០ម៉ែត្រ ពីលើមកក្រោមនៅចំណុចស្ពានទី១ទំបន់នេះលាតសន្ធឹងនៅលើផ្លូវបុរាណមួយ ដែលក្រាលដោយថ្មបាយក្រៀម ប៉ុន្តែខ្មែរក្រហមបញ្ជាឲ្យកងចល័ត គាស់ចេញទាំងអស់ព្រោះខ្លាចទឹកជ្រាបចេញ នៅសម័យចក្រភពអង្គរមានផ្លូវធំមួយ តភ្ជាប់ពីប្រាសាទអង្គរចុះមកទិសខាងលិច ដោយឆ្លងកាត់តាមស្រុកស្រីស្នំតាមទ្វារទឹកស្ពានស្រែង ឆ្លងកាត់តាមត្រពាំងថ្ម ស្រុកភ្នំស្រុក រហូតដល់បន្ទាយឆ្មា ស្រុកថ្មពួក មុននឹងទៅដល់ប្រាសាទភីម៉ៃ ដែលស្ថិតក្នុង ប្រទេសថៃសព្វថ្ងៃ ។ នៅក្នុងរបបខ្មែរក្រហម គេបានយកផ្លូវបុរាណនេះបង្កើតបានជាទំនប់អាងស្តុកទឹកពីរ គឺអាងទឹករោគស្ពានស្រែង និងអាងត្រពាំងថ្ម (ដែលឋិតនៅមិនឆ្ងាយពីគ្នាក្នុងស្រុកភ្នំស្រុកតែមួយ) ។ នៅទីនោះអង្គការបានកំណត់ក្នុងមួយថ្ងៃកងចល័តម្នាក់ត្រូវវែកដីឲ្យបាន៤ម៉ែត្រគូប ចំណែកកងពិសេសត្រូវវែកឲ្យបាន៥ម៉ែត្រគូប ។ ពេលមួយ ដោយសារតែខ្ញុំមានកម្លាំងខ្សោយ ខំប្រឹងវែកដីឡើងខ្នងទំនប់ចោទគ្រេង មានចម្ងាយប្រហែលមួយរយម៉ែត្រពីមាត់រណ្តៅដីទៅដល់ខ្នងទំនប់ ខ្ញុំងងឹតមុខដួលជ្រប់ ពេលដែលក្រឡេកឃើញបាតទំនប់ជ្រៅពេក ។

នៅរដូវប្រាំងឆ្នាំ១៩៧៧ កងចល័តមានការខ្វះខាតទឹកផឹកកាន់តែខ្លាំង ព្រោះមានតែបឹងមួយដែលមានទឹកល្អក់ ខាប់ដោយសារអ្នកភូមិដែលរស់នៅក្បែរនោះចុះចាប់ត្រី ។ ថ្ងៃមួយពេលឡានបានដឹកទឹកមកដល់ ខ្ញុំប្រជ្រៀតជណ្តើមយកទឹកបានមួយបីដុង ដែលមានចំណុះតែមួយលីត្រកន្លះ ប៉ុណ្ណោះមកចែកគ្នាផឹក ហើយពេលសម្រាកថ្ងៃត្រង់ ខ្ញុំតែងតែដើរទៅជីកកន្លែងណាដែលមានដីសើមៗ ក្នុងបាតត្រពាំង នៅម្តុំនោះដើម្បីសម្រេងយកទឹកផឹកសម្រាប់ពេលយប់ ។ ព្រឹកខ្លះ យើងក្រោកយឺត ត្រូវគេលួចដងយកទឹកអស់គ្មានសល់ ។ ចំណែករបបអាហារ ខ្មែរក្រហមបានវាល់បាយឲ្យម្នាក់មួយវែក ហូបជាមួយសម្លកូនត្រីកញ្ចុះប្រឡាក់ ។ របបអាហារនេះមិនឆ្អែតសម្រាប់ខ្ញុំ ហើយពេលខ្លះ ដោយសារហត់ហេវខ្លាំងពេក ខ្ញុំបានលួចដើរជីកក្តាមបុកផ្អែបជាមួយមិត្តភក្តិយកមកស្ងោរលាយជាមួយស្លឹកឈើព្រៃហូបបន្ថែមទៀត ។ ទំនប់ត្រពាំងថ្ម បានបញ្ចប់ទៅដោយឆក់ជីវិតកងចល័តអស់ជាច្រើននាក់ ចំណែកអ្នកដែលនៅសេសសល់រាប់រយនាក់ទៀត មានរូបកាយទ្រុឌទ្រោម សុខភាពទន់ខ្សោយ ដោយកង្វះអាហារ និងថ្នាំព្យាបាល ។

**(នៅមានត)**

**ស៊ីវ ធួន**

# ដំណឹងស្វែករកពូ

នាងខ្ញុំឈ្មោះ លឹម ភានុវណ្ណរង្សីសីហៈ រស់នៅសង្កាត់សន្សំកុសល ខណ្ឌមានជ័យ ក្រុងភ្នំពេញ សូមប្រកាសរកពូឈ្មោះ ហាក់ អុល មកដល់បច្ចុប្បន្នមានអាយុ៧២ឆ្នាំ ។ កាលពីសម័យ លន់ នល់ ពូរបស់នាងខ្ញុំមានផ្ទះនៅទួលគោក ហើយគាត់ធ្វើជាប៉េអឹម ។ គាត់បានបែកពីគ្រួសារនៅម្តុំវត្តលង្កា ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីក្រុងឆ្នាំ១៩៧៥ ។ ចាប់តាំងពីពេលនោះមក គ្រួសារនាងខ្ញុំបាត់ដំណឹងគាត់រហូត ។

ប្រសិនបើ បងប្អូនណាបានដឹង ឬស្គាល់ឈ្មោះពូរបស់នាងខ្ញុំ សូមមេត្តាទាក់ទងមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ៖ ០១៥ ៥៥៥ ០០៧ ឬ ០១២ ៩៩៦ ៧៥០ ឬ មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអាសយដ្ឋាន ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ខណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬ ០១៦ ៨៧៦ ៦៩២ ។

***សូមអរគុណ!***

# ប្រវត្តិអ្នកម្តាយ

ម្តាយខ្ញុំមានឈ្មោះ ម៉ឹង ចាន់ មានស្រុកកំណើតនិងរស់នៅភូមិបួរ ឃុំព្រៃរំដេង ស្រុកគិរីវង្ស ខេត្តតាកែវ ។ ឪពុករបស់គាត់ឈ្មោះ ម៉ឹង សៀក និង ម្តាយឈ្មោះ ឆៀញ ។ ម្តាយខ្ញុំជាកូនច្បងក្នុងចំណោមបងប្អូនប្រុសស្រីប្រាំមួយនាក់ ។

ខ្ញុំបាទឈ្មោះ ហេង សំណាង ។ កាលពីខ្ញុំនៅតូច ម្តាយរបស់ខ្ញុំខស្សរាប់រៀបរាប់អំពីដំណើរជីវិតរបស់គាត់ដែលធ្លាប់ឆ្លងកាត់នៅក្នុងសម័យខ្មែរក្រហមប្រាប់ទៅដល់កូនៗណាស់ ។ គាត់តែងតែរំឭក ប្រាប់កូនៗថា មុនសម័យខ្មែរក្រហម ទោះបីក្រុមគ្រួសាររបស់គាត់មិនសូវមានជីវភាពធូរធារដូចគ្រួសារផ្សេងក៏ដោយ ក៏ជីតារបស់ខ្ញុំនៅតែបញ្ជូនម្តាយខ្ញុំទៅរៀនសូត្របានដែរ ទោះបីជាម្តាយខ្ញុំមានភារកិច្ចរវល់ជាប់ជាមួយនិងការងារនៅផ្ទះក៏ដោយ ។ ពេលនោះម្តាយខ្ញុំបានរៀនសូត្រត្រឹមតែថ្នាក់ទី១២ប៉ុណ្ណោះ ។ មួយរយៈក្រោយមក នៅភូមិកំណើតរបស់ម្តាយខ្ញុំចាប់ផ្តើមមានភាពប្រទាំងទង់យ៉ាងខ្លាំងដោយនៅក្នុងក្រុមគ្រួសាររបស់ម្តាយក៏ដូចជាក្រុមគ្រួសាផ្សេងគ្នាបាននាំគ្នាចាកចេញពីស្រុកកំណើតរបស់ខ្លួនរួចនាំគ្នាគេចខ្លួនមួយរយៈដោយសារតែមានការទម្លាក់គ្រាប់បែករបស់អាមេរិក និងទាហាន លន់ នល់ ។

នៅឆ្នាំ១៩៧៥ នៅពេលដែលខ្មែរក្រហមបានចាប់ផ្តើមគ្រប់គ្រងភូមិរបស់ម្តាយខ្ញុំ ក្រុមគ្រួសាររបស់ម្តាយខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យចាកចេញទៅរស់នៅស្រុកផ្សេង ។ ការជម្លៀសនេះ ម្តាយខ្ញុំបានរៀបរាប់ប្រាប់ខ្ញុំថា "នៅពេលជម្លៀស ក្រុមគ្រួសាររបស់គាត់ក៏ដូចជាក្រុមគ្រួសារផ្សេងទៀតដែលមានចំនួនរាប់រយគ្រួសារត្រូវបានបែកបាក់ពីឪពុកម្តាយបងប្អូននិងសាច់ញាតិដោយអង្គការបានបែកចែកឲ្យរស់នៅផ្សេងពីគ្នា" ។

ម្តាយខ្ញុំត្រូវបានអង្គការបញ្ជូនទៅរស់កងនារី ។ គាត់មិនដឹងថាឪពុកម្តាយរបស់គាត់ត្រូវបានអង្គការបញ្ជូនទៅទីណាទេ ដោយមិនបានទទួលដំណឹងអ្វីសោះពីអ្នកទាំងពីរ ។ ហើយចំណែកប្អូនបន្ទាប់បីនាក់ទៀត អង្គការបានបញ្ជូនទៅកងកុមារ ។ នៅក្នុងកងនារី ម្តាយខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យជីកដី ជីកប្រឡាយរស់នៅយ៉ាងណាលំបាកនៅទីនោះ ។ គាត់ក្រោកពីព្រលឹមទៅធ្វើការងាររហូតដល់ម៉ោង៦ល្ងាចទើបមកផ្ទះវិញ ។ ពេលសម្រាកគឺអាចសម្រាកបានតែនៅពេលបាយប៉ុណ្ណោះ ។ ការហូបចុកនៅទីនោះមិនគ្រប់គ្រាន់នោះទេ មានតែបបររាវៗប៉ុណ្ណោះ ។

នៅរដូវវស្សា ម្តាយខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យចូលទៅក្នុងក្រុមដកស្ទូង ។ បន្តដោយសំឡេងអួលដើមក គាត់បានប្រាប់ថា "ទោះបីជាភ្លៀងខ្លាំងយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងឈប់ដែរ" ។ ម្នាក់ៗខំប្រឹងធ្វើដើម្បីឲ្យទាន់ផែនការរបស់ដែលអង្គការចាត់តាំងហើយក៏គ្មាននរណាហ៊ានជំទាស់ដែរ បើហ៊ានជំទាស់អង្គការនឹងយកទៅសម្លាប់ចោលជាមិនខានឡើយ ។ ថ្ងៃមួយ ពេលដែលម្តាយខ្ញុំកំពុងស្ទូង មិត្តភក្តិរបស់គាត់បានឃើញកូនក្តាមមួយវៀរកាត់មុខ ។ ដោយសារភាពស្រេកឃ្លាន មិត្តភក្តិរបស់គាត់ក៏ចាប់កូនក្តាមនោះហូប ។ស្រាប់តែកងឈ្លបឃើញ រួចចាប់ខ្លួននិងស្រែកឡើងថា "មិត្តនារីចង់ក្បត់នឹងបក្សដូច្នេះត្រូវយកទៅកសាង" ។

ម្តាយរបស់ខ្ញុំនៅឃើញដូច្នេះ ក្នុងចិត្តរបស់គាត់ក្តុកក្តួលចំពោះមិត្តភក្តិជាខ្លាំងតែមិនអាចធ្វើអ្វីបានគឺបានត្រឹមតែអាណិតប៉ុណ្ណោះ ។ ចំណែកប្អូនប្រុសរបស់គាត់បីនាក់ទៀតដែលរស់នៅក្នុងកងកុមារត្រូវបានអង្គការចាត់តាំងឲ្យដើររើសអាចម៍គោតាមវាលស្រែដើម្បីយកមកធ្វើជី ។ ឯប្អូនប្រុសពីរនាក់ទៀតនៅតូចៗបានស្លាប់ដោយសារជំងឺលាប់កញ្ជ្រិល ។ រីឯឪពុករបស់គាត់ក៏បានស្លាប់ដែរដោយសារការអត់អាហារ ។ នេះគឺជាពាក្យសម្តីដែលអ្នកធ្វើការជាមួយជីតាខ្ញុំនិយាយពេលដែលគាត់នៅរស់ ។

ថ្ងៃមួយ ក្រុមរបស់ជីតាខ្ញុំប្អូននាក់បានសាច់សេះមកធ្វើជាម្ហូបជីតារបស់ខ្ញុំគាត់បានហូបច្រើនជាងគេហើយក៏ពុលស្លាប់តែម្តង ។ ចំណែកអ្នកផ្សេងទៀតគ្មាននរណាស្លាប់ទេគ្រាន់តែចុកពោះបន្តិចបន្តួចប៉ុណ្ណោះ ។

ពេលនោះម្តាយខ្ញុំនិយាយថា ពេលបានឮដំណឹងថាឪពុករបស់គាត់ស្លាប់ភ្លាម គាត់ក៏សុំអង្គការដើម្បីទៅមើលតែមិនត្រូវបានអនុញ្ញាតឲ្យទៅទេ ដោយនិយាយទៅកាន់ម្តាយខ្ញុំថា «នេះជារឿងរបស់បុគ្គលទេ»

ក្រោយពេលដែលកងទ័ពវៀតណាមចូលមករំដោះ ក្រុមគ្រួសាររបស់ម្តាយខ្ញុំក៏ជួបជុំគ្រួសារ ហើយនាំគ្នាវិលត្រឡប់ស្រុកកំណើតវិញ ។ ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅអស់រយៈពេលជាសាមសិបឆ្នាំហើយក៏ដោយ ក៏ស្លាកស្នាមនៃភាពឈឺចាប់នៃការបាត់បង់ក្រុមគ្រួសារឪពុកម្តាយ បងប្អូន សាច់ញាតិ និងមនុស្សជាទីស្រឡាញ់នៅតែដក់ក្នុងចិត្តគាត់ជានិច្ច ។

ជាចុងក្រោយ ម្តាយរបស់ខ្ញុំសង្ឃឹមថា មានតែតុលាការខ្មែរក្រហមទេដែលអាចស្វែងរកយុត្តិធម៌ជូនក្រុមគ្រួសាររបស់គាត់ក៏ដូចជាជនរងគ្រោះបានស្លាប់អស់ជិតពីរលាននាក់នឹងទទួលបាននូវយុត្តិធម៌ដ៏សមស្របមួយសម្រាប់ព្រលឹងរបស់អ្នកទាំងនោះក៏ដូចជាជនរងគ្រោះដែលបានរួចជីវិត ។

ដូច្នេះ ម្តាយរបស់ខ្ញុំ សំណូមពរឲ្យតុលាការមេត្តាពន្លឿនការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនោះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។ **ហេង សំណាង**

# រកឃើញប្អូនជីដូនមួយតាមរយៈទស្សនាវដ្តីស្វែងរកការពិត

នាងខ្ញុំឈ្មោះ ស ដួក ហៅ ធួក អាយុ៥៨ឆ្នាំ ស្រុកកំណើតនៅភូមិលេខ៥ ឃុំកំពង់លាង ស្រុកកំពង់លាវ ខេត្តព្រៃវែង ។ នាងខ្ញុំមានឪពុកឈ្មោះ អេង ស ជាប៉ូលីស (ស្លាប់នៅជំនាន់ លន់ នល់) និងម្តាយឈ្មោះ ស៊ុត នៃហេង (ស្លាប់នៅជំនាន់ខ្មែរក្រហម) ។

នាងខ្ញុំមានប្អូនជីដូនមួយឈ្មោះ ចក់ មុំ ហៅ ចក់ ប៉ូលីន បានចេញពីស្រុកខ្មែរទៅរស់នៅប្រទេសអាមេរិកក្រោយរបបខ្មែរក្រហម ។ ប៉ូលីន មានឪពុកឈ្មោះ រុំ ឬ សុទ្ធី ធ្វើជាពេទ្យ (អ្នកភូមិតែងហៅគាត់ថា ពេទ្យសុទ្ធី) ស្លាប់នៅមុំព្រែកពោធិ៍ដោយខ្មែរក្រហមចងគាត់រួចហើយយកទៅទម្លាក់ក្នុងទឹកទន្លេ ។ ចំណែកម្តាយឈ្មោះ ស៊ុត គឹមជួរ ជាមេផ្ទះ ។

ប៉ូលីន មានបងប្អូនបង្កើតបួននាក់ ។ បងទី១) ឈ្មោះ គឹម ឡាយ ប្រុស (ស្លាប់ជំនាន់ខ្មែរក្រហម) , បងទី២) ឈ្មោះ ស្រី (ស្លាប់ជំនាន់ខ្មែរក្រហម) ទី៣) ប៉ូលីន និងទី៤) ប្អូនស្រីពៅឈ្មោះ គឹម អួន សព្វថ្ងៃរស់នៅស្រុកពញាក្រែក ខេត្តកំពង់ចាម ។

ប៉ូលីន បានមកលេងស្រុកខ្មែរម្តងកាលពីឆ្នាំ១៩៩៧ ហើយគាត់បានជួបខ្ញុំ ប្តីខ្ញុំ ព្រមទាំងកូនខ្ញុំម្នាក់ និងបានជួបជាមួយប្អូនបង្កើតរបស់គាត់ឈ្មោះ គឹម អួន និងប្តីព្រមទាំងកូនបួននាក់ទៀតនៅភ្នំពេញ ។ គ្រួសារនាងខ្ញុំ និងគ្រួសារ អួន បានថតរូបជុំគ្នានៅព្រះបរមរាជវាំងដើម្បីទុកជាអនុស្សាវរីយ៍ ។ នៅឆ្នាំនោះ ប៉ូលីន មិនបានទៅលេងស្រុកកំណើតនៅខេត្តព្រៃវែងទេ ព្រោះពេលនោះ ប្រទេសកម្ពុជាកំពុងមានចលាចល ហើយគាត់ក៏ត្រឡប់ទៅសហរដ្ឋអាមេរិកវិញ ។ ចាប់តាំងពីពេលនោះមក យើងក៏ដាច់ការទាក់ទងគ្នារហូត ។

ទើបតែមកដល់ថ្ងៃទី២ ខែសីហា ឆ្នាំ២០១២នេះ បងស្រីជីដូនមួយរបស់នាងខ្ញុំឈ្មោះ សៀវ ធ្វើការនៅក្រុមប្រឹក្សាខេត្តព្រៃវែងបានឃើញដំណឹងស្វែងរកគ្រួសារសរសេរដោយ ចេស៊ីកា កៀសាន់ (ត្រូវជាកូនរបស់ ចក់ ប៉ូលីន) និងបានឃើញរូបខ្ញុំដែលថតនៅខាងមុខព្រះបរមរាជវាំងកាលពីឆ្នាំ១៩៩៧) បោះពុម្ពផ្សាយក្នុងទស្សនាវដ្តីស្វែងរកការពិត លេខ១៣៥ ខែមីនា ឆ្នាំ២០១១ ។ ភ្លាមនោះបងសៀវ ក៏បានទូរស័ព្ទប្រាប់អំពីដំណឹងស្វែងរកគ្រួសារនេះមកនាងខ្ញុំនៅខេត្តសៀមរាប ព្រោះគ្រួសារនាងខ្ញុំបានផ្លាស់ពីខេត្តព្រៃវែងទៅរស់នៅខេត្តសៀមរាបតាំងពីឆ្នាំ២០០០មកម្ល៉េះ ។ នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២ នាងខ្ញុំនិងប្តីបានមកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបានជួបជាមួយលោក ញាណ សុជាតិ ដើម្បីសួរនាំពីដំណឹងប្អូន ប៉ូលីន និងក្មួយ ចេស៊ីកា ។ ខ្ញុំសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានជួយផ្សព្វផ្សាយពីដំណឹងស្វែងរកគ្រួសារនិងឲ្យខ្ញុំនិងប្អូនជីដូនមួយរបស់ខ្ញុំអាចជួបគ្នាឡើងវិញ ។

***សូមអរគុណ!***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៩៥៥ ៨៥៨ ឬ អ៊ីម៉ែល : truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

**សូមផ្តល់ព័ត៌មានដូចខាងក្រោម :**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ : ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ : ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ : លេខទូរស័ព្ទ អាសយដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម :**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ : រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ


ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ន័រវេ៉ និងសហរដ្ឋអាមេរិក

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 152, August 2012 ◆ Funded by Norway and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.